សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# របបពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែ មេសា ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៧

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **ក.យ៉េន ទណ្ឌីដា**

**ក.អ៊ឹង ហ៊ុយគង់**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ម៉ូលី បញ្ញា**

ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ

ជំនាន់ទី២១ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១២

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ យ៉េន វណ្ណីដា និង អ៊ឹង ហ៊ុយគង់ ជានិស្សិតថ្នាក់ បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ថ្នាក់អាហារូបករណ៍ ជំនាន់ទី២១ ក្រុម$L_4C_4$ និង $L_4A_5$ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

*សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖*

- លោកឪពុក អ្នកម្តាយ អ្នកមានគុណ ដែលបានផ្តល់កំណើត ថែមទាំងបានបាច់បីថែរក្សាទំនុកបម្រុងផ្នែកស្មារតី និងសម្ភារៈ និងជំបូន្មានល្អៗដល់កូនៗគ្រប់ពេលវេលា ហើយតែងតែអធ្យាស្រ័យរាល់កំហុសខុសឆ្គងរបស់កូន។ ពិសេសជាងនេះទៅទៀតលោកទាំងបួនបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ដើម្បីឱ្យកូនបានសិក្សាជ្រៅជ្រះ និងមានអនាគតល្អ។ គុណរបស់លោកទាំងបួនធ្ងន់ជាងប្រថពី ដែលមិនអាចឱ្យកូនបំភ្លេចបាន ហើយកូនប្តេជ្ញាថា នឹងខិតខំបំពេញនូវបំណងប្រាថ្នារបស់លោកទាំងបួនជាការតបស្នងសងគុណ ។

- ឯកឧត្តម **លុយ ចណ្ណា** សាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងលោក លោកស្រី សាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់នូវទីកន្លែងសិក្សា និងឯកសារផ្សេងៗ នៅក្នុងបណ្ណាល័យ ដើម្បីជាជំនួយក្នុងការស្រាវជ្រាវរបស់យើងខ្ញុំ ។

- លោកស្រីសាស្ត្រាចារ្យ **ម៉ូលី បញ្ញា** ដែលមិនត្រឹមតែបង្ហាត់បង្រៀនដល់យើងខ្ញុំប៉ុណ្ណោះទេតែ ថែមទាំងចំណាយពេលវេលាដ៏មានតម្លៃ ជួយណែនាំពន្យល់ក្នុងការធ្វើសារណាបញ្ចប់ការសិក្សានេះ ដោយយកចិត្តទុកដាក់ជាទីបំផុត ។

- ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលផ្តល់ឱកាស និងការស្វាគមន៍ ទំនុកបម្រុងយ៉ាងកក់ក្តៅ ជាពិសេស លោក **អ៊ឹម ភុយ** ជាអនុប្រធាននាយកដ្ឋាននីតិកម្មនៃក្រសួងពាណិជ្ជកម្ម និងលោក **កែវ ម៉ុនថេង** ជាមន្ត្រីនៃការិយាល័យច្បាប់ពាណិជ្ជកម្ម ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការស្រាយបំភ្លឺនូវរាល់ចម្ងល់ទាំងឡាយ ក្នុងអំឡុងពេលនៃការចុះទៅសិក្សាស្រាវជ្រាវនៅក្រសួងពាណិជ្ជកម្ម និងបានណែនាំយើងខ្ញុំនូវឯកសារពិគ្រោះនានាដែលចូលរួមចំណែកយ៉ាងសំខាន់ក្នុងការតាក់តែងសារណានេះឡើង។

ជាចុងក្រោយ យើងខ្ញុំសូមលំឱនកាយបួងសួងដល់ទេព្តា និងវត្ថុសក្តិសិទ្ធិទាំងអស់ សូមឱ្យលោកឪពុក អ្នកម្តាយ សាស្ត្រាចារ្យ និងបុគ្គលដែលបានរៀបរាប់ខាងលើ ជួបប្រទះតែសេចក្តីសុខសុភមង្គល និងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

# អារម្ភកថា

យើងខ្ញុំជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី៤ មានសេចក្តីសោមនស្ស រីករាយ ដោយបានតាក់តែងនូវសារណាមួយក្រោមប្រធានបទ **"របបពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក"** ឱ្យលេចចេញជារូបរាងឡើង។ សមិទ្ធផលនេះបានកើតចេញពីការស្រាវជ្រាវ លើឯកសារពាក់ព័ន្ធទាំងឡាយរួមមានលិខិតបទដ្ឋានគតិយុត្តនានា ឯកសារពិគ្រោះរបស់សាស្ត្រាចារ្យ និងស្ថាប័ននានាទាំងក្នុងស្រុក និងបរទេស កិច្ចពិគ្រោះយោបល់ជាមួយអ្នកជំនាញ ព្រមទាំងការប្រមូលផ្តុំចំណេះដឹងផ្នែកច្បាប់ ដែលទទួលបានក្នុងរយៈពេល៤ឆ្នាំកន្លងមកនេះ។

យើងខ្ញុំយល់ឃើញថាប្រធានបទនេះពិតជាមានសារៈសំខាន់ខ្លាំងដល់យើងទាំងពីរ និងអ្នកអានដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ពីការធ្វើទំនាក់ទំនងពាណិជ្ជកម្មផ្សារភ្ជាប់ទៅនឹងនីតិពាណិជ្ជ-កម្ម និងជាពិសេសទៅទៀតនោះ គឺយល់ដឹងពីរបត់ថ្មីមួយនៅក្នុងវិស័យពាណិជ្ជកម្ម ដែលគេអាចធ្វើសកម្មភាពនេះបានដោយប្រើប្រាស់បច្ចេកវិទ្យាថ្មី នោះគឺប្រព័ន្ធអេឡិចត្រូនិក។ ថ្វីត្បិតតែ មានការអភិវឌ្ឍខ្លាំង ហើយប្រទេសជាច្រើនលើពិភពលោកបាន និងកំពុងតែប្រើប្រាស់ និងទាញយកផលប្រយោជន៍ ពីបច្ចេកវិទ្យាទំនើបនេះ ប៉ុន្តែសម្រាប់ប្រទេសកម្ពុជា ពាណិជ្ជកម្មតាមប្រព័ន្ធបច្ចេក-វិទ្យានេះ គឺជាគំនិតថ្មីមួយនៅឡើយ។ ជាក់ស្តែង ប្រទេសកម្ពុជា មិនទាន់មានច្បាប់គ្រប់គ្រងលើសកម្មភាពនោះទេ។ ដូច្នេះ យើងខ្ញុំសង្ឃឹមថា ការសិក្សានេះអាចចូលរួមចំណែកជាចំណេះដឹង និងការផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយពាក់ព័ន្ធទៅនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ក្នុងការស្រាវជ្រាវនេះ យើងក៏បានជួបប្រទះនូវឧបសគ្គមួយចំនួន ដូចជាកង្វះខាតនូវឯកសារពិគ្រោះនានា ដោយសារនីតិពាណិជ្ជកម្មជាមុខវិជ្ជាមួយដែលមានសាស្ត្រាចារ្យតិចតួចដែលចាប់យកជំនាញផ្នែកនេះនិងតាក់តែងជាឯកសារពិគ្រោះឡើង។ ម្យ៉ាងទៀត ប្រធានបទនៃការស្រាវជ្រាវក៏មានលក្ខណៈថ្មី សម្រាប់បរិបទនៃប្រទេសកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ តាមរយៈការស្រាវជ្រាវលើឯកសារពិគ្រោះទាំងក្នុងស្រុក និងបរទេស ការសំណេះសំណាលសុំយោបល់ពីសាស្ត្រាចារ្យ និង មន្ត្រីក្រសួងពាណិជ្ជកម្ម ធ្វើឱ្យយើងអាចជំនះនូវឧបសគ្គទាំងឡាយហើយធ្វើការបញ្ចប់សារណានេះ ជាមួយចំណេះដឹងជាច្រើនពីការស្រាវជ្រាវ។

ដោយសារណានេះ គឺជាស្នាដៃដំបូង យើងខ្ញុំជឿជាក់ថាការខ្វះខាតដោយប្រការណាមួយដូចជា ការបកស្រាយ ការប្រើប្រាស់ពាក្យពេចន៍ ឃ្លាឃ្លោង អក្ខរាវិរុទ្ធ ជាដើម ប្រាកដជាជៀសមិនផុត។ អាស្រ័យហេតុនេះ យើងខ្ញុំសូមអភ័យទោសជាមុនរាល់កំហុសទាំងឡាយដែលកើតឡើងដោយឥតព្រាងទុក និងទទួលយកនូវមតិរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យសារណានេះមានខ្លឹមសារកាន់តែល្អប្រសើរឡើងមួយកម្រិតទៀត។

# មាតិកា

**ទំព័រ**

**សេចក្ដីផ្ដើម**

**ជំពូកទី១**

**សញ្ញាណទូទៅនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

**១.១. ប្រវត្តិនៃការបង្កើតពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ........ ៤

**១.១.១. អត្ថន័យនៃរបបពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកតាមច្បាប់អន្តរជាតិ** ........ ៧

**១.១.១.១. អង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍ ១៩៩៧** (Organization for Economic Co-operation and Development "OECD", 1997) ........ ៧

**១.១.១.២. ក្រុមខណ្ឌអ៊ីអាស៊ាន** ( E-ASEAN ) ........ ៨

**១.១.២. ភាពខុសគ្នានៃរបបពាណិជ្ជកម្មទូទៅ និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូ–និក** ........ ៩

**១.១.២.១. លក្ខណៈទូទៅ** ........ ៩

ក. តម្លៃ និងពេលវេលា ........ ១០

ខ. លទ្ធភាពនៃការទទួលព័ត៌មានទំនិញនិងជម្រើសរបស់អ្នកប្រើប្រាស់ ........ ១០

គ. ព័ត៌មានវិទ្យា (Information Technology) ........ ១០

**១.១.២.២. លក្ខណៈច្បាប់** ........ ១០

ក. ការបង្កើតកិច្ចសន្យា ........ ១០

ខ.សមត្ថភាពរបស់ភាគី ........ ១១

គ. ការបង្ហាញឆន្ទៈ ........ ១២

**១.២. សញ្ញាណនៃរបបពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា** ........ ១៣

**១.២.១. បច្ចុប្បន្នភាព និងភាពចាំបាច់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅប្រទេសកម្ពុជា** ........ ១៣

**១.២.២. សេចក្ដីព្រាងច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ........ ១៤

**១.២.២.១. និយមន័យនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ........ ១៤

១.២.២.២. បច្ចុប្បន្នភាពនៃសេចក្ដីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូ-និកនៅប្រទេសកម្ពុជា និងខ្លឹមសារសំខាន់ៗ ..... ១៧

# ជំពូកទី២

# របបគតិយុត្តនៃការបង្កើតកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

២.១. ការបង្កើតកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ..... ២១

២.១.១. លក្ខខណ្ឌសុពលភាពគតិយុត្តនៃទំនាក់ទំនងអេឡិចត្រូនិក ..... ២១

២.១.១.១. ទម្រង់លាយលក្ខណ៍អក្សរ ..... ២២

២.១.១.២. ហត្ថលេខា ..... ២៥

២.១.១.៣. ទម្រង់ដើម ..... ២៩

២.១.១.៤. តស្តុតាង ..... ៣២

២.១.២. ការបង្កើត និងអានុភាពគតិយុត្តនៃកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិច-ត្រូនិក ..... ៣៤

២.២. កិច្ចប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ..... ៣៥

២.២.១. កិច្ចប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅប្រទេសកម្ពុជា ..... ៣៦

២.២.១.១. ការជ្រើសរើសទំនិញ ..... ៣៧

២.២.១.២. ការបញ្ជាទិញ ..... ៣៧

២.២.១.៣. ការទូទាត់ប្រាក់ ..... ៣៧

២.២.១.៤. ការដឹកជញ្ជូន និងការទទួលទំនិញ ..... ៣៩

២.២.២. កិច្ចប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅប្រទេសដទៃ ..... ៣៩

២.២.២.១. ការជ្រើសរើសទំនិញ ..... ៤០

២.២.២.២. ការបញ្ជាទិញ ..... ៤០

២.២.២.៣. ការទូទាត់ប្រាក់ ..... ៤១

២.២.២.៤. ការដឹកជញ្ជូននិងការទទួលទំនិញ ..... ៤១

# ជំពូកទី៣

# ឱកាស និងបញ្ហាប្រឈមនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

៣.១. ឱកាសនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ..... ៤២

៣.២. បញ្ហាដែលអាចប្រឈមរបស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ..... ៤៣

**៣.២.១. បញ្ហាប្រឈមរបស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅប្រទេសកម្ពុជា** ៥៤

**៣.២.២. ការសិក្សាទៅលើបញ្ហា និងរកដំណោះស្រាយដោយសិក្សាពីប្រទេសជនៃ** ....៥៦

**៣.២.២.១. ការទូទាត់ និងការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិច** ( e-payment ) .....៥៦

ក. បញ្ហា ......................................................................................................................... ៥៧

ខ. ដំណោះស្រាយ ................................................................................................................ ៥៨

**៣.២.២.២. ការដោះស្រាយវិវាទ** ................................................................................ ៥៩

**សេចក្ដីសន្និដ្ឋាន** ..................................................................................................................... ៦២

**ឯកសារយោង**

**ឧបសម្ព័ន្ធទី១** សេចក្តីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ២០១៦

**ឧបសម្ព័ន្ធទី២** UNCITRAL Model Law on Electronic Commerce, 1998

**ឧបសម្ព័ន្ធទី៣** រូបភាពនៃប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅប្រទេសជប៉ុន

# សេចក្តីផ្តើម

សញ្ញាណនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានគេរកឃើញថាមានវត្តមានជាយូរក្រាស់ក្រែលមកហើយ។ យ៉ាងណាមិញ បន្តិចម្តងៗ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បាន និងកំពុងលេចចេញជារូបរាងឡើងនៅក្នុងប្រទេសកម្ពុជា ស្របពេលដែលចំនួនប្រជាជន ដែលប្រើប្រាស់អ៊ីនធើណេត និងឧបករណ៍អេឡិចត្រូនិក ជាពិសេសទូរសព្ទដៃទំនើប នៅប្រទេសកម្ពុជាមានចំនួនកាន់តែច្រើនឡើងៗ។ ម្យ៉ាងទៀត ការចូលជាសមាជិកអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក គួបផ្សំនឹងស្ថានភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់ប្រទេសជាច្រើន នៅលើ ពិភពលោក រួមទាំងប្រទេសជាសមាជិកនៃអាស៊ាន ដែលជាប្រទេសជិតខាងរបស់ប្រទេសកម្ពុជា កំពុងតែមានការលូតលាស់គួរឱ្យកត់សម្គាល់ វាជាការចាំបាច់ដែលប្រទេសកម្ពុជា ត្រូវរៀបចំខ្លួនដើរឱ្យទាន់ការវិវត្តនៃពិភពលោក តាមរយៈការកែលម្អចំណុចខ្វះខាតទាំងឡាយ ធ្វើយ៉ាងណាធានាថាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អាចដំណើរការទៅបានដោយរលូន។ អាស្រ័យដោយហេតុនេះហើយ ទើបប្រទេសកម្ពុជា បាន និងកំពុងធ្វើការតាក់តែង សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឱ្យលេចចេញជារូបរាងឡើង ហើយស្ថាប័នពាក់ព័ន្ធនានាបានព្យាយាម និងរំពឹងថាសេចក្តីព្រាងច្បាប់នេះ នឹងត្រូវបានអនុម័តដាក់ឱ្យអនុវត្តនៅក្នុងរវាងឆ្នាំ ២០១៧ នេះ។

ដោយយកគំរូតាមច្បាប់គំរូស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្នាំ១៩៩៨ (UNCITRAL Model Law on Electronic Commerce, 1998) សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេ-ឡិចត្រូនិក មានគោលបំណងសំខាន់ក្នុងការបង្កើតឱ្យមានជាបទដ្ឋានច្បាប់ សម្រាប់គ្រប់គ្រងសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៅប្រទេសកម្ពុជា ដែលមានលក្ខណៈថ្មីស្រឡាងនៅឡើយចំពោះប្រជាជនភាគច្រើន។ ជាក់ស្តែង សេចក្តីព្រាងច្បាប់នេះ បានផ្តល់និយមន័យ និងបញ្ញត្តិពីលក្ខខណ្ឌសំខាន់នានា របស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងគោលបំណងបញ្ជ្រាបពីសញ្ញាណនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ទៅក្នុងស្រទាប់ប្រជាជន។ ជាងនេះទៅទៀត សេចក្តីព្រាងច្បាប់នេះ ក៏មានគោលបំណងដោះស្រាយបញ្ហាប្រឈមសម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកផងដែរ ដូចជាបញ្ញត្តិពីការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ក៏ដូចជាបទ-ល្មើសមួយចំនួន ក្នុងគោលបំណងការពារដល់អ្នកប្រើប្រាស់ នៅក្នុងទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

បើទោះជា មានការខិតខំប្រឹងប្រែងពីស្ថាប័នពាក់ព័ន្ធនានា ក្នុងការតាក់តែងសេចក្តីព្រាងច្បាប់នេះយ៉ាងណាក៏ដោយ បញ្ហាប្រឈមជាច្រើននៅតែត្រូវបានគេមើលឃើញ ហើយទាមទារឱ្យ

មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីធានាបានថា ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅប្រទេសកម្ពុជា អាចដើរទាន់បណ្ដាប្រទេសដទៃទៀតលើសកលលោក ដែលមានប្រព័ន្ធគ្រប់គ្រងសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកយ៉ាងជឿនលឿន ដូចជាប្រទេសជប៉ុន កូរ៉េជាដើម។ មួយវិញទៀត ដោយសារពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជាគំនិតមួយថ្មីសម្រាប់ប្រទេសកម្ពុ-ជា ហេតុនេះ ការផ្សព្វផ្សាយខ្លឹមសារ និងវិធានស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ទៅក្នុងស្រទាប់ប្រជាជន បន្ទាប់ពីបានអនុម័តរួច ជាកត្តាសំខាន់ដែលធ្វើឱ្យគ្រប់ជ្រុងជ្រោយចំពោះការដាក់ឱ្យអនុវត្តច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនាពេលអនាគត ដើម្បីធានាថា ជាបឋមយ៉ាងហោចណាស់ប្រជាជន អាចបានទទួលបានការយល់ជាមូលដ្ឋានខ្លះពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ។

អាស្រ័យដូចបានរៀបរាប់ខាងលើនេះហើយ ទើបសារណា ដែលសិក្សាអំពីរបបពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ សិក្សាឱ្យបានស៊ីជម្រៅទៅលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ថាតើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ មានដើមចមនិងភាពចាំបាច់យ៉ាងណានៅក្នុងប្រទេសកម្ពុជា សកម្មភាពអ្វីខ្លះដែលគេហៅថាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ហើយតើសកម្មភាពនោះខុសគ្នាយ៉ាងដូចម្ដេចទៅនឹងពាណិជ្ជកម្មទូទៅ ចុះតើបច្ចុប្បន្នពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូ-និកនេះបានវិវត្តដល់ណាហើយ ហើយដំណើរការទំនាក់ទំនងប្រព្រឹត្តទៅយ៉ាងដូចម្ដេចដែរ អ្វីខ្លះជាបញ្ហាប្រឈម និងគួរមានដំណោះស្រាយយ៉ាងណាវិញចំពោះបញ្ហាប្រឈមទាំងនោះ។

គួរកត់សម្គាល់ផងដែរថា ដោយសារតែពេលវេលាមានកំណត់ រីឯ ឯកសារស្រាវជ្រាវទៀតសោតមិនមានភាពទូលំទូលាយ ហើយជាពិសេសទៅទៀតនោះ វិសាលភាពដ៏ធំទូលាយនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកផ្ទាល់ ការសិក្សានេះ មិនរំពឹងថានឹងអាចសិក្សាឱ្យបានគ្រប់ជ្រុងជ្រោយទៅលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះទេ ដោយសារណានេះត្រូវបានរៀបរៀងឡើងជា បី ជំពូក។ ជំពូកទី១ រៀបរាប់ពីសញ្ញាណទូទៅនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលរួមមានទាំង ប្រវត្តិនៃការបង្កើតពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងសញ្ញាណនៃពាណិជ្ជ-កម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា។ ជំពូកទី២ សិក្សាអំពីរបបគតិយុត្តនៃការបង្កើតកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយផ្ដោតទៅលើការបង្កើតកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងកិច្ចប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ជំពូកទី ៣ លើកឡើងពីឱកាស និងបញ្ហាប្រឈមនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលក្នុងនោះរួមមាន ឱកាស

ពេលគឺគុណសម្បត្តិនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងបញ្ហាដែលអាចប្រឈមរបស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

# ជំពូកទី១

# សញ្ញាណទូទៅនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានទម្រង់ បែបបទស្រដៀងគ្នានៅទូទាំងពិភពលោក តែច្បាប់គ្រប់គ្រងមានលក្ខណៈខុសគ្នាទៅតាមបរិបទប្រទេសនីមួយៗ។ ប៉ុន្មានឆ្នាំចុងក្រោយនេះ គេឃើញមានសន្ទុះនៃការកើនឡើង ដ៏គួរឱ្យកត់សម្គាល់នៃទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅប្រទេសកម្ពុជាទាំងក្នុងទីផ្សារជាតិ និងអន្តរជាតិ ជាពិសេសនៅក្នុងវិស័យឯកជនចំពោះក្រុមហ៊ុនធុនតូច។ នៅក្នុងជំពូកនេះ យើងនឹងសិក្សាអំពីប្រវត្តិនៃរបបពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (១.១) ដោយរៀបរាប់ពីប្រវត្តិនៃការបង្កើត និងផ្តោតសំខាន់ទៅលើអត្ថន័យនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកស្របតាមវចនានុក្រម និងវិធានច្បាប់អន្តរជាតិដែលមានបញ្ញត្តិពីសញ្ញាណនៃរបបពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា (១.២) ដែលបកស្រាយពីអត្ថន័យទៅតាមច្បាប់វិជ្ជមានរបស់ប្រទេសកម្ពុជា រៀបរាប់អំពីស្ថានភាពនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅប្រទេសកម្ពុជានិងភាពចាំបាច់នៃប្រព័ន្ធពាណិជ្ជកម្ម និងច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

## ១.១. ប្រវត្តិនៃការបង្កើតពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានលេចរូបរាងឡើងដំបូង នាពាក់កណ្តាលសតវត្សទី១៨ ស្របពេលទៅនឹងការបង្កើតកិច្ចសន្យាដំបូងបំផុត ដោយប្រើប្រាស់ម៉ាស៊ីនទូរលេខ និងទូរសព្ទ។ ការវិវត្តបន្ទាប់មកទៀតនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានគេសម្គាល់ថាជាប្រតិបត្តិការនៃទំនិញ និងសេវាតាមរយៈប្រព័ន្ធអ៊ីនធើណេត ដោយចាប់ផ្តើមជាប់ទាក់ទងទៅនឹងសកម្មភាពជំនួញ។ បន្ទាប់មកនៅឆ្នាំ១៩៨០ ប្រព័ន្ធអ៊ីនធើណេតបានក្លាយទៅជាវិធីដ៏សមស្របមួយដែលផ្តល់លទ្ធភាពឱ្យកុំព្យូទ័រទាំងអស់អាចផ្លាស់ប្តូរ និងផ្ទេរទិន្នន័យព័ត៌មានបានយ៉ាងស្មើភាព។

លើសពីនេះ នៅក្រោយពាក់កណ្តាលឆ្នាំ១៩៦០ កិច្ចប្រតិបត្តិការធនាគារតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានចាប់ផ្តើម។ បន្ទាប់មក ប្រព័ន្ធអ៊ីនធើណេតក៏បានរីកលូតលាស់ដោយតភ្ជាប់បណ្តាញពីក្រុមហ៊ុនមួយទៅក្រុមហ៊ុនផ្សេងៗជាច្រើនដែលនាំឱ្យរាល់ការបញ្ជូនព័ត៌មាន និងទំនាក់ទំនងធ្វើឡើងក្នុងលក្ខខណ្ឌដ៏រហ័ស និងងាយស្រួល ហើយវាក៏ត្រូវបានគេស្គាល់ថាជាប្រព័ន្ធស្តង់ដារមួយដែលជំរុញឱ្យការផ្លាស់ប្តូរទិន្នន័យរវាងក្រុមហ៊ុននិងក្រុមហ៊ុនតាមរយៈប្រព័ន្ធអេឡិចត្រូនិក (Electronic Data Interchange) ផងដែរ។ នៅឆ្នាំ១៩៩១ ចំនួនអ្នកប្រើប្រាស់អ៊ីនធើណេត មានមិនដល់ ៣ លាននាក់ទេ នៅទូទាំងពិភពលោក ហើយការប្រើប្រាស់អ៊ីនធើណេតនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធ

អេឡិចត្រូនិកក៏មិនឃើញមានវត្តមានដែរ។ ប្រហែល ១ ទសវត្សក្រោយមក ក្នុងអំឡុងឆ្នាំ ១៩៩៩ ទិន្នន័យបានបង្ហាញថា អ្នកដែលចូលប្រើប្រាស់ដំណើរការប្រព័ន្ធអ៊ីនធើណេតបានកើនឡើងដល់ ៣០០លាននាក់ ស្មើ១ភាគ៤ នៃអ្នកប្រើប្រាស់ទាំងនោះបានធ្វើការទិញទំនិញតាមរយៈអនឡាញពីគេហទំព័រពាណិជ្ជកម្មអេឡិចត្រូនិក ដែលមានតម្លៃប្រហែល ១១០ កោដដុល្លារអាមេរិក។[1]

នៅឆ្នាំ១៩៩៦ គណៈកម្មការច្បាប់ពាណិជ្ជកម្មអន្តរជាតិរបស់អង្គការសហប្រជាជាតិ (United Nations Commission on International Trade Law "UNCITRAL") បានអនុម័តនូវច្បាប់គំរូស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (UNCITRAL Model Law on Electronic Commerce) ក្នុងគោលបំណងដើម្បីជួយសម្រួលដល់មធ្យោបាយទំនើបក្នុងការទំនាក់ទំនង និងការផ្ទុកនូវព័ត៌មានដូចជាការផ្លាស់ប្តូរទិន្នន័យតាមប្រព័ន្ធអេឡិចត្រូនិក (Electronic Data Interchange) សារអេឡិចត្រូនិក ដោយអាចប្រើប្រាស់ប្រព័ន្ធអ៊ីនធើណេត ឬ មិនប្រើប្រាស់ប្រព័ន្ធអ៊ីនធើណេត។ ទាំងនេះ គឺពឹងផ្អែកទាំងស្រុងទៅលើការបង្កើតឱ្យមានមុខងារដូចគ្នាទៅនឹងខ្លឹមសារនៅលើក្រដាស ដូចជា ទម្រង់ជាលាយលក្ខណ៍អក្សរ ហត្ថលេខា និងទម្រង់ដើមជាដើម។ គោលការណ៍ចម្បងដែលមាននៅក្នុងច្បាប់គំរូស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គឺ "ភាពស្មើគ្នានៃទម្រង់អេឡិចត្រូនិក (electronic equivalence)" ដែលមានបញ្ញត្តិនៅក្នុងមាត្រា ៥ នៃច្បាប់គំរូស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ។ ថ្វីត្បិតតែ ច្បាប់គំរូ មិនបានចាត់ទុកទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិកថាមានសុពលភាពដូចឯកសារជាក្រដាស ប៉ុន្តែច្បាប់គំរូបានកំណត់ថាព័ត៌មាន ឬ ឯកសារ ទាំងឡាយនឹងមិនត្រូវបានបដិសេធពីសុពលភាពគតិយុត្ត និងភាពដែលអាចអនុវត្ត ដោយសំអាងតែលើហេតុផលថា វាត្រូវបានធ្វើឡើងនៅក្នុងទម្រង់អេឡិចត្រូនិក។

ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០០ ក្រុមការងារនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក របស់គណៈកម្មការច្បាប់ពាណិជ្ជកម្មអន្តរជាតិ របស់អង្គការសហប្រជាជាតិ (UNCITRAL Working Group on Electronic Commerce) បានឯកភាពលើច្បាប់គំរូស្តីពីហត្ថលេខាតាមប្រព័ន្ធអេឡិចត្រូនិក (UNCITRAL Model Law on Electronic Signatures) នៅក្នុងកិច្ចប្រជុំលើកទី៣៧ របស់ខ្លួន នៅទីក្រុងហ្សឺណែវ។ ច្បាប់គំរូស្តីពីហត្ថលេខាតាមប្រព័ន្ធអេឡិចត្រូនិក ចូលជាធរមាននៅក្នុងឆ្នាំ២០០១។ មាត្រា ១ នៃច្បាប់គំរូនេះ បានបញ្ញត្តិថាច្បាប់នេះត្រូវអនុវត្តនៅក្នុងករណីដែលហត្ថលេខាតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបាននៅក្នុងសកម្មភាពពាណិជ្ជកម្ម ។ ដោយ

[1] World Trade Organization 'E-commerce in Developing Countries' 2013 , ទំព័រ 3

ទៀត ច្បាប់នេះមិនបដិសេធវិធាននៃច្បាប់ណាដែលមានគោលបំណងការពារអ្នកប្រើប្រាស់នោះទឡើយ។

បន្ថែមពីនេះ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៥ មហាសន្និបាតរបស់អង្គការសហប្រជាជាតិ (United Nations General Assembly) បានអនុម័តនូវសន្ធិសញ្ញាស្តីពីការប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកនៅក្នុងកិច្ចសន្យាអន្តរជាតិ (The United Nations Convention on the Use of Electronic Communications in International Contracts "The Electronic Communications Convention" or "ECC") ដែលរៀបចំឡើងដោយ គណៈកម្មការច្បាប់ពាណិជ្ជកម្មអន្តរជាតិរបស់អង្គការសហប្រជាជាតិ (UNCITRAL) ក្នុងគោលបំណងជួយសម្រួលដល់ ការប្រើប្រាស់ទំនាក់ទំនងតាមប្រព័ន្ធអេឡិច-ត្រូនិកនៅក្នុងពាណិជ្ជកម្មអន្តរជាតិ។ សន្ធិសញ្ញានេះត្រូវបានបង្កើតឡើងពីព្រោះថាបើទោះបីជា ច្បាប់គំរូស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (UNCITRAL Model Law on Electronic Commerce) និងច្បាប់គំរូស្តីពីហត្ថលេខាតាមប្រព័ន្ធអេឡិចត្រូនិក (UNCITRAL Model Law on Electronic Signatures) ត្រូវបានអនុម័តនៅឆ្នាំ១៩៩៦ និងឆ្នាំ១៩៩៨ ប៉ុន្តែបញ្ហាមួយចំនួននៅតែមិនត្រូវបានដោះស្រាយ ដែលរួមមានភាពដែលអាចធ្វើទៅបាននូវការជម្រុញឱ្យមានការប្រើប្រាស់ទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងករណីដែលមានការទាមទារជាចាំបាច់ឱ្យប្រើប្រាស់ទម្រង់ជាលាយលក្ខណ៍អក្សរដោយសន្ធិសញ្ញាផ្សេង (ជាទូទៅសន្ធិសញ្ញានោះត្រូវបានតាក់តែងឡើង នៅមុនពេលមធ្យោបាយទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានផ្សព្វផ្សាយ) ។ មួយវិញទៀត ច្បាប់គំរូទាំងពីរនោះត្រូវបានបង្កើតឡើងដោយផ្អែកលើភាពផ្សេងៗគ្នានៃយុត្តាធិការមួយចំនួន ហេតុនេះការបង្កើតឱ្យមានវិធានច្បាប់ជាក់លាក់មួយ អាចបង្កើននូវភាពស្របគ្នានៃច្បាប់ស្តីពីពាណិជ្ជកម្មអន្តរជាតិ។ មិនតែប៉ុណ្ណោះ មានការព្រួយបារម្ភថាវិធាននៃច្បាប់គំរូទាំងពីរ អាចមានលក្ខណៈចាស់គំរឹល មិនស្របតាមការវិវត្តនៃសម័យកាល។ ដោយយោងលើហេតុផលទាំងនេះ ហើយទើបសន្ធិសញ្ញាស្តីពីការប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកនៅក្នុងកិច្ចសន្យាអន្តរជាតិ (The United Nations Convention on the Use of Electronic Communications in International Contracts) ត្រូវបានអនុម័តឡើង។

មុននឹងឈានដល់ការបកស្រាយឱ្យបានជ្រាលជ្រៅ អំពីរបបពាណិជ្ជកម្មតាមប្រព័ន្ធអេឡិច-ត្រូនិក យើងត្រូវយល់ឱ្យច្បាស់នូវនិយមន័យនៃពាក្យគន្លឹះ ដែលនៅក្នុងផ្នែកនេះ នឹងធ្វើការសិក្សាអំពី អត្ថន័យនៃរបបពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក **(១.១.១)** ដែលនឹងកំណត់សម្គាល់អត្ថន័យនៃពាណិជ្ជកម្ម និងអេឡិចត្រូនិក ទៅតាមវចនានុក្រម លិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ។

លើសពីនេះ ក៏បង្ហាញពីភាពខុសគ្នានៃរបបពាណិជ្ជកម្មទូទៅ និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (១.១.២) ផងដែរ។

### ១.១.១. អត្ថន័យនៃរបបពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកតាមច្បាប់អន្តរជាតិ

ដោយយោងតាមវចនានុក្រមភាសាអង់គ្លេសអន្តរជាតិ[2]ពាក្យ *ពាណិជ្ជកម្ម (Commerce)* ថ្នាក់ពាក្យជានាម គឺជាការទិញ និងលក់នៃទំនិញ និងសេវា។ ចំណែកឯពាក្យ *អេឡិចត្រូនិក (Electronic)* ថ្នាក់ពាក្យជាគុណនាម ជាឧបករណ៍អេឡិចត្រូនិកដែលប្រើបន្ទះឈីប (chip) ដែលអាចឆ្លងចរន្តអគ្គិសនីបាន។ ស្រដៀងគ្នានេះផងដែរ វចនានុក្រមធុរកិច្ចជាភាសាអង់គ្លេស[3] ក៏បានពន្យល់ពីអត្ថន័យនៃពាក្យ *ពាណិជ្ជកម្ម* ថាជាការផ្លាស់ប្តូររវាងទំនិញ ឬសេវា ជាមួយនឹងប្រាក់ ឬវត្ថុផ្សេងៗដែលជាទូទៅធ្វើឡើងនៅលើចម្ងាយដ៏ឆ្ងាយល្មម ដែលចាំបាច់ត្រូវមានការដឹកជញ្ជូនពីកន្លែងមួយទៅកន្លែងមួយ ឬ ឆ្លងទីក្រុង រដ្ឋ ឬព្រំប្រទល់នៃជាតិណាមួយ ។ ពាក្យ *អេឡិចត្រូនិក* ត្រូវបានផ្តល់អត្ថន័យថាជា ឧបករណ៍ ឬប្រព័ន្ធតិចណូឡូជី ដែលបញ្ចូលគ្នារវាងរ៉ុលទាប និង បន្ទះរឹង ដែលមានបង្គុំនឹងសមាសភាគតូចៗច្រើន ដែលជាធម្មតាប្រើក្នុងការបញ្ជូន ឬដំណើរការនៃទិន្នន័យឌីជីថល។

លើសពីនេះ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានគេឱ្យនិយមន័យយ៉ាងទូលាយផ្សេងៗគ្នាជាច្រើនទៅតាមច្បាប់អន្តរជាតិ ដែលខាងក្រោមនេះ នឹងយកច្បាប់អន្តរជាតិសំខាន់ៗដែលទាក់ទងនឹង ការកំណត់និយមន័យនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មកសិក្សាបន្ថែម។

#### ១.១.១.១. អង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍ ១៩៩៧ (Organization for Economic Co-operation and Development “OECD”, 1997)

យោងតាមអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍ ១៩៩៧ (OECD, 1997) បានកំណត់និយមន័យនៃពាណិជ្ជកម្មអេឡិចត្រូនិកថាជា គ្រប់ទម្រង់នៃប្រតិបត្តិការពាណិជ្ជកម្មទាំងអស់ដែលជាប់ទាក់ទងទៅនឹងសកម្មភាពជំនួញ ដោយផ្អែកទៅលើដំណើរការ និងការបញ្ជូនទិន្នន័យឌីជីថល មានទាំងឯកសារសម្លេង និងរូបភាព ដែលរាប់បញ្ចូលទាំងនីតិបុគ្គល រូបវន្តបុគ្គល ។

#### ១.១.១.២. ក្របខណ្ឌអ៊ីអាស៊ាន (E-ASEAN)[4]

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលត្រូវបានប្រើប្រាស់នៅក្នុង ក្របខណ្ឌអ៊ីអាស៊ាន (E-ASEAN) គឺចង់សំដៅទៅលើប្រតិបត្តិការអេឡិចត្រូនិកនៅលើបណ្តាញអ៊ីនធើណេត ឬនៅលើ

[2] វចនានុក្រម Longman , បោះពុម្ពលើកទី៣ , ទំព័រ២៦៤ និង៨៤៥

[3] Business Dictionary 〈http://www.businessdictionary.com/definition.html〉 (ចូលទស្សនាចុងក្រោយ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧)

[4] E-ASEAN Reference Framework For Electronic Commerce Legal Infrastructure, 2001, page 2

បណ្តាញបើកទូលាយផ្សេងទៀត។ គួរកត់សម្គាល់ផងដែរថា ក្រុបខណ្ឌអ៊ីអាស៊ាន (E-ASEAN) នេះ បានបែងចែកប្រតិបត្តិការអេឡិចត្រូនិកខាងលើទៅជា២ប្រភេទ គឺប្រតិបត្តិការដែលពាក់ព័ន្ធទៅនឹងការលក់ទំនិញឬសេវារូបិយដែលជាប្រតិបត្តិការទី១ និងប្រតិបត្តិការដែលពាក់ព័ន្ធនឹងទៅនឹងការផ្ទេរដោយផ្ទាល់នៅលើបណ្តាញអ៊ីនធើណេតនូវព័ត៌មានព្រមទាំងទំនិញ និងសេវាដែលមានលក្ខណៈឌីជីថល ឧទាហរណ៍៖ សូហ្វវែរ បទភ្លេង វីដេអូ។

នៅក្នុងប្រភេទប្រតិបត្តិការទី១ បណ្តាញអ៊ីនធើណែត ឬបណ្តាញបើកទូលាយផ្សេងទៀតត្រូវបានប្រើប្រាស់ជាមធ្យោបាយសម្រាប់ដាក់បញ្ជាទិញ និងទទួលការដាក់បញ្ជាទិញទំនិញ ឬសេវា ព្រមទាំងការបង់ប្រាក់ទៀតផង ប៉ុន្តែការបញ្ជូនទំនិញ ឬសេវាទៅកាន់អតិថិជនត្រូវធ្វើឡើងជាធម្មតា ដូចពាណិជ្ជកម្មទូទៅដែលជាក់ស្តែងគឺបញ្ជូនតាមមធ្យោបាយដឹកទំនិញដូចជា រថយន្តជាដើម។

ចំណែកប្រភេទប្រតិបត្តិការទី២វិញ បណ្តាញអ៊ីនធើណេត ឬបណ្តាញបើកទូលាយផ្សេងទៀត ត្រូវបានប្រើប្រាស់ជាមធ្យោបាយទំនាក់ទំនង ក៏ដូចជាមធ្យោបាយដោះដូរព័ត៌មាន ទំនិញ និងសេវាក្នុងលក្ខណៈឌីជីថល ។

ដោយឡែក យោងតាមច្បាប់ដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់ប្រទេសជប៉ុន និយមន័យនៃវាក្យសព្ទ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនត្រូវបានឃើញកំណត់និយមន័យច្បាស់លាស់ទេ គ្រាន់តែចង្អុលបង្ហាញជាទូទៅថា គឺជាការប្រើប្រាស់ប្រព័ន្ធអ៊ីន-ធើណេត ឬកុំព្យូទ័រ ឬបណ្តាញប្រព័ន្ធផ្សេងៗ ក្នុងការទិញលក់ទំនិញនិងសេវាជាដើម ហើយក៏ជាសកម្មភាពសេដ្ឋកិច្ចដែលធ្វើការផ្ញើរ ឬបញ្ជូនប្រាក់ ឬទិន្នន័យ។[5]

ក្រោយពីបានសិក្សាស្វែងយល់ពីនិយមន័យដែលបានរៀបរាប់ខាងលើ គេសង្កេតឃើញមានចំណុច២ ដែលសម្គាល់ពីសញ្ញាណនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ទី១ គឺ សណ្ឋាននៃពាណិជ្ជកម្ម ត្រូវធ្វើឡើងជាលក្ខណៈឌីជីថល និង ទៅតាមប្រព័ន្ធអ៊ីនធើណេត។ ទី២ បរិយាកាស ឬសង្គមនៃពាណិជ្ជកម្មដែលឆ្លងកាត់ឌីជីថល និងប្រព័ន្ធអ៊ីនធើណេត គឺជាសណ្ឋាននៃពាណិជ្ជកម្មថ្មីមួយ ដែលបង្កើតនូវតម្លៃមន្ថែមទៅលើទីផ្សារសេដ្ឋកិច្ច និងសង្គម ដែលមកដល់ពេលនេះមិនធ្លាប់មានវត្តមានឡើយ។

### ១.១.២. ភាពខុសគ្នានៃរបបពាណិជ្ជកម្មទូទៅ និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ពាណិជ្ជកម្មទូទៅ ទាំងការព្រមព្រៀងគ្នានៅលើកិច្ចសន្យា និងការផ្ទេរសិទ្ធិកម្មសិទ្ធិ ការ

[5] Mastui Shigenori, Suzuki Hidemi, Yamaguchi Itsuko,「インターネット法 (Internet Law)」,有斐閣、2015、ទំព័រ១៦៨

ក្តោបក្តាប់នៃព័ត៌មានទំនិញ ការចរចា ការសម្រេចពីឆន្ទៈ ការបង្កើតកិច្ចសន្យា ការដឹកជញ្ជូន និងដំណើរទូទាត់ប្រាក់ ត្រូវបានគេសម្គាល់ថាជានីតិវិធីនៃការធ្វើជំនួញទៅតាមលំដាប់លំដោយ ពោលគឺត្រូវបានធ្វើឡើង ជាទម្រង់ដោយផ្ទាល់រវាងអ្នកទិញ និងអ្នកលក់ ដោយអ្នកលក់ និងអ្នកទិញធ្វើការចរចាពីតម្លៃ ពិនិត្យគុណភាពទំនិញជាក់ស្តែងមុននឹងជាវ ឬបង្ហាញពីឆន្ទៈផ្សេងៗដោយឃើញមុខគ្នា។ ចំណែកឯ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក៏មានលំដាប់លំដោយដូចបានរៀបរាប់ខាងលើដែរ តែត្រូវបានគេកំណត់សម្គាល់ថា គឺរាល់សកម្មភាពទាំងអស់ធ្វើឡើងដោយឆ្លងកាត់តាមប្រព័ន្ធអេឡិចត្រូនិក និងឌីជីថល ។

បន្ទាប់ពីបានយល់ដឹងពីនិយមន័យនៃពាក្យ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ខាងលើរួចមក ខាងក្រោមនេះយើងនឹងបង្ហាញថាតើរបបពាណិជ្ជកម្មទូទៅ និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានលក្ខណៈខុសគ្នាយ៉ាងដូចម្តេច ។

**១.១.២.១. លក្ខណៈទូទៅ**

ក. <u>តម្លៃ និងពេលវេលា</u> ៖ ជាការពិតណាស់ អ្នកប្រើប្រាស់ ឬអ្នកទិញ តែងតែប្រាថ្នាចង់បានតម្លៃថោក ដូចនេះ ការប្រៀបធៀបរវាងតម្លៃទំនិញទៅតាមហាងនីមួយៗនៅក្នុងទីផ្សារសេរីបែបនេះ ត្រូវគេដឹងថាជារឿងធម្មតា ប៉ុន្តែទាមទារត្រូវចំណាយពេលច្រើន ក្នុងការបន្លាស់ទីពីហាងទំនិញមួយទៅហាងទំនិញមួយទៀត។ ផ្ទុយទៅវិញ ការទិញទំនិញនៅតាមប្រព័ន្ធអេឡិចត្រូនិកមានការងាយស្រួលក្នុងការស្រាវជ្រាវនិងប្រៀបធៀប ពីតម្លៃទំនិញក្នុងហាងរាប់រយដែលតម្រៀបគ្នាជាច្រើន នៅលើគេហទំព័រទំនិញដោយគ្រាន់តែចុចជ្រើសរើសប្រភេទទំនិញបានយ៉ាងរហ័ស និងចំណាយពេលតិច។

ខ. <u>លទ្ធភាពនៃការទទួលព័ត៌មានទំនិញនិងជម្រើសរបស់អ្នកប្រើប្រាស់</u> ៖ នៅលើទីផ្សារទូទៅ វាពិតជាមិនងាយស្រួលក្នុងការទទួលបាននូវព័ត៌មាននៃទំនិញដែលគេដាក់លក់នៅក្នុងហាងទេ។ ប៉ុន្តែ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករាល់ព័ត៌មាននៃទំនិញទាំងអស់នឹងត្រូវបានរៀបរាប់ បង្ហាញយ៉ាងលម្អិតរួមមាន ទាំងសារធាតុផលិតផល ទំហំ ប្រទេសដែលផលិត តម្លៃជាដើម ស្របពេលដែលអាចឱ្យអ្នកប្រើប្រាស់ជ្រើសរើសនូវអ្វីដែលចាំបាច់។ នេះជាគម្លាតដ៏ធំអំពីលទ្ធភាពនៃការទទួលនៃព័ត៌មានទំនិញសម្រាប់អ្នកទិញរវាងពាណិជ្ជកម្មទូទៅ និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ លើសពីនេះទៅទៀត អ្នកទិញក៏អាចពិនិត្យមើលការវាយតម្លៃ ឬមតិយោបល់ទៅលើទំនិញទាំងនោះពីអ្នកទិញមុនៗ ដោយបន្ថែមទំនុកចិត្តលើទំនិញមួយកម្រិតថែមទៀតតាមប្រព័ន្ធអេឡិចត្រូនិក។

គ. ព័ត៌មានវិទ្យា (Information Technology)៖ប្រព័ន្ធព័ត៌មានវិទ្យា គឺដើរតួយ៉ាងសំខាន់ដោយជួយសម្រួល និងបញ្ជូនព័ត៌មានក្នុងលក្ខណៈជាសកលភាវូបនីយកម្ម និងសមាហរណកម្មជាពិសេស ការផ្ញើទំនិញដែលជាប្រភេទឌីជីថល ដោយមិនចាំបាច់ធ្វើការដឹកជញ្ជូនទេ គឺអាចផ្ញើបញ្ជូនតាមអ៊ីនធើណេតតែម្តង។ គួរកត់សម្គាល់ផងដែរថា អ្នកបង្កើតផលិតផលទាំងនោះក៏អាចឆ្លើយឆ្លងផ្ទាល់ ជាមួយអ្នកទិញ ដែលនេះជាការប្តូរវិធីធ្វើជំនួញ។

**១.១.២.២. លក្ខណៈច្បាប់**

ក. ការបង្កើតកិច្ចសន្យា

នៅក្នុងពាណិជ្ជកម្មទូទៅ កិច្ចសន្យាត្រូវបានធ្វើឡើងរវាងរូបវ័ន្តបុគ្គល និងរូបវ័ន្តបុគ្គល ដែលជាលក្ខណៈខុសគ្នាដ៏ធំមួយជាមួយនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ពីព្រោះនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក កិច្ចសន្យាធ្វើឡើងតាមរយៈមធ្យោបាយទំនាក់ទំនងអេឡិចត្រូនិក ពោលគឺ នីតិវិធីនៃការបង្កើតកិច្ចសន្យាត្រូវធ្វើឡើងតាមការចង្អុលបង្ហាញទៅតាមប្រព័ន្ធកុំព្យូទ័រដែលបានបង្ហាញនៅលើកញ្ចក់កុំព្យូទ័រ។

ជាគោលការណ៍ កិច្ចសន្យាត្រូវបានបង្កើតឡើង នៅពេលដែល សំណើ និងស្វីការត្រូវគ្នា។[6] កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលដំណឹងអំពីស្វីការ បានមកដល់អ្នកស្នើ (មាត្រា៣៤០ នៃក្រមរដ្ឋប្បវេណីខ្មែរ ឆ្នាំ២០០៧)។

ដោយយោងតាម សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មាត្រា១១ បានចែងថា "ការបង្កើតកិច្ចសន្យា សំណើ និងស្វីការអាចត្រូវបានធ្វើឡើងតាមមធ្យោបាយទំនាក់ទំនងអេឡិចត្រូនិក។" គួរបញ្ជាក់ផងដែរថា ការចុចចូលមើលរាល់ទំនិញដែលបានដាក់លើប្រព័ន្ធអ៊ីនធើណេត ដែលមិនសំដៅដល់បុគ្គលណាមួយជាក់លាក់ ត្រូវចាត់ទុកថាជាការអញ្ជើញឱ្យធ្វើសំណើបង្កើតកិច្ចសន្យា[7] ពោលគឺ ទោះបីជាអ្នកប្រើប្រាស់បានបង្ហាញឆន្ទៈ ថាចង់ទិញទំនិញមួយក៏ដោយ ក៏វាមិនមែនជាស្វីការដែរ។ ប្រការនេះដូចគ្នាផងដែរ ចំពោះការផ្ញើសារតាមប្រព័ន្ធអេឡិចត្រូនិកទៅកាន់អ្នកប្រើប្រាស់នៃចំនួនណាមួយ។ ប៉ុន្តែ សំណើបង្កើតកិច្ចសន្យាបានបង្ហាញឱ្យឃើញច្បាស់អំពីឆន្ទៈរបស់បុគ្គលដែលបានបង្កើតសំណើនោះ ថាខ្លួននឹងត្រូវជាប់កាតព្វកិច្ចលុះត្រាតែមានស្វីការ ហើយនៅពេលដែលមានស្វីការអញ្ជើញនោះត្រូវចាត់ទុកថាជាសំណើ គឺ មិនត្រូវចាត់ទុកថាជាការអញ្ជើញឱ្យធ្វើសំណើទេ។ កិច្ចសន្យាមានអានុភាពដោយមានការព្រមព្រៀងគ្នាទៅវិញទៅមករបស់ភាគីទាំងពីរតែប៉ុណ្ណោះ។

[6] ក្រមរដ្ឋប្បវេណីខ្មែរ ឆ្នាំ២០០៧ មាត្រា ៣៣៦

[7] សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ឆ្នាំ២០១៦, មាត្រា១៥

បន្ថែមពីនេះ គួររំលឹកដែរថា កិច្ចសន្យាដែលបង្កើតឡើង ដោយអន្តរកម្មរវាងប្រព័ន្ធសារស្វ័យប្រវត្តិជាអេឡិចត្រូនិក គឺត្រូវបានគេទទួលស្គាល់ពីសុពលភាពដូចកិច្ចសន្យាដែលធ្វើឡើងធម្មតាដែរ ពោលគឺ មិនត្រូវបានបដិសេធអំពីសុពលភាព ឬភាពដែលអាចតតាំងបានរបស់កិច្ចសន្យានោះ ដោយយកហេតុផលថាវាធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិក ព្រោះថាសំណើ និងស្ទីការបានត្រូវគ្នាទៅតាមឆន្ទៈរបស់ពាណិជ្ជករ និងអ្នកប្រើប្រាស់។[8]

ខ. <u>សមត្ថភាពរបស់ភាគី</u>

នៅក្នុងប្រតិបត្តិការទិញ លក់តាមប្រព័ន្ធអេឡិចត្រូនិក គេពិបាកក្នុងការកំណត់ពីសមត្ថភាពរបស់ភាគីម្ខាងទៀត (អ្នកទិញ) ណាស់ ពីព្រោះការប្រព្រឹត្តធ្វើឡើងដោយប្រយោល ពោលគឺមិនបានឃើញជួបមុខគ្នាដោយផ្ទាល់ឡើយ។

ជាគោលការណ៍ សកម្មភាពដែលអនីតិជនបានធ្វើ ដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលុបចោលបាន ទោះបីជាករណីអនុវត្តក្នុងប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិកក៏ដោយ។ អ្នកដែលអាចលុបចោលបាននូវសកម្មភាពនេះ គឺអនីតិជនសាមីខ្លួន ព្រមទាំងអ្នកមានសិទ្ធិអំណាចមេបា។[9]

ទន្ទឹមនឹងនេះផងដែរ មាត្រា៣៣ នៃក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ២០០៧ បានកំណត់ថា ៖

"ប្រសិនបើជនដែលត្រូវបានកម្រិតសមត្ថភាព បានប្រើប្រាស់មធ្យោបាយឆបោក ដើម្បីឱ្យគេជឿជាក់ថាខ្លួនជាសមត្ថជន ជននោះមិនអាចលុបចោលសកម្មភាពបានទេ។"

ក្នុងករណីដែលជនដែលត្រូវបានកម្រិតនូវសមត្ថភាព បានប្រើវិធីឆបោកធ្វើឱ្យភាគីម្ខាងទៀតយល់ច្រឡំថាជនដែលត្រូវបានកម្រិតនូវសមត្ថភាពនោះជាសមត្ថជន ហើយបានធ្វើកិច្ចសន្យាជួញដូរជាមួយអ្នកនោះ មិនបាច់ការពារជនដែលត្រូវបានកម្រិតនូវសមត្ថភាពនោះទេ ដូច្នេះក្នុងករណីនេះ មិនត្រូវទទួលស្គាល់ឱ្យលុបចោលបានទេ។

ដូចនេះ វាជាការចាំបាច់ដែលត្រូវបង្កើតប្រព័ន្ធមួយដើម្បីកំណត់ពីសមត្ថភាពរបស់ភាគីថាជាជនប្រភេទណា (អនីតិជន) ជៀសវាងមានបញ្ហាណាមួយកើតឡើង ពោលគឺត្រូវពិចារណាថាកិច្ចសន្យាដែលធ្វើឡើងដោយអនីតិជនតាមប្រព័ន្ធអេឡិចត្រូនិកអាចមានដល់កម្រិតណា លទ្ធភាពដែលអាចត្រូវលុបកិច្ចសន្យា ដែលធ្វើឡើងដោយអនីតិជន ពិចារណាពីប្រព័ន្ធកម្មវិធីដែលអាចបញ្ជាក់ និងបង្ហាញ ក្រោយពីជាអ្នកប្រើប្រាស់ដែលជាអនីតិជនទទួលបានការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនជាដើម។

[8] សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ឆ្នាំ២០១៦, មាត្រា១៦

[9] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី១ គន្ថីទី២, ទំព័រ១០ ភ្នំពេញ៖ក្រសួងយុត្តិធម៌ (២០១០)

គ. ការបង្ហាញឆន្ទៈ

ការស្ថាបនាគេហទំព័រ ចំណេះដឹងរបស់បុគ្គល ការរចនាពីដំណើរការនៅក្នុងអាស័យដ្ឋានអេឡិចត្រូនិកនីមួយៗអាចមានលក្ខណៈខុសគ្នាទៅតាមអ្នកបង្កើត។ ចំណុចទាំងនេះ អាចបណ្តាលឱ្យអ្នកប្រើប្រាស់បញ្ចូលព័ត៌មានខុស ឬច្រឡំក្នុងការចុចចំណុចណាមួយដោយយល់ខុស ដែលនាំឱ្យខុសពីឆន្ទៈពិតប្រាកដរបស់ខ្លួន។ ជាការពិបាកក្នុងការកំណត់ពីឆន្ទៈពិតប្រាកដ របស់បុគ្គលពីព្រោះ វាមិនត្រូវបានបង្ហាញចេញមកខាងក្រៅ ហើយបុគ្គលម្ខាងទៀតជាប្រព័ន្ធកុំព្យូទ័រ។

នៅក្នុងចំណុចនេះ មាត្រា ១៧ នៃសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់ប្រទេសកម្ពុជា ឆ្នាំ២០១៦ ក៏បានកំណត់ដូចខាងក្រោមដែរថា ៖

"នៅពេលដែលរូបវន្តបុគ្គលបញ្ចូលព័ត៌មានខុសនៅក្នុងទំនាក់ទំនងអេឡិចត្រូនិក មួយ ដែលបានដោះដូរជាមួយភាគីម្ខាងទៀតតាមរយៈប្រព័ន្ធសារស្វ័យប្រវត្តិ ហើយប្រព័ន្ធស្វ័យប្រវត្តិនោះមិនផ្តល់ឱកាសឱ្យរូបវន្តបុគ្គលនោះធ្វើការកែប្រែព័ត៌មានដែលខុស នោះរូបវន្តបុគ្គល ឬភាគីដែលជំនួសមុខឱ្យរូបវន្តបុគ្គលដែលធ្វើសកម្មភាពនោះ មានសិទ្ធិកែ តម្រូវ ឬដកចេញពីទំនាក់ទំនងអេឡិចត្រូនិកនូវព័ត៌មានដែលខុសនោះបាន ក្នុងករណីដែល៖

១. រូបវន្តបុគ្គលនោះ ជូនដំណឹងទៅភាគីម្ខាងទៀតអំពីកំហុសដែលបានកើតឡើង ឱ្យបានឆាប់បំផុតតាមលទ្ធភាពដែលអាចធ្វើទៅបាន ក្រោយពីបានដឹងអំពីកំហុសនោះ ហើយត្រូវបង្ហាញថាខ្លួនបានបញ្ចូលព័ត៌មាន ដែលខុសនៅក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះ ។

២. រូបវន្តបុគ្គលនោះមិនទទួលបានផលប្រយោជន៍ណាមួយ ដោយសារការបញ្ចូលព័ត៌មានខុសនេះ មុនពេលដែលខ្លួនធ្វើការជូនដំណឹងទៅឱ្យភាគីម្ខាងទៀត។"

## ១.២. សញ្ញាណនៃរបបពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា

ផ្នែកនេះ នឹងធ្វើការសិក្សាអំពី បច្ចុប្បន្នភាព និងភាពចាំបាច់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅប្រទេសកម្ពុជា (១.២.១) និង សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក (១.២.២)។

### ១.២.១. បច្ចុប្បន្នភាព និងភាពចាំបាច់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅប្រទេសកម្ពុជា

សក្តានុពលភាពនៃការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានសារៈសំខាន់ខ្លាំងណាស់នៅក្នុងប្រទេសកម្ពុជា ពីព្រោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកធានាបាននូវពិពិធកម្មសេដ្ឋកិច្ច ការបង្កើតការងារថ្មី និងការបង្កើនចំណូលបន្ថែម ក៏ដូចជាការចូលរួមចំណែកក្នុងការធ្វើឱ្យមានភាពប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។ ម្យ៉ាងទៀត បច្ចុប្បន្នប្រទេសកម្ពុជា

ស្ថិតនៅក្នុងដំណាក់កាលអភិវឌ្ឍមួយ ដែលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក កំពុងតែលេច ចេញជារូបរាងឡើង ស្របពេលដែលបច្ចេកវិទ្យា បាន និងកំពុងបញ្ជ្រាបខ្លួនចូលទៅក្នុងស្រទាប់ប្រជាជនទីក្រុងដែលមានជីវភាពមធ្យម អស់រយៈពេលប្រមាណជា ១០ ឆ្នាំ មកហើយ។[10]

ទោះជាយ៉ាងណាក៏ដោយ គេសង្កេតឃើញថា អ្នកប្រើប្រាស់ភាគច្រើន នៅតែគាំទ្រទីផ្សារដែលមានលក្ខណៈប្រពៃណី ពោលគឺទីផ្សារហិរញ្ញវត្ថុនៅតែត្រូវពឹងផ្អែកខ្លាំងលើក្រដាសប្រាក់។ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានភាពចាំបាច់ សម្រាប់តែទំនិញដែលគេមិនអាចរកបាននៅក្នុងនៅក្នុងហាងលក់ទំនិញធម្មតាទូទៅប៉ុណ្ណោះ។

ប៉ុន្តែ គួរកត់សម្គាល់ផងដែរថា សហគ្រាសធុនតូចនៅក្នុងប្រទេសកម្ពុជា នៅតែមានឱកាសក្នុងការទិញទំនិញពីបរទេស មកលក់តាមប្រព័ន្ធអនឡាញ ដូចជាតាមរយៈ ហ្វេសប៊ុក (Facebook) ឬ អ៊ីនស្តាក្រាម (Instagram) ដែលបម្រើដល់អតិថិជនប្រមាណជា ១៥, ០០០ នាក់។ បន្លាស់ប្តូរសេដ្ឋកិច្ចកម្ពុជាឱ្យមានលក្ខណៈទំនើប កំពុងត្រូវបានធ្វើឡើងយ៉ាងឆាប់រហ័ស ជាមួយនឹងភាពងាយស្រួល និងតម្លៃសមរម្យក្នុងការប្រើប្រាស់សេវាអ៊ីនធើណេត។ ក្រសួងប្រៃសណីយ៍ និងទូរ-គមនាគមន៍កម្ពុជា រំពឹងថាចំនួនប្រជាជនដែលប្រើប្រាស់អ៊ីនធើណេតនឹងកើនឡើងទ្វេដងរហូតដល់ចំនួន ៩.៥ លាន នាក់ ឬ ស្មើនឹង ៦០ ភាគរយ នៃចំនួនប្រជាជនសរុប នៅក្នុងឆ្នាំ២០២០។ នាពេលឆាប់ៗខាងមុខ ការពង្រឹងទំនាក់ទំនងតាមរយៈអ៊ីនធើណេត នឹងបង្កើតជាឱកាសថ្មីៗ សម្រាប់ទម្រង់នៃកិច្ចប្រតិបត្តិការជំនួញតាមប្រព័ន្ធអេឡិចត្រូនិក ក៏ដូចជាដើម្បីបម្រើដល់អតិថិជន និងសេដ្ឋកិច្ចទូទៅ ហើយឱកាសទាំងនេះចូលរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឱ្យមានភាពប្រសើរឡើងនៃស្ថានភាពហិរញ្ញវត្ថុ ការរីកចម្រើននៃសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយនិរន្តភាពរបស់ប្រទេសកម្ពុជា។

ទន្ទឹមនឹងសញ្ញាណជាវិជ្ជមាននៃសេវាអ៊ីនធើណេត ទំនើបកម្មនៃបច្ចេកវិទ្យា ការយល់ដឹង និងការរួមចំណែករបស់ប្រជាជន ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅប្រទេសកម្ពុជា ក៏នៅមានកម្រិតនៅឡើយ បើធៀបទៅនឹងបណ្តាប្រទេសអាស៊ានផ្សេងទៀត ហើយសក្តានុពលភាពនៃការនាំចេញទៀតសោតក៏មានភាពទន់ខ្សោយ។ ឧបសគ្គនៃការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូ-និក នៅប្រទេសកម្ពុជា ត្រូវបានគេមើលឃើញថា រួមមាន កង្វះខាតនៃប្រព័ន្ធអ៊ីនធើណេត (នៅតំបន់ជនបទ) មធ្យោបាយទូទាត់ប្រាក់ ប្រព័ន្ធដឹកជញ្ជូន ការកសាងទំនុកចិត្ត ប្រព័ន្ធច្បាប់ដែលមាន

[10] វង្វាយតម្លៃចំពោះភាពរួចរាល់សម្រាប់ការធ្វើជំនួញតាមប្រព័ន្ធអេឡិចត្រូនិកនៅប្រទេសកម្ពុជា, ២០១៧

ភាពមិនច្បាស់លាស់ ជាដើម ។ *(បញ្ហាប្រឈមដែលជាឧបសគ្គនៃការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធ អេឡិចត្រូនិក នឹងត្រូវបានបញ្ជាក់បន្ថែមនៅក្នុងជំពូកទី ៣)*

ស្ថិតនៅក្នុងបរិបទដែលប្រទេសជិតខាង នៅក្នុងតំបន់ មានការអភិវឌ្ឍខ្លាំង និងដោយមើលឃើញពីសក្តានុពលនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ព្រមទាំងបញ្ហារាំងស្ទះចំពោះការអភិវឌ្ឍពាណិជ្ជកម្មប្រភេទនេះ ដូច្នេះហើយ ទើបប្រទេសកម្ពុជា បានចាប់ផ្តើមតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកចាប់ពីឆ្នាំ២០០៤ មក ដើម្បីអាចគ្រប់គ្រងបានល្អប្រសើរនូវទំនាក់ទំនងពាណិជ្ជកម្ម ដែលមានលក្ខណៈទំនើបនេះ។ ដោយឡែក អស់រយៈកាលជាង ១០ ឆ្នាំ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក របស់ប្រទេសកម្ពុជាទើបតែត្រូវបានក្រសួងជំនាញ (ក្រសួងពាណិជ្ជកម្ម) បញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី ពិនិត្យ នៅដើមឆ្នាំ ២០១៧ នេះទេ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក្រសួងពាណិជ្ជកម្មមានសុទិដ្ឋិនិយម យ៉ាងមុតមាំថា សេចក្តីព្រាងច្បាប់នេះនឹងត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់ ដោយជោគជ័យនៅក្នុងរវាងឆ្នាំ ២០១៧ នេះតែម្តង។[11]

### ១.២.២. សេចក្តីព្រាងច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

#### ១.២.២.១. និយមន័យនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក របស់ក្រសួងពាណិជ្ជកម្ម មិនបានផ្តល់និយមន័យជាក់លាក់ណាមួយចំពោះ វាក្យសព្ទ **ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** នោះទេ។ ដោយឡែក បើយោងតាមអ្នកជំនាញពាក់ព័ន្ធ ដែលចូលរួមតាក់តែងសេចក្តីព្រាងច្បាប់នេះ *"ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក"* អាចត្រូវបានពន្យល់បាន ដោយប្រើវិធីបំបែកពាក្យ ដោយគេនឹងទទួលបាន ពាក្យ *"ពាណិជ្ជកម្ម"* និង *"ប្រព័ន្ធអេឡិចត្រូនិក"* ។ គេអាចឱ្យនិយមន័យពាក្យ *"ពាណិជ្ជកម្ម "* ដោយផ្អែកទៅតាមច្បាប់ជាធរមាននៃប្រទេសកម្ពុជា ដែលរួមមានច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ។ យ៉ាងណាមិញ ចំពោះពាក្យថា *"ប្រព័ន្ធអេឡិចត្រូនិក"* នឹងត្រូវបានបកស្រាយ ដោយផ្អែកលើនិយមន័យ ដែលមាននៅក្នុងឧបសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ទំព័រទី៣២។

[11] អ៊ឹម កុយ (អនុប្រធាននាយកដ្ឋាននីតិកម្មនៃក្រសួងពាណិជ្ជកម្ម), បទសម្ភាសន៍ដោយ យ៉េន វណ្ណីដា និង អ៊ឹង ហ៊ុយគង់, ៣១ ឧសភា ២០១៧

មាត្រា ២ ចំណុច "ឈ" នៃច្បាប់ស្តីពីមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម ឆ្នាំ២០០៦ បានផ្តល់និយមន័យចំពោះពាក្យ "ពាណិជ្ជកម្ម" ដោយបានចែងថា៖

> "ពាក្យថា "ពាណិជ្ជកម្ម" ត្រូវបានបកស្រាយឱ្យបានទូលំទូលាយ ដើម្បីគ្របដណ្តប់លើធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្ម ទោះបីជាមានកិច្ចសន្យា ឬ គ្មានកិច្ចសន្យាក៏ដោយ។ ធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្មមានជាអាទ៍ : កិច្ចការជំនួញដើម្បីផ្គត់ផ្គង់ ឬ ការផ្លាស់ប្តូរទំនិញ ឬ សេវាផ្សេងៗ កិច្ចព្រមព្រៀងនៃការចែកចាយតំណាង ឬ ទីភ្នាក់ងារពាណិជ្ជកម្ម ការទិញ-លក់គណនីក្រុមហ៊ុន ការជួលទីតាំង ឬ សម្ភារៈវត្ថុ ការងារស្ថាបនាការពិគ្រោះយោបល់វិស្វកម្ម ការចេញអាជ្ញាប័ណ្ណ ការវិនិយោគទុន ការផ្តល់ហិរញ្ញវត្ថុ ការធ្វើអាជីវកម្មធនាគារ ការធានារ៉ាប់រង កិច្ចព្រមព្រៀងធ្វើអាជីវកម្ម ឬ សម្បទាន ក្រុមហ៊ុនចំរុះ និងប្រភេទផ្សេងៗទៀតនៃសហប្រតិបត្តិការឧស្សាហកម្ម ឬ ពាណិជ្ជកម្ម និងការដឹកជញ្ជូនទំនិញ ឬអ្នកដំណើរតាមផ្លូវអាកាស ផ្លូវទឹក ផ្លូវគោក។"

យោងតាមច្បាប់ស្តីពីមជ្ឈត្តការផ្ទែកពាណិជ្ជកម្មខាងលើ គេអាចសន្និដ្ឋានដោយខ្លីបានថា ពាណិជ្ជកម្ម សំដៅទៅដល់សកម្មភាពរបស់បុគ្គល ឬ សហគ្រាស ក្នុងការផ្គត់ផ្គង់ ឬ ផ្លាស់ប្តូរទំនិញ ឬ សេវាផ្សេងៗ ការទិញ លក់ ឬជួល ការពិគ្រោះយោបល់ ការផ្តល់ហិរញ្ញវត្ថុ ការធានារ៉ាប់រង ការព្រមព្រៀងធ្វើអាជីវកម្មផ្សេងៗដូចជា ការដឹកជញ្ជូននានា។

យ៉ាងណាមិញ យោងតាមសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់ក្រសួងពាណិជ្ជកម្ម ពាក្យ *"ប្រព័ន្ធអេឡិចត្រូនិក" (Electronic system)* ត្រូវបានពន្យល់ នៅក្នុងឧបសម្ព័ន្ធ ទំព័រទី ៣២ ថា៖

> "សំដៅដល់ឧបករណ៍អេឡិចត្រូនិក ឬបណ្តុំឧបករណ៍តភ្ជាប់គ្នា ឬទាក់ទងគ្នា តាមរយៈកម្មវិធីអេឡិចត្រូនិក អាចធ្វើឱ្យមានដំណើរការស្វ័យប្រវត្តិនៃទិន្នន័យ និងរួមបញ្ចូលទាំងឧបករណ៍រក្សាទុកបែបអេឡិចត្រូនិក ។"

ពាក្យគន្លឹះមួយទៀត ដែលចូលរួមចំណែកក្នុងការពន្យល់ពីអត្ថន័យរបស់ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ហើយត្រូវបានពន្យល់នៅក្នុងឧបសម្ព័ន្ធ ទំព័រទី ៣២ នៃសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ផងដែរនោះ គឺពាក្យ "*ទម្រង់អេឡិចត្រូនិក*" ដែលត្រូវបានបកស្រាយថា៖

> "ទាក់ទងនឹងព័ត៌មាន សំដៅដល់ព័ត៌មានដែលបង្កើត ដែលបានបញ្ជូន ដែលទទួលបាន ឬដែលរក្សាទុកក្នុងប្រព័ន្ធផ្សព្វផ្សាយ ក្នុងទម្រង់ម៉ាញ៉េទិច ក្នុងទម្រង់អុបទិច ក្នុងអង្គចងចាំរបស់កុំព្យូទ័រ ក្នុងមីក្រូហ្វីល ក្នុងកុំព្យូទ័រ ឬក្នុងឧបករណ៍ដែលមានមុខងារស្រដៀងគ្នា។"

ក្រោយពីបានសិក្សាទៅលើអត្ថន័យ ខ្លឹមសារ ការពន្យល់ នៃពាក្យគន្លឹះពាក់ព័ន្ធរួចមក ពាក្យប្រព័ន្ធអេឡិចត្រូនិក អាចត្រូវពន្យល់ក្នុងន័យសាមញ្ញថា ជាប្រព័ន្ធមួយដែលរួមផ្គុំដោយឧបករណ៍អេឡិចត្រូនិកតភ្ជាប់គ្នា ទាក់ទងគ្នាតាមកម្មវិធីអេឡិចត្រូនិក ក្នុងទម្រង់ម៉ាញ៉េទិច អុបទិច ក្នុងអង្គចងចាំរបស់កុំព្យូទ័រ មីក្រូហ្វីល ជាដើម ដើម្បីបង្កើតឱ្យមានដំណើរស្វ័យប្រវត្តិ និងការរក្សាទុកនៃទិន្នន័យ។

បន្ទាប់ពីបានធ្វើការបកស្រាយដាច់ដោយឡែក នូវខ្លឹមសារនៃបំណែកផ្សេងគ្នារបស់ពាក្យគន្លឹះរួចហើយ ពាក្យ*ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក* អាចត្រូវគេយល់បានថា ជាការផ្គត់ផ្គង់ ឬ ផ្លាស់ប្តូរទំនិញ ឬ សេវាផ្សេងៗ ការទិញ លក់ ជួល ការពិគ្រោះយោបល់ ការផ្តល់ហិរញ្ញវត្ថុ ការធានារ៉ាប់រង ការព្រមព្រៀងធ្វើអាជីវកម្មផ្សេងៗ ដែលត្រូវបានធ្វើឡើង តាមរយៈប្រព័ន្ធមួយដែលរួមផ្គុំដោយឧបករណ៍អេឡិចត្រូនិកតភ្ជាប់គ្នា ហើយទាក់ទងគ្នាតាមកម្មវិធីអេឡិចត្រូនិក ក្នុងទម្រង់ម៉ាញ៉េទិច អុបទិច អង្គចងចាំរបស់កុំព្យូទ័រ ជាដើម ដើម្បីបង្កើតឱ្យមានដំណើរការស្វ័យប្រវត្តិ និងការរក្សាទុកនៃទិន្នន័យ។

ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬ E-Commerce សំដៅលើសកម្មភាពទិញលក់ទំនិញ និងទូទាត់សេវាកម្មតាមរយៈប្រព័ន្ធអ៊ីនធើណេត ដែលអាចនាំមកនូវកាលានុវត្តភាពអាជីវកម្មថ្មីៗយ៉ាងច្រើនសម្រាប់សហគ្រិនវ័យក្មេង នៅក្នុងប្រទេសកម្ពុជា ក្នុងការចូលរួមពង្រីកកំណើនសេដ្ឋកិច្ចជាតិ។[12]

សរុបសេចក្តីមក ពាក្យថាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលជាពាក្យគន្លឹះដ៏សំខាន់មួយ នៃការសិក្សានេះ ហើយអាចជាពាក្យគន្លឹះថ្មីមួយនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន អាចត្រូវបានគេឱ្យនិយមន័យដោយផ្អែកលើច្បាប់ពាក់ព័ន្ធ (ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម) និងសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកផ្ទាល់។ ម្យ៉ាងទៀត គួរកត់សម្គាល់ថា ពាក្យថា "ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក" នេះទៀតសោតអាចត្រូវបានគេយល់ក្នុងន័យសាមញ្ញបំផុតថាវាក៏ដូចជា សកម្មភាពពាណិជ្ជកម្មទូទៅដែរ ដោយគ្រាន់តែវាមានបន្ថែមលក្ខណៈពិសេសមួយគឺ ការភ្ជាប់ទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិក មានន័យថាសកម្មភាពពាណិជ្ជកម្មប្រភេទនេះ បានប្រើប្រាស់នូវមធ្យោបាយទំនាក់ទំនងដែលជាប្រព័ន្ធអេឡិចត្រូនិក។

[12] សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងពាណិជ្ជកម្មថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៦

**១.២.២.២. បច្ចុប្បន្នភាពនៃសេចក្តីព្រាងច្បាប់ ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៅប្រទេសកម្ពុជា និងខ្លឹមសារសំខាន់ៗ**

អស់រយៈកាលជាងមួយទសវត្ស មកហើយ ដែលប្រទេសកម្ពុជា បាន និងកំពុងធ្វើសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីជួយសម្រួល ក៏ដូចជាគ្រប់គ្រងការធ្វើជំនួញតាមប្រព័ន្ធអនឡាញរវាងវិនិយោគិន ជាមួយនឹងអតិថិជន។ [13] សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកចុងក្រោយ ដែលរៀបចំឡើងដោយក្រសួងពាណិជ្ជកម្មចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ហើយដែលត្រូវបានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីសម្រាប់ធ្វើការពិនិត្យនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ មានចំនួន ១១ ជំពូក ចែកចេញជា ៥៨ មាត្រា និងកំពុងស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ទីស្តីការគណៈរដ្ឋមន្ត្រី មុននឹងបញ្ជូនទៅរដ្ឋសភា ដើម្បីធ្វើការអនុម័ត។

នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៦ នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឯកឧត្តម ប៉ាន សូរស័ក្តិ នៅក្នុងឱកាសនៃពិធីបើកដាក់ឱ្យដំណើរការកម្មវិធី ជំនួញនៅក្នុងលំហ (Cloud Business) ដែលជាគម្រោងមួយនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រ (PUC ITC 2016) បានលើកឡើងថាសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនមែនសម្រាប់តែបរិបទនៅក្នុងប្រទេសកម្ពុជានោះទេ ប៉ុន្តែគឺសម្រាប់ពិភពលោកទាំងមូល ពីព្រោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ មិនមានព្រំដែននោះឡើយ។ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បង្កើតបែបបទជំនួញថ្មីមួយ នៅក្នុងលំហ (អ៊ីនធើណេត) និងអនុញ្ញាតឱ្យយុវជនធ្វើជំនួញ ដោយមិនមានព្រំដែនកំណត់ គ្រប់ពេលវេលា នៅជុំវិញពិភពលោក ដើម្បីនាំយកចំណូលឱ្យក្រុមហ៊ុននានានៅប្រទេសកម្ពុជា។[14]

ប្រធាននាយកដ្ឋាននៃនាយកដ្ឋាននីតិកម្ម របស់ក្រសួងពាណិជ្ជកម្ម អ្នកស្រី គីម សារឿង បានលើកឡើងថាច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានតាក់តែងឡើងក្នុងគោលបំណងដើម្បីការពារ ទាំងវិនិយោគិន និងអ្នកប្រើប្រាស់ ដោយអ្នកស្រីបានបញ្ជាក់ថា សេចក្តីព្រាងច្បាប់នេះ នឹងគ្របដណ្តប់ ការទូទាត់/ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក (E-Payment)[15]។ គួរកត់សម្គាល់ផងដែរថា ការទូទាត់ និងផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកនេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារជាតិ នៃប្រទេសកម្ពុជា។ ម្យ៉ាងទៀត សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធ

---

[13] សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងពាណិជ្ជកម្មថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៦

[14] សុន្ទរកថារបស់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៦ នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រ

[15] ជំពូកទី៩ ការទូទាត់/ផ្ទេរប្រាក់ជាអេឡិចត្រូនិក នៃសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦

អេឡិចត្រូនិកនេះ ក៏មានបញ្ញត្តិពីបទល្មើសប្រឆាំងនឹងប្រព័ន្ធព័ត៌មាន និងទិន្នន័យកុំព្យូទ័រ[16] ព្រមទាំងទោសពិន័យចំពោះបទល្មើសទាំងនោះផងដែរ។[17]

ខាងក្រោមនេះ ជាការបង្ហាញយ៉ាងសង្ខេបពី បទបញ្ញត្តិនៃសេចក្តីព្រាងចុងក្រោយនៃ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ៖

ជំពូកទី ១ បទប្បញ្ញត្តិទូទៅ ដែលមានចំនួន ៣ មាត្រា បញ្ញត្តិពីគោលបំណង គោលដៅ និងវិសាលភាព នៃសេចក្តីព្រាងច្បាប់ ដែលមានសារៈសំខាន់ក្នុងការកំណត់ទំនាក់ទំនងទាំងឡាយដែលមិនស្ថិតនៅក្រោមវិសាលភាពនៃសេចក្តីព្រាងច្បាប់នេះ ដូចដែលមានបញ្ជាក់នៅក្នុងជំពូកទី ២ នៃការសិក្សានេះ។

ជំពូកទី២ សុពលភាពនៃទំនាក់ទំនងអេឡិចត្រូនិក ដែលមានចំនួន ១០ មាត្រា បញ្ញត្តិពីការផ្តល់សុពលភាពចំពោះទំនាក់ទំនងអេឡិចត្រូនិកទាំងឡាយ រួមមានទាំងលក្ខខណ្ឌទាំង ៤ និងអានុភាពរវាងគូភាគីនៃទំនាក់ទំនងអេឡិចត្រូនិក។

ជំពូកទី ៣ ដំណើរការទំនាក់ទំនង ដែលមានចំនួន ៤ មាត្រា បញ្ញត្តិលម្អិតពីដំណើរប្រព្រឹត្តទៅនៃទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិក ដោយរួមបញ្ចូលទាំង ពេលវេលា និងទីកន្លែងនៃការបញ្ជូនចេញ និងទទួលបាននូវព័ត៌មានអេឡិចត្រូនិក ដែលជាដំណាក់កាលបង្កើតឱ្យមានជាកិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិក។

ជំពូកទី ៤ កំណត់ត្រាអេឡិចត្រូនិក និងហត្ថលេខា អេឡិចត្រូនិកដែលមានសុវត្ថិភាព មានចំនួន ៤ មាត្រា ។ ជំពូកនេះ ហាក់មានគោលបំណងក្នុងការបញ្ជាក់បន្ថែមពីលើជំពូកទី ២ ដោយបញ្ញត្តិពីកំណត់ត្រា និងហត្ថលេខាអេឡិចត្រូនិក ដែលអាចចាត់ទុកបានថាមានសុវត្ថិភាព។

ជំពូកទី ៥ អន្តរការី និងអ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានចំនួន ៣ មាត្រា បានបញ្ញត្តិពីការការពារចំពោះអន្តរការី ក៏ដូចជាអ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិច-ត្រូនិក ព្រមទាំងកំណត់ពីវិធានការដែលអន្តរការី និងអ្នកផ្តល់សេវាត្រូវចូលនៅក្នុងករណីដែលព័ត៌មានដែលមានលក្ខណៈខុសច្បាប់ និងមិនសមស្រប។

ជំពូកទី ៦ កិច្ចការពារអ្នកប្រើប្រាស់ ដែលមានចំនួន ៤ មាត្រា បញ្ញត្តិពីការពារមួយចំនួនចំពោះអ្នកប្រើប្រាស់ ដូចជា ការពារទិន្នន័យ និងទំនាក់ទំនងដែលមិនបានស្នើសុំ ជាដើម។ ប៉ុន្តែ

[16] ជំពូកទី១០ បទល្មើសប្រឆាំង នឹងប្រព័ន្ធព័ត៌មាន និងទិន្នន័យកុំព្យូទ័រ នៃសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦

[17] សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងពាណិជ្ជកម្មថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៦

បញ្ញត្តិនៅក្នុងជំពូកទី ៦នេះមិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការពារអ្នកប្រើប្រាស់នោះទេ ពោលគឺការពារដែលមានលក្ខណៈលម្អិតគឺមានបញ្ញត្តិនៅក្នុងច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់។[18]

ជំពូកទី ៧ នីតិវិធី និងស៊ើបអង្កេត ដែលមានចំនួន ១ មាត្រា បញ្ញត្តិពីលទ្ធភាពដែលស្ថាប័នរបស់រាជរដ្ឋាភិបាល អាចប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក សម្រាប់សកម្មភាពជាក់លាក់មួយចំនួន។

ជំពូកទី ៨ ភស្តុតាងអេឡិចត្រូនិក ដែលមានចំនួន ៩ មាត្រា បានបញ្ញត្តិលម្អិតបន្ថែមពីលើជំពូកទី ២ ដែលផ្តល់សុពលភាព ដល់លក្ខខណ្ឌសំខាន់ៗទាំងបួននោះ ដោយកំណត់ពីការទទួលយកជាទូទៅនៃភស្តុតាងអេឡិចត្រូនិក និងសុក្រឹតភាពរបស់ព័ត៌មាន និងពង្រីកវិសាលភាពនៃភស្តុតាងអេឡិចត្រូនិកនេះ ដោយទទួលស្គាល់ព័ត៌មានពីបណ្តាប្រទេសផ្សេងៗ។

ជំពូកទី ៩ ការទូទាត់/ផ្ទេរប្រាក់ជាអេឡិចត្រូនិក ដែលមានចំនួន ៤ មាត្រា ចែងអំពីប្រតិបត្តិការទូទាត់ និងផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ដោយអ្នកដែលបំណងបម្រើសេវា ចាំបាច់ត្រូវស្នើសុំការអនុញ្ញាតពីធនាគារជាតិ ហើយទាំងអ្នកផ្តល់សេវាទូទាត់ និងអតិថិជន សុទ្ធសឹងតែមានការទទួលខុសត្រូវផ្សេងៗគ្នា។

ជំពូកទី ១០ បទល្មើសប្រឆាំង នឹងប្រព័ន្ធព័ត៌មាន និងទិន្នន័យកុំព្យូទ័រ ដែលមានចំនួន ១៣ មាត្រា បានកំណត់ពីនិយមន័យនៃបទល្មើសផ្សេងៗនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ ក៏ដូចជាការផាកពិន័យសម្រាប់បទល្មើសទាំងនោះ។ ទោះជាយ៉ាងណាក៏ដោយ ទោសពិន័យនៃបទល្មើសដែលត្រូវបានចែងទាំងនោះ មិនត្រូវបានកំណត់នៅឡើយទេ ដោយក្រសួងរង់ចាំពិភាក្សាជាមួយក្រសួងយុត្តិធម៌ ដែលជាក្រសួងជំនាញ។[19]

ជំពូកទី ១១ អវសានប្បញ្ញត្តិ ដែលមានចំនួន ៣ មាត្រា ដែលបញ្ញត្តិពីការដាក់ឱ្យអនុវត្តច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក តាមរយៈការបង្កើតឱ្យមានគណៈកម្មការអន្តរក្រសួងដែលមានសមាសភាពនៃគណៈកម្មការនេះត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងទេសាភិបាលធនាគារជាតិនៃកម្ពុជាដើម្បីអនុវត្តជំពូកនេះ។ ជំពូកនេះ ក៏បានបញ្ញត្តិពីការនិរាករណ៍នៃបញ្ញត្តិ ដែលផ្ទុយនឹងបញ្ញត្តិនៃច្បាប់នេះ ប៉ុន្តែមិនបានចង្អុលបង្ហាញឱ្យជាក់លាក់ថាបញ្ញត្តិណាមួយនឹងត្រូវនិរាករណ៍នោះទេ ដែលកត្តានេះអាចបង្កជាផលលំបាកក្នុងការអនុវត្តផងដែរ។

[18] អ៊ឹម កុយ (អនុប្រធាននាយកដ្ឋាននីតិកម្មនៃក្រសួងពាណិជ្ជកម្ម), បទសម្ភាសន៍ដោយ យ៉េន វណ្ណីដា និង អ៊ឹង ហ៊ុយគង់, ៣១ ឧសភា ២០១៧

[19] អ៊ឹម កុយ (អនុប្រធាននាយកដ្ឋាននីតិកម្មនៃក្រសួងពាណិជ្ជកម្ម), បទសម្ភាសន៍ដោយ យ៉េន វណ្ណីដា និង អ៊ឹង ហ៊ុយគង់, ៣១ ឧសភា ២០១៧

គួរកត់សម្គាល់ផងដែរថា សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុងក្រោយនេះ ជាសេចក្តីព្រាងដែលមានចំនួនជំពូក និងមាត្រា តិចជាងសេចក្តីព្រាងច្បាប់មុនៗទាំងអស់របស់ក្រសួងពាណិជ្ជកម្ម ដែលបើតាមអ្នកជំនាញរបស់ក្រសួងពាណិជ្ជកម្ម ដែលចូលរួមតាក់តែងសេចក្តីព្រាងច្បាប់នេះ បញ្ជាក់ថាការណ៍នេះ ដោយសារក្រុមអ្នកជំនាញដែលតាក់តែងសេចក្តីព្រាងច្បាប់ ព្យាយាមប្រើពាក្យពេចន៍សាមញ្ញ ងាយស្រួលយល់ ពីសេចក្តីព្រាងមួយ ទៅសេចក្តីព្រាងមួយ។[20]

[20] អ៊ឹម កុយ (អនុប្រធាននាយកដ្ឋាននីតិកម្មនៃក្រសួងពាណិជ្ជកម្ម), បទសម្ភាសន៍ដោយ យ៉េន វណ្ណីដា និង អ៊ឹង ហ៊ុយគង់, ៣១ ឧសភា ២០១៧

# ជំពូកទី២

# របបគតិយុត្ត នៃការបង្កើតកិច្ចសន្យាពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក

ការទិញ លក់ទំនិញ និងសេវាតាមតាមប្រព័ន្ធអេឡិចត្រូនិក ក៏ចាំបាច់ទាមទារឱ្យមានកិច្ចសន្យាជាក់លាក់ផងដែរ ដើម្បីធ្វើការអះអាងទុកជាភស្តុតាង បញ្ជាក់នៅពេលដែលមានវិវាទកើតឡើង ហើយកិច្ចសន្យាដែលធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិក ក៏មិនត្រូវអាចជំទាស់ការទទួលស្គាល់ទំនាក់ទំនង និងបដិសេធពីសុពលភាពឡើយ ពោលគឺមានអានុភាព និងសុពលភាពដូចកិច្ចសន្យាធម្មតាដែរ។ ប៉ុន្តែ កិច្ចសន្យាដែលធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានគ្រប់គ្រង ដោយរបបគតិយុត្តថ្មីមួយដែលហៅថា ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ គួរបញ្ជាក់ផងដែរថា នៅប្រទេសកម្ពុជាច្បាប់នេះគឺស្ថិតនៅដំណាក់កាលសេចក្តីព្រាងនៅឡើយទេ។ ការបង្កើតកិច្ច-សន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (២.១) ដែលទីនេះនឹងសិក្សាពីលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិក តាមសេចក្តីព្រាងខាងលើនេះ និងកិច្ចប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (២.២ )ដែលកំពុងអនុវត្តជាក់ស្តែងនៅប្រទេសកម្ពុជា។

## ២.១. ការបង្កើតកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

លក្ខខណ្ឌសុពលភាពគតិយុត្តនៃទំនាក់ទំនងអេឡិចត្រូនិក (២.១.១) និង ការបង្កើត និងអានុភាពគតិយុត្ត នៃកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (២.១.២) នឹងត្រូវបានលើកយកមកសិក្សាលម្អិតនៅក្នុងផ្នែកនេះ។

### ២.១.១. លក្ខខណ្ឌសុពលភាពគតិយុត្តនៃទំនាក់ទំនងអេឡិចត្រូនិក

កថាខណ្ឌនេះ នឹងធ្វើការសិក្សាទៅលើលក្ខខណ្ឌសំខាន់ៗចំនួន ៤ ដែលធ្វើឱ្យកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានសុពលភាព ដែលក្នុងនោះរួមមាន (ក) ទម្រង់លាយលក្ខណ៍អក្សរ (ខ) ហត្ថលេខា (គ) ទម្រង់ដើម (ឃ) ភស្តុតាង។

គួរកត់សម្គាល់ផងដែរថា លក្ខខណ្ឌសុពលភាពនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សំដៅទៅលើលក្ខខណ្ឌទាំងឡាយ ដែលភាគីបានបំពេញស្របតាមបទប្បញ្ញត្តិ នៃសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកហើយ ប្រតិបត្តិការ ឬ ទំនាក់ទំនងនោះ នឹងត្រូវបានចាត់ទុកថាមានសុពលភាព ស្របតាមសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ពោលគឺសេចក្តីព្រាងច្បាប់នេះទទួលស្គាល់នូវសុពលភាពគតិយុត្ត នៃប្រតិបត្តិការ ឬ ទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិក ដោយមិនមានភាគីណាមួយ អាចបដិសេធមិនទទួលស្គាល់សុពលភាព

គតិយុត្ត ឬ ភាពតតាំងជាមួយតតិយជនបាន ដោយគ្រាន់តែអះអាងថាទំនាក់ទំនងនោះត្រូវបានធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិកនោះឡើយ។[21]

ទោះជាយ៉ាងណាក៏ដោយ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក៏បានកំណត់ពីវិសាលភាពនៃការអនុវត្ត ចំពោះទំនាក់ទំនងជាក់លាក់មួយចំនួនផងដែរថា សេចក្តីព្រាងច្បាប់នេះ មិនទទួលស្គាល់នូវសុពលភាពគតិយុត្តរបស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះទេ ចំពោះសកម្មភាព ឯកសារ និងប្រតិបត្តិការដែលទាក់ទងនឹង៖

- ការបង្កើត ឬការអនុវត្តលិខិតប្រគល់សិទ្ធិ។

- ការបង្កើត ឬការចុះហត្ថលេខាលើមតកសាសន៍ លិខិតកែមតកសាសន៍ ឬ បញ្ហាផ្សេងៗទៀតទាក់ទិននឹងការស្នងមរតក។

- រាល់កិច្ចសន្យាសម្រាប់ការលក់ ការផ្ទេរ ឬការបោះបង់សិទ្ធិលើអចលនទ្រព្យ ឬផលប្រយោជន៍ផ្សេងៗទៀតក្នុងទ្រព្យនោះ។

- ការផ្ទេរអចលនវត្ថុ ឬផលប្រយោជន៍ណាមួយដែលពាក់ព័ន្ធនឹងអចលនវត្ថុនោះ។

- ឧបករណ៍អាចជួញដូរបាន។

- ករណីលើកលែងផ្សេងទៀតដែលត្រូវកំណត់ដោយអនុក្រឹត្យ។[22]

### ២.១.១.១. ទម្រង់លាយលក្ខណ៍អក្សរ

កិច្ចសន្យា ឬ ការប្រាស្រ័យទាក់ទង (សេចក្តីថ្លែងការ សេចក្តីប្រកាស ការទាមទារ ការជូនដំណឹង ស្ទីការ ដែលធ្វើឡើងពាក់ព័ន្ធនឹងការបង្កើត ឬ ការបំពេញកាតព្វកិច្ចនៃកិច្ចសន្យា) ដែលតម្រូវឱ្យធ្វើឡើងជាលាយលក្ខណ៍អក្សរ នឹងមិនអាចត្រូវបានបដិសេធអំពីសុពលភាព ដោយគ្រាន់តែសំអាងលើហេតុផលថាវាត្រូវបានធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិកនោះឡើយ។ ទម្រង់អេឡិច-ត្រូនិក រក្សានូវសុចរិតភាព និងភាពដែលអាចទុកចិត្តបាន ហើយអាចត្រូវបញ្ជាក់ដើម្បីប្រើប្រាស់ជាសំអាងនៅពេលក្រោយបាន។ ការកត់ត្រាទុកក្នុងទម្រង់អេឡិចត្រូនិកដែលអាចទុកចិត្តបាន ត្រូវបំពេញនូវលក្ខខណ្ឌច្បាប់ជាក់លាក់ ដែលតម្រូវឱ្យព័ត៌មានស្ថិតនៅក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ឬ សម្រាប់ធ្វើការបង្ហាញជាលាយលក្ខណ៍អក្សរ។[23]

---

[21] សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ២០១៦, មាត្រា ៨ "ការទទួលស្គាល់លក្ខណៈគតិយុត្តនៃទំនាក់ទំនងអេឡិចត្រូនិក"

[22] ដូច ២០, មាត្រា ៣ "វិសាលភាព"

[23] សារណាបញ្ចប់ថ្នាក់អនុបណ្ឌិត អំពី បទដ្ឋានច្បាប់សម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅអាស៊ាន៖ច្បាប់គំរូ ឆ្នាំ២០០៦/E-COMMERCE LEGAL FRAMEWORK FOR ASEAN: a MODEL CODE, National University of Singapore, 2006

មាត្រា ៦ នៃ ច្បាប់គំរូស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ១៩៩៨ (UNCITRAL Model Law on Electronic Commerce, 1998) បានចែងពាក់ព័ន្ធនឹងលក្ខខណ្ឌលាយលក្ខណ៍អក្សរថា៖

"១. នៅពេលដែលច្បាប់តម្រូវឱ្យការផ្តល់ព័ត៌មាន ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ លក្ខខណ្ឌនោះនឹងត្រូវបំពេញប្រសិនបើព័ត៌មាននោះ អាចចូលទៅប្រើប្រាស់ជាសំអាងបាននៅពេលក្រោយ។

២. កថាខណ្ឌទី១ ខាងលើនេះត្រូវយកអនុវត្តក្នុងករណីដែលលក្ខខណ្ឌនេះគឺជាកាតព្វកិច្ច ឬក្នុងករណីដែលច្បាប់មានបញ្ញត្តិពីលទ្ធផលនៃអវត្តមានលក្ខខណ្ឌទម្រង់ ដែលមិនមែនជាលាយលក្ខណ៍អក្សរ ។

៣. បទបញ្ញត្តិនេះ មិនត្រូវបានអនុវត្តក្នុងករណីដូចតទៅ។ [...]"[24]

យោងទៅតាម សេចក្តីណែនាំឱ្យអនុម័ត ច្បាប់គំរូស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មាត្រា ៦ នៃច្បាប់ខាងលើនេះ មានគោលបំណងក្នុងការកំណត់ពីមូលដ្ឋានគ្រឹះនៃទិន្នន័យដើម្បីក្លាយជាព័ត៌មានមួយ ដែលមានទម្រង់ជាលាយលក្ខណ៍អក្សរ ឬ ជាព័ត៌មានដែលមានផ្ទុកនៅក្នុងឯកសារជាក្រដាស សមស្របទៅតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងយុត្តិសាស្ត្រ។

នៅក្នុងការរៀបចំតាក់តែងច្បាប់គំរូនេះ តួនាទីជាប្រពៃណីនៃលក្ខខណ្ឌលាយលក្ខណ៍អក្សរនៅលើក្រដាស ត្រូវបានទទួលការយកចិត្តទុកដាក់ខ្ពស់។ ជាក់ស្តែង តួនាទីដ៏ច្រើនដែលមិនអាចរៀបរាប់ឱ្យអស់បាន ហើយត្រូវបានលើកឡើងខ្លះៗខាងក្រោមនេះ បញ្ជាក់ពីហេតុផលដែល ច្បាប់ជាតិនីមួយៗតម្រូវឱ្យមានការធ្វើជាលាយលក្ខណ៍អក្សរ ដែលក្នុងនោះរួមមាន ភស្តុតាងរូបីដើម្បីបង្ហាញពីអត្ថិភាព និងភាពពិតនៃចេតនារបស់ភាគីក្នុងការចងកាតព្វកិច្ចខ្លួនឯង រំលឹកភាគីពីលទ្ធផលនៃការបង្កើតកិច្ចសន្យា ផ្តល់ឯកសារមួយដែលមិនអាចកែប្រែបាន និងកត់ត្រាជាអចិន្ត្រៃយ៍នូវប្រតិបត្តិការនានា ឯកសារមួយដែលអាចទទួលយកបានដោយអាជ្ញាធរសាធារណៈ និងតុលាការ ។ល។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងដំណើរការរៀបចំច្បាប់គំរូនេះដែរ គេរកឃើញថា មិនមែនជាការត្រឹមត្រូវនោះទេ ក្នុងការផ្តល់មុខងារធំទូលាយពេកដល់លក្ខខណ្ឌលាយលក្ខណ៍អក្សរ។

---

[24] UNCITRAL Model Law on Electronic Commerce, 1998, Article 6. Writing

(1) Where the law requires information to be in writing, that requirement is met by a data message if the information contained therein is accessible so as to be usable for subsequent reference.

(2) Paragraph (1) applies whether the requirement therein is in the form of an obligation or whether the law simply provides consequences for the information not being in writing.

(3) The provisions of this article do not apply to the following: [...].

លក្ខខណ្ឌតម្រូវបច្ចុប្បន្នដែលទិន្នន័យត្រូវផ្តល់ក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ តែងតែមានភ្ជាប់នូវលក្ខខណ្ឌផ្សេងទៀត ដែលជាយល់ឃើញខុស តួយ៉ាងដូចជា លក្ខខណ្ឌហត្ថលេខា លក្ខខណ្ឌទម្រង់ដើម ជាដើម។ ដោយសារកត្តានេះហើយ ទើបនៅពេលតាក់តែងពីតួនាទីរបស់លក្ខខណ្ឌលាយលក្ខណ៍អក្សរ គេត្រូវយកចិត្តទុកដាក់ខ្ពស់ចំពោះការពិតដែលលក្ខខណ្ឌលាយលក្ខណ៍អក្សរនេះ គួរត្រូវបានចាត់ទុកជាស្រទាប់មួយទាបបំផុតរបស់ឋានានុក្រមនៃលក្ខខណ្ឌទាំងអស់ ពោលគឺដើម្បីបង្ហាញពីកម្រិតខុសគ្នានៃភាពជឿទុកចិត្តបាន ភាពអាចតាមដានបាន និងភាពដែលមិនអាចកែតម្រូវបាន នៃឯកសារជាលាយលក្ខណ៍អក្សរនៅលើក្រដាស។ ហេតុនេះ មិនគួរមានការយល់ច្រឡំរវាងលក្ខខណ្ឌលាយលក្ខណ៍អក្សរ និងលក្ខខណ្ឌមួយចំនួនទៀតដែលបញ្ជាក់ពីភាពច្បាស់លាស់ និងអាចជឿទុកចិត្តបាន ដូចជាការចុះហត្ថលេខាជាលាយលក្ខណ៍អក្សរ ឬអត្ថបទដើមដែលបានត្រូវបានចុះហត្ថលេខា នោះឡើយ។ ឧទាហរណ៍ យោងតាមទៅតាមវិធានច្បាប់នៃប្រទេសមួយចំនួន ឯកសារជាលាយលក្ខណ៍អក្សរមួយចំនួន ដែលមិនមានបញ្ជាក់ពីកាលបរិច្ឆេទ ឬ មិនត្រូវបានចុះហត្ថលេខា ឬ មិនបានបង្ហាញពីអ្នកសរសេរ ក៏នឹងត្រូវចាត់ទុកថាបានបំពេញលក្ខខណ្ឌលាយលក្ខណ៍អក្សរផងដែរ បើទោះបីជាឯកសារប្រភេទទាំងនេះមានទម្ងន់ភស្តុតាងបន្តិចបន្តួចក៏ដោយ។ បន្ថែមពីនេះ ភាពមិនអាចកែប្រែបាន ក៏មិនគួរចាត់ទុកថាជាផ្នែកមួយដែលមិនអាចខ្វះបានក្នុងការបង្កើតលក្ខខណ្ឌលាយលក្ខណ៍អក្សរផងដែរ ពីព្រោះថា ការសរសេរដោយប្រើខ្មៅដៃ ក៏អាចត្រូវបានចាត់ទុកថាជា លក្ខខណ្ឌលាយលក្ខណ៍អក្សរ ដោយផ្អែកតាមអត្ថបទច្បាប់ជាក់លាក់មួយចំនួនផងដែរ។[25]

ពាក់ព័ន្ធនឹងមាត្រា ៦ ខាងលើនេះ វាក្យសព្ទ "*អាចចូលទៅប្រើប្រាស់បាន*" សំដៅទៅលើព័ត៌មាននៅក្នុងទិន្នន័យកុំព្យូទ័រដែលរក្សាទុក សម្រាប់អាចអានបាន និងបកស្រាយបាន ដើម្បីមនុស្សអាចប្រើប្រាស់ និងដំណើរការនៅក្នុងកុំព្យូទ័រ។

ចំណែកឯ "*ជាសំអាងនៅពេលក្រោយ*" សំដៅដល់ភាពយូរអង្វែង និងមិនអាចកែប្រែបាន ដែលកត្តានេះបានបង្កើតជាស្តង់ដារខ្ពស់មួយ។

ដោយឡែក កថាខណ្ឌទី៣ នៃមាត្រានេះ មិនត្រូវបានបំពេញនោះឡើយ ក្នុងគោលបំណងពង្រឹងបន្ថែមនូវភាពដែលអាចទទួលយកបាននៃច្បាប់គំរូ តាមរយៈការផ្តល់សិទ្ធិដល់រដ្ឋ ដែលអនុវត្តច្បាប់គំរូ ដែលអាចបញ្ញត្តិពីករណីលើកលែងរៀងៗខ្លួន។[26]

---

[25] សេចក្តីណែនាំឱ្យអនុម័ត ច្បាប់គំរូស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (Guide to Enactment of the UNCITRAL Model Law on Electronic Commerce (1996))

[26] សេចក្តីណែនាំឱ្យអនុម័ត ច្បាប់គំរូស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ១៩៩៦ ទំព័រទី៣៥-៣៧

យ៉ាងណាមិញ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៅប្រទេសកម្ពុជា[27] ក៏ត្រូវបានតាក់តែងឡើងស្រដៀងគ្នាទៅនឹងច្បាប់គំរូផងដែរ ដោយចាត់ទុកថាលក្ខខណ្ឌតម្រូវនេះត្រូវបានបំពេញប្រសិនបើព័ត៌មាន ដែលធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក អាចចូលទៅប្រើប្រាស់បាន និងយកជាសំអាងបាននៅពេលក្រោយ ពោលគឺត្រូវបានចូលប្រើប្រាស់ និងអាចយកជាសំអាងនៅពេលក្រោយ។ បន្ថែមពីនេះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា បានកម្រិតអំពីទម្រង់លាយលក្ខណ៍អក្សរ ដោយឡែកពីលក្ខខណ្ឌផ្សេងទៀត ដោយបញ្ញត្តិថា នៅពេលដែលកថាខណ្ឌទី១នេះ ត្រូវបានយកអនុវត្ត ហើយច្បាប់ទាមទារឱ្យបុគ្គលណាមួយផ្តល់សំណៅចម្លងច្រើនច្បាប់ក្នុងពេលតែមួយ ទៅឱ្យបុគ្គលផ្សេងទៀត នោះគេអាចបំពេញលក្ខខណ្ឌនេះបានដោយគ្រាន់តែផ្តល់ក្រោមទម្រង់អេឡិចត្រូនិកតែមួយច្បាប់ប៉ុណ្ណោះ។

ជារួមមក ជាសេចក្តីសន្និដ្ឋាន លក្ខខណ្ឌលាយលក្ខណ៍អក្សរ ត្រូវបានបំពេញប្រសិនបើព័ត៌មានណាមួយធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក ហើយអាចចូលទៅប្រើប្រាស់បាន និងអាចយកជាសំអាងនៅពេលក្រោយបាន ជាមួយនឹងមុខងារជាក់លាក់របស់លក្ខខណ្ឌមួយនេះ។

**២.១.១.២. ហត្ថលេខា**

ហត្ថលេខាតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវតែបំពេញលក្ខខណ្ឌទាំងអស់ ដូចគ្នានឹងហត្ថលេខាដែលសរសេរដោយដៃ។[28]

មាត្រា ៧ នៃ ច្បាប់គំរូស្តីពីណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ១៩៩៨ (UNCITRAL Model Law on Electronic Commerce, 1998) បានចែងពាក់ព័ន្ធនឹងលក្ខខណ្ឌហត្ថលេខាថា៖

"១. នៅពេលដែលច្បាប់តម្រូវឱ្យមានហត្ថលេខារបស់បុគ្គលណាមួយ លក្ខខណ្ឌតម្រូវនោះត្រូវបានបំពេញ ពាក់ព័ន្ធនឹងទិន្នន័យ ប្រសិនបើ៖

ក. មធ្យោបាយមួយ ត្រូវបានប្រើប្រាស់សម្រាប់កំណត់ពីបុគ្គលនោះ និងបង្ហាញពីការព្រមព្រៀងរបស់បុគ្គលនោះចំពោះព័ត៌មានដែលមាននៅក្នុងទិន្នន័យ, និង

ខ. មធ្យោបាយប្រើប្រាស់នោះ អាចទុកចិត្តបាន ហើយសមស្របទៅនឹងគោលបំណងដែលទិន្នន័យត្រូវបានបង្កើតឡើង ឬ យកមកប្រាស្រ័យទាក់ទងដោយបានពិចារណាពីកាលៈទេសៈនៅជុំវិញ រួមទាំងកិច្ចព្រមព្រៀងទាំងឡាយដែលពាក់ព័ន្ធ។

[27] សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកមមតាមប្រព័ន្ធអេឡិចត្រូនិក, ឆ្នាំ២០១៦, មាត្រា ៥(១) "លក្ខខណ្ឌតម្រូវជាលាយលក្ខណ៍អក្សរ"

[28] សារណាបញ្ចប់ថ្នាក់អនុបណ្ឌិត អំពី បទដ្ឋានច្បាប់សម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅអាស៊ាន៖ច្បាប់គំរូ ឆ្នាំ២០០៦/E-COMMERCE LEGAL FRAMEWORK FOR ASEAN: a MODEL CODE, National University of Singapore, 2006

២. កថាខណ្ឌទី១ ត្រូវអនុវត្ត ក្នុងករណីដែលលក្ខខណ្ឌនេះគឺជាកាតព្វកិច្ច ឬ ក្នុងករណីដែលច្បាប់មានបញ្ញត្តិពីលទ្ធផលនៃអវត្តមានហត្ថលេខា។

៣. បទបញ្ញត្តិនេះ មិនត្រូវបានអនុវត្តក្នុងករណីដូចតទៅ។ [...] ”។[29]

មាត្រា៧ ខាងលើនេះ ផ្អែកទៅលើការទទួលស្គាល់តួនាទីរបស់ហត្ថលេខា នៅក្នុងបរិបទនៃការចុះហត្ថលេខានៅលើក្រដាស។ នៅក្នុងដំណាក់កាលរៀបចំច្បាប់គំរូ តួនាទីនៃហត្ថលេខាមួយចំនួនត្រូវបានពិចារណា ដូចជា ការកំណត់ពីមនុស្ស ការផ្តល់ភាពច្បាស់លាស់អំពីការពាក់ព័ន្ធដោយផ្ទាល់របស់មនុស្សម្នាក់ជាមួយនឹងការចុះហត្ថលេខា ការផ្សារភ្ជាប់មនុស្សម្នាក់ទៅនឹងខ្លឹមសារនៃឯកសារណាមួយ។ បន្ថែមពីនេះ គួរកត់សម្គាល់ថា ហត្ថលេខា អាចដើរតួនាទីផ្សេងៗទៀត អាស្រ័យទៅតាមច្បាប់ដើមនៃឯកសារដែលត្រូវបានចុះហត្ថលេខា។ ឧទាហរណ៍ ហត្ថលេខា អាចជាភស្តុតាងបង្ហាញពីការបង្ហាញឆន្ទៈរបស់ភាគី ក្នុងការចងកាតព្វកិច្ចខ្លួនឯង តាមរយៈការចុះហត្ថលេខាលើ កិច្ចសន្យាណាមួយ ចេតនារបស់មនុស្សម្នាក់ក្នុងការគាំទ្រស្នាដៃនិពន្ធណាមួយ ចេតនារបស់មនុស្សក្នុងការចងភ្ជាប់ខ្លួនឯង ជាមួយនឹងខ្លឹមសារនៃឯកសារណាមួយ ដែលត្រូវបានសរសេរឡើងដោយអ្នកដទៃ ។

ការចុះហត្ថលេខាតាមបែបប្រពៃណី មាននីតិវិធីច្រើនប្រភេទផ្សេងៗគ្នា ដូចជា ការបោះត្រា ការចោះក្រដាស ពេលខ្លះក៏ត្រូវបានចាត់ទុកថាជាហត្ថលេខាផងដែរ ហើយដែលបង្កើតឱ្យមានកម្រិតផ្សេងគ្នានៃភាពច្បាស់លាស់ ជឿជាក់បាន។ ឧទាហរណ៍ ប្រទេសខ្លះ លក្ខខណ្ឌទូទៅដែលកិច្ចសន្យាលក់ទំនិញ នៅក្នុងចំនួនណាមួយត្រូវមានចុះហត្ថលេខា ដើម្បីអាចអនុវត្តបាន។ ដោយឡែក ផ្ទុតគំនិតពីក្រោយហត្ថលេខា នៅប្រទេសទាំងនោះ គឺអាចជាការបោះត្រា ការចោះក្រដាស ការចុះហត្ថលេខាដោយផ្ទាល់ដៃ ការប្រើលិខិតដែលមានក្បាលលិខិតបញ្ជាក់ ក៏អាចត្រូវបានចាត់ទុកថាគ្រប់គ្រាន់ដើម្បីបំពេញលក្ខខណ្ឌហត្ថលេខា។

---

[29] UNCITRAL Model Law on Electronic Commerce, 1998, Article 7. Signature

(1) Where the law requires a signature of a person, that requirement is met in relation to a data message if:

*(a)* a method is used to identify that person and to indicate that person′s approval of the information contained in the data message; and

*(b)* that method is as reliable as was appropriate for the purpose for which the data message was generated or communicated, in the light of all the circumstances, including any relevant agreement.

(2) Paragraph (1) applies whether the requirement therein is in the form of an obligation or whether the law simply provides consequences for the absence of a signature.

(3) The provisions of this article do not apply to the following: [...].

ដើម្បីធានាថា ខ្លឹមសារដែលទាមទារឱ្យមានភាពដែលអាចជឿជាក់បាន មិនត្រូវបានជំទាស់ពីសុពលភាពគតិយុត្ត ដោយសារតែខ្លឹមសារណាមួយនោះ មិនត្រូវបានចុះហត្ថលេខានៅលើក្រដាស មាត្រា ៧ នៃច្បាប់គំរូបានអនុម័តនូវ មធ្យោបាយដ៏ធំទូលាយ ដោយបានបង្កើតនូវលក្ខខណ្ឌទូទៅ ដែលខ្លឹមសារ ឬ ទិន្នន័យ នឹងត្រូវបានចាត់ទុកថាបានផ្ទៀងផ្ទាត់ត្រឹមត្រូវ ហើយអាចអនុវត្តបាន ដោយគ្រាន់តែបំពេញលក្ខខណ្ឌហត្ថលេខា ដូចដែលមាននៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ មាត្រា ៧ នេះ ផ្តោតសំខាន់ទៅលើ តួនាទីជាមូលដ្ឋានចំនួន ២ របស់លក្ខខណ្ឌហត្ថលេខា ដែលរួមមាន ភាពដែលអាចកំណត់ពីអ្នកសរសេរឯកសារ ហើយអ្នកសរសេរនោះឯកភាពចំពោះ ខ្លឹមសារនៅក្នុងឯកសារនោះ។ កថាខណ្ឌទី១ ត្រង់ចំណុច ក បង្កើតនូវគោលការណ៍មួយសម្រាប់នៅក្នុងបរិបទអេឡិចត្រូនិក ដោយបានកំណត់ថា សុពលភាពគតិយុត្តជាមូលដ្ឋាននៃលក្ខខណ្ឌហត្ថលេខា នឹងត្រូវបានបំពេញ ដោយគ្រាន់តែមានមធ្យោបាយដើម្បីកំណត់ពីម្ចាស់របស់ទិន្នន័យ និងអាចបញ្ជាក់បានថាម្ចាស់ទិន្នន័យនោះយល់ព្រមចំពោះខ្លឹមសារនោះ។

កថាខណ្ឌទី១ ដដែល ប៉ុន្តែត្រង់ចំណុច ខ បង្កើតឱ្យមាននូវនីតិវិធីបត់បែនពាក់ព័ន្ធនឹងបញ្ហាសុវត្ថិភាព ដែលត្រូវសម្រេចបានដោយនីតិវិធីកំណត់ពីអត្តសញ្ញាណ ដែលបានបញ្ញត្តិនៅក្នុងកថា-ខណ្ឌទី១ ចំណុច ក។ មធ្យោបាយដែលប្រើនៅក្នុងកថាខណ្ឌទី១ ចំណុច ក ត្រូវតែសមស្របទៅនឹងគោលបំណង ដែលទិន្នន័យត្រូវបានបង្កើតឡើង ដោយបានគ្របដណ្តប់ទៅលើលក្ខខណ្ឌជុំវិញ រួមទាំងកិច្ចព្រមព្រៀងរវាងអ្នកបង្កើត និងអ្នកទទួលបានទិន្នន័យនោះ។

ក្នុងការកំណត់ថាតើ មធ្យោបាយប្រើប្រាស់នៅក្នុងកថាខណ្ឌទី១ មានភាពសមរម្យឬយ៉ាងណានោះ កត្តាច្បាប់ បច្ចេកទេស ពាណិជ្ជកម្ម មួយចំនួនត្រូវបានយកមកពិចារណាដែលរួមមានភាពដែលអាចទទួលយកបាននៃសម្ភារប្រើប្រាស់ដោយភាគី ចរិតលក្ខណៈនៃសកម្មភាពពាណិជ្ជ-កម្ម ភាពញឹកញាប់ដែលសកម្មភាពពាណិជ្ជកម្មរវាងភាគីត្រូវបានធ្វើឡើង ប្រភេទ និងទំហំនៃសកម្មភាពពាណិជ្ជកម្ម តួនាទីនៃលក្ខខណ្ឌតម្រូវហត្ថលេខានៅក្នុងបរិបទច្បាប់នៃប្រទេសណាមួយលទ្ធភាពនៃប្រព័ន្ធទំនាក់ទំនង ការអនុវត្តបាននូវនីតិវិធីផ្ទៀងផ្ទាត់ពីភាពដែលអាចជឿជាក់បានដែលកំណត់ដោយអន្តរការី ការអនុវត្តតាមទំនៀមទំលាប់ និងការអនុវត្តកន្លងមកនៃពាណិជ្ជកម្មយន្តការសម្រាប់ប្រើប្រាស់ប្រឆាំងនឹងខ្លឹមសារ ដែលមិនត្រូវបានអនុញ្ញាត សារៈសំខាន់នៃខ្លឹមសារដែលមាននៅក្នុងទិន្នន័យ ។ល។

មាត្រា ៧ នៃច្បាប់គំរូ មិនបានបង្ហាញពីភាពខុសគ្នារវាងស្ថានភាព ដែលអ្នកប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានផ្សារភ្ជាប់ដោយកិច្ចព្រមព្រៀងទំនាក់ទំនង និងស្ថាន-

ភាពដែលភាគីមិនធ្លាប់មានទំនាក់ទំនងកិច្ចសន្យាពីមុន ពាក់ព័ន្ធនឹងការប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ហេតុនេះ មាត្រា ៧ អាចត្រូវបានចាត់ទុកថាជាការបង្កើតនូវស្តង់ដារជាមូលដ្ឋាននៃការផ្ទៀងផ្ទាត់ភាព ដែលអាចជឿជាក់បានរបស់ទិន្នន័យ សម្រាប់ជំនួសនៅពេលអវត្តមាននៃទំនាក់ទំនងកិច្ចសន្យាពីមុនមក ហើយក្នុងពេលជាមួយគ្នានោះផ្តល់នូវការណែនាំថាតើអ្វីដែលអាចជាថ្នូរទៅនឹងហត្ថលេខា ប្រសិនបើភាគីប្រើប្រាស់ទម្រង់អេឡិចត្រូនិកនៅក្នុងការប្រាស្រ័យទាក់ទងនៅក្នុងការបង្កើតកិច្ចព្រមព្រៀង។ ច្បាប់គំរូ មានគោលបំណងផ្តល់នូវគោលការណ៍ណែនាំ ដែលមានប្រយោជន៍ដល់ បរិបទដែលច្បាប់ជាតិផ្តល់សិទ្ធិពេញលេញឱ្យទៅភាគីក្នុងការកំណត់ពីភាពដែលអាចជឿជាក់បាននៃទិន្នន័យ និងនៅក្នុងបរិបទដែលលក្ខខណ្ឌតម្រូវហត្ថលេខាដែលជាទូទៅត្រូវបានកំណត់ជាលក្ខខណ្ឌចាំបាច់ដោយច្បាប់ជាតិ មិនអាចត្រូវបានកែប្រែដោយកិច្ចព្រមព្រៀងរបស់ភាគីនោះឡើយ។

គួរកត់សម្គាល់ផងដែរថា យោងតាមច្បាប់គំរូ ការចុះហត្ថលេខាតែមួយមុខទៅលើទិន្នន័យតាមមធ្យោបាយប្រហាក់ប្រហែលនឹងការចុះហត្ថលេខាដោយផ្ទាល់ដៃ មិនមានចេតនាក្នុងការបង្កើតនូវសុពលភាពគតិយុត្តដល់ទិន្នន័យនោះទេ ពោលគឺខ្លឹមសារ ឬ ទិន្នន័យនោះ នឹងបំពេញលក្ខខណ្ឌតម្រូវកិច្ចសន្យា យោងទៅតាមការកំណត់របស់ច្បាប់មួយផ្សេង ពីច្បាប់គំរូស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ១៩៩៨ (ច្បាប់ផ្សេងនោះគឺ ច្បាប់គំរូស្តីពីហត្ថលេខាតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ ២០០១ UNCITRAL Model Law on Electronic Signatures 2001)។

ប្រហាក់ប្រហែលគ្នានឹង មាត្រា ៧ នៃច្បាប់គំរូខាងលើ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៅប្រទេសកម្ពុជា[30] ចាត់ទុកថាលក្ខខណ្ឌតម្រូវចំពោះហត្ថលេខាត្រូវបានបំពេញតាមរយៈការចុះហត្ថលេខាតាមប្រព័ន្ធអេឡិចត្រូនិក ដោយហត្ថលេខានោះត្រូវតែអាចជឿជាក់បាន សមស្របតាមគោលបំណងដែលទំនាក់ទំនងនោះត្រូវបានបង្កើតឡើង ហើយឆ្លុះបញ្ចាំងពីកាលៈទេសៈជាក់ស្តែង រួមទាំងកិច្ចសន្យាដែលពាក់ព័ន្ធ។ម្យ៉ាងទៀត ដើម្បីកំណត់ពីភាពដែលអាចជឿជាក់បាននៃហត្ថលេខា មានលក្ខខណ្ឌមួយចំនួនដែលគេត្រូវគោរព ដូចជា ៖ ការផ្សារភ្ជាប់ទៅនឹងហត្ថលេខីតែម្នាក់គត់ ការអាចកំណត់បានពីហត្ថលេខីនោះ មធ្យោបាយប្រើប្រាស់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ហត្ថលេខី និងព័ត៌មានដែលនៅក្នុងទិន្នន័យអាចឱ្យបុគ្គលណាមួយកែប្រែបាននៅពេលក្រោយ។

[30] សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ២០១៦, មាត្រា ៦ "លក្ខខណ្ឌតម្រូវចំពោះហត្ថលេខា"

ជាងនេះទៅទៀត គេសង្កេតឃើញថា សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅប្រទេសកម្ពុជា ត្រង់កថាខណ្ឌទី៤ សបង្ហាញឱ្យឃើញថាប្រទេសកម្ពុជាស្ថិតនៅក្នុងបរិបទមួយថា ដែលបុគ្គលជាភាគីមានសិទ្ធិពេញលេញ ក្នុងការកំណត់ពីលក្ខខណ្ឌផ្សេងទៀតដើម្បីបញ្ជាក់ភាពដែលអាចជឿជាក់បានរបស់ហត្ថលេខាអេឡិចត្រូនិក និងអាចលើកភស្តុតាងពីភាពមិនអាចជឿជាក់បាននៃហត្ថលេខាអេឡិចត្រូនិកផងដែរ។

សរុបសេចក្តីមក លក្ខខណ្ឌតម្រូវចំពោះហត្ថលេខា ចាំបាច់ត្រូវតែបំពេញក្នុងករណីដែលបទប្បញ្ញត្តិណាមួយកំណត់ពីលក្ខខណ្ឌតម្រូវនេះ ឬ បទប្បញ្ញត្តិនោះគ្រាន់តែកំណត់ពីផលវិបាកនៃការមិនចុះហត្ថលេខា។ លក្ខខណ្ឌតម្រូវនេះទៀតសោត អាចត្រូវបានបំពេញដោយ បង្ហាញពីភាពដែលអាចជឿជាក់បាន និងភាពសមស្របទៅនឹងគោលបំណងដែលទំនាក់ទំនងនោះបង្កើតឡើងព្រមទាំងឆ្លុះបញ្ចាំងពីកាលៈទេសៈជាក់ស្តែង។

**២.១.១.៣. ទម្រង់ដើម**

មាត្រា ៨ នៃ ច្បាប់គំរូស្តីពីណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ១៩៩៨ (UNCITRAL Model Law on Electronic Commerce, 1998) បានចែងពាក់ព័ន្ធនឹងលក្ខខណ្ឌទម្រង់ដើមថា៖

"(១) នៅពេលដែលច្បាប់ទាមទារឱ្យមានការផ្តល់ព័ត៌មាននៅក្នុងទម្រង់ដើម លក្ខខណ្ឌតម្រូវនេះនឹងត្រូវបានបំពេញ ដោយទិន្នន័យ ប្រសិនបើ៖

(ក) មានការធានាច្បាស់លាស់ពាក់ព័ន្ធនឹងសុចរិតភាពនៃព័ត៌មាន ចាប់ពីពេលដែលវាត្រូវបានបង្កើតឡើងនៅក្នុងទម្រង់ចុងក្រោយថាជាទិន្នន័យ ឬ មិនមែន; ហើយ

(ខ) នៅពេលដែលមានការតម្រូវឱ្យធ្វើការបង្ហាញព័ត៌មាន ហើយព័ត៌មាននោះអាចត្រូវបានបង្ហាញទៅឱ្យបុគ្គល ដែលតម្រូវឱ្យមានការធ្វើការបង្ហាញចំពោះខ្លួន។

(២) កថាខណ្ឌទី១ ត្រូវអនុវត្តនៅពេលដែលមានលក្ខខណ្ឌតម្រូវក្នុងទម្រង់ជាកាតព្វកិច្ច ឬ នៅពេលដែលច្បាប់គ្រាន់តែបញ្ញត្តិពីផលវិបាកនៃការមិនបង្ហាញព័ត៌មាន នៅក្នុងទម្រង់ដើម។

(៣) ចំពោះ ចំណុច (ក) កថាខណ្ឌទី (១)៖

(ក) លក្ខខណ្ឌសម្រាប់ធ្វើការវាយតម្លៃពីភាពសុចរិត គឺព័ត៌មាននោះមានភាពពេញលេញ និងមិនអាចកែប្រែបាន ដាច់ដោយឡែកពីការកែប្រែដែលអាចកើតចេញពីទំនាក់ទំនងធម្មតា ការផ្ទុក និងការបង្ហាញ។

(ខ) ស្តង់ដារនៃភាពដែលអាចជឿជាក់បានដែលតម្រូវ នឹងត្រូវវាយតម្លៃ ដោយពិនិត្យទៅលើគោលបំណង ដែលព័ត៌មាននោះត្រូវបានបង្កើតឡើង និងឆ្លុះបញ្ចាំងពីកាលៈទេសៈជាក់ស្តែង។

(៤) បទបញ្ញត្តិនៃមាត្រានេះ មិនត្រូវបានអនុវត្តក្នុងករណីដូចតទៅ។ [...]"។[31]

ទម្រង់ដើម នៅក្នុងមាត្រា ៨ នៃច្បាប់គំរូ មានសារៈសំខាន់ ពីព្រោះនៅក្នុងការអនុវត្ត ជម្លោះជាច្រើនពាក់ព័ន្ធទៅនឹងទម្រង់ដើមនៃឯកសារ ចំណែកឯនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក លក្ខខណ្ឌតម្រូវនៃការបង្ហាញច្បាប់ដើម គឺជាឧបសគ្គចំបងមួយ ដែលច្បាប់គំរូព្យាយាមលុបបំបាត់ ។ ទោះជានៅក្នុងយុត្តាធិការខ្លះ លក្ខខណ្ឌលាយលក្ខណ៍អក្សរ លក្ខខណ្ឌហត្ថលេខា និងលក្ខខណ្ឌទម្រង់ដើម អាចជាន់គ្នាក៏ដោយ ច្បាប់គំរូបានកំណត់ថា លក្ខខណ្ឌទាំង ៣ ត្រូវបានចែកដាច់ពីគ្នា។ មាត្រា ៨ នៃច្បាប់គំរូ ក៏អាចបញ្ជាក់បន្ថែមពី លក្ខខណ្ឌលាយលក្ខណ៍អក្សរ និងទម្រង់ដើម ជាពិសេសពាក់ព័ន្ធនឹងសារសំខាន់នៃភស្តុតាង។

មាត្រា ៨ ពាក់ព័ន្ធទៅនឹងឯកសារផ្លូវការសិទ្ធិ-កម្មសិទ្ធិ និងឯកសារខាងពាណិជ្ជកម្មដូចជាវិក្កយបត្រ ឬ សែក (cheque) ដែលទាមទារឱ្យមានលក្ខណៈពិសេសនៃទម្រង់ដើម។ ដោយឡែកគួរកត់សម្គាល់ថាច្បាប់គំរូ មិនមានគោលបំណងអនុវត្តចំពោះតែឯកសារដូចដែលបានរៀបរាប់ខាងលើនេះ ឬ សម្រាប់ផ្នែកណាមួយនៃច្បាប់ដែលទាមទារឱ្យមានលក្ខខណ្ឌពិសេសក្នុងការចុះបញ្ជី ឬ សម្រាប់ប្រភេទលិខិតយថាភូតនោះទេ ដូចជាការទិញ លក់ អចលនវត្ថុនោះទេ។ ឧទាហរណ៍នៃឯកសារ ដែលអាចទាមទារឱ្យមានទម្រង់ដើម រួមមាន ឯកសារពាក់ព័ន្ធនឹងពាណិជ្ជកិច្ច ដូចជាវិញ្ញាបនបត្របញ្ជាក់ពីទំងន់ វិញ្ញាបនបត្រកសិកម្ម វិញ្ញាបនបត្របញ្ជាក់ពីគុណភាព ឬ បរិមាណរបាយការណ៍ស្តីពីអធិការកិច្ច វិញ្ញាបនបត្របញ្ជាក់ពីការធានារ៉ាប់រង ជាដើម។ ខណៈពេលដែល

[31] UNCITRAL Model Law on Electronic Commerce, 1998, Article 8. Original

(1) Where the law requires information to be presented or retained in its original form, that requirement is met by a data message if:

*(a)* there exists a reliable assurance as to the integrity of the information from the time when it was first generated in its final form, as a data message or otherwise; and

*(b)* where it is required that information be presented, that information is capable of being displayed to the person to whom it is to be presented.

(2) Paragraph (1) applies whether the requirement therein is in the form of an obligation or whether the law simply provides consequences for the information not being presented or retained in its original form.

(3) For the purposes of subparagraph *(a)* of paragraph (1):

*(a)* the criteria for assessing integrity shall be whether the information has remained complete and unaltered, apart from the addition of any endorsement and any change which arises in the normal course of communication, storage and display; and

*(b)* the standard of reliability required shall be assessed in the light of the purpose for which the information was generated and in the light of all the relevant circumstances.

(4) The provisions of this article do not apply to the following: [...].

ឯកសារទាំងនេះ មិនមែនជាប្រភេទឯកសារសម្រាប់ចរចា ឬ ប្រើប្រាស់សម្រាប់ផ្ទេរសិទ្ធិកម្មសិទ្ធិ វាមានសារៈសំខាន់ដែលឯកសារទាំងនេះមិនអាចកែប្រែ ហើយស្ថិតនៅក្នុងទម្រង់ដើម ពីព្រោះដើម្បីធានាថាភាគីម្ខាងទៀតនៅក្នុងទំនាក់ទំនងពាណិជ្ជកម្ម មានទំនុកចិត្តចំពោះខ្លឹមសារនៅក្នុងឯកសារទាំងនោះ។ នៅក្នុងបរិបទនៃការប្រើប្រាស់ក្រដាស ឯកសារប្រភេទនេះអាចទទួលយកបានតែក្នុងករណីដែលវាជាឯកសារច្បាប់ដើម ដើម្បីកាត់បន្ថយលទ្ធភាពដែលវាអាចត្រូវបានកែប្រែ ពីព្រោះចំពោះឯកសារជាក្រដាស មានការលំបាកក្នុងការកំណត់ថាវាជាឯកសារច្បាប់ដើម ឬ ចតចម្លង។ មធ្យោបាយបច្ចេកទេសមួយចំនួន អាចត្រូវបានប្រើប្រាស់ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃខ្លឹមសាររបស់ទិន្នន័យណាមួយ។ ប្រសិនបើគ្មានមធ្យោបាយបច្ចេកទេសនេះ ការលក់ទំនិញតាមប្រព័ន្ធអេឡិចត្រូនិក អាចត្រូវបានរាំងស្ទះ ពីព្រោះអ្នកដែលចេញនូវឯកសារទាំងនោះ នឹងត្រូវបានតម្រូវឱ្យបញ្ជូនទិន្នន័យរបស់ខ្លួនរៀងរាល់ពេលដែលមានការលក់ទំនិញ។ បើមិនដូច្នោះទេ ភាគីនឹងត្រូវបង្ខំចិត្តប្រើឯកសារក្រដាស ជំនួសឱ្យការធ្វើទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

មាត្រា ៨ នៃច្បាប់គំរូ បង្ហាញពីសារសំខាន់នៃសុចរិតភាពរបស់ព័ត៌មាន ដែលបំពេញទម្រង់ដើម និងកំណត់ពីលក្ខខណ្ឌចាំបាច់សម្រាប់វាយតម្លៃសុចរិតភាព ដោយយោងទៅលើការកត់ត្រានៃព័ត៌មានជាប្រព័ន្ធ ការធានាថាព័ត៌មានត្រូវបានកត់ត្រាដោយមិនមានចន្លោះប្រហោង ហើយទិន្នន័យមានការការពារប្រឆាំងនឹងការកែប្រែ។ វាផ្សារភ្ជាប់នូវទម្រង់ដើម ទៅនឹងវិធីសាស្ត្រនៃការផ្ទៀងផ្ទាត់ពីភាពដែលអាចជឿជាក់បាន ហើយផ្តោតសំខាន់ទៅលើមធ្យោបាយនៃការផ្ទៀងផ្ទាត់ដែលត្រូវធ្វើដើម្បីបំពេញលក្ខខណ្ឌ។ មធ្យោបាយនោះមានធាតុផ្សំដូចជា លក្ខខណ្ឌសាមញ្ញពាក់ព័ន្ធនឹងសុចរិតភាពរបស់ទិន្នន័យ ការរៀបរាប់ពីធាតុផ្សំដែលចាំបាច់សម្រាប់វាយតម្លៃសុចរិតភាព និងធាតុផ្សំនៃការបត់បែន។

ដូចដែលមានបញ្ញត្តិនៅក្នុងកថាខណ្ឌទី១ ត្រង់ចំណុច ក *"ពេលដែលវាត្រូវបានបង្កើតឡើងនៅក្នុងទម្រង់ចុងក្រោយ"* គួរកត់សម្គាល់ថាខ្លឹមសារនេះ មានគោលបំណងបង្ហាញពីស្ថានភាពមួយដែលព័ត៌មានត្រូវបានបង្កើតឡើងដំបូងនៅលើក្រដាស ហើយបន្ទាប់មកត្រូវបានបញ្ចូលទៅក្នុងកុំព្យូទ័រ។ នៅក្នុងករណីបែបនេះ កថាខណ្ឌទី១ ចំណុច ក ត្រូវបានបកស្រាយថាជាលក្ខខណ្ឌតម្រូវដែលព័ត៌មានចាំបាច់ត្រូវតែពេញលេញ និងមិនអាចកែប្រែបាន ចាប់ពីពេលដែលវាត្រូវបានដាក់បញ្ចូលទៅក្នុងក្រដាស ពោលគឺមិនមែនគិតចាប់ពីពេលដែលវាត្រូវបានដាក់បញ្ចូលទៅក្នុងទម្រង់អេឡិចត្រូនិកនោះទេ។ ប៉ុន្តែ ចំពោះករណីដែលមានសេចក្តីព្រាងមួយចំនួនត្រូវបានបង្កើតឡើង

និងរក្សាទុក មុនពេលដែលទិន្នន័យចុងក្រោយត្រូវបានបង្កើតឡើង កថាខណ្ឌទី១ ចំណុច ក មិនត្រូវធ្វើការបកស្រាយដោយតម្រូវឱ្យមានសុចរិតភាពនៅក្នុងសេចក្ដីព្រាងនោះទេ។

កថាខណ្ឌទី៣ ចំណុច ក ចែងពីលក្ខខណ្ឌតម្រូវសម្រាប់វាយតម្លៃសុចរិតភាព បញ្ជាក់ពីករណីលើកលែងចំពោះលក្ខខណ្ឌទម្រង់ដើមនៃទិន្នន័យ ដូចជា ការបញ្ជាក់ ជាដើម ដែលត្រូវបានញែកដាច់ចេញពីការកែប្រែ។ ដរាបណាខ្លឹមសារនៃទិន្នន័យ ពេញលេញ និងមិនមានការកែប្រែ ការបន្ថែមផ្សេងៗទៅលើទិន្នន័យនោះនឹងមិនប៉ះពាល់ដល់លក្ខខណ្ឌទម្រង់ដើមនេះទេ។ ដូច្នេះ នៅពេលដែលវិញ្ញាបនបត្រអេឡិចត្រូនិក ត្រូវបានបន្ថែមទៅលើទិន្នន័យដើម ដើម្បីគាំទ្រលក្ខខណ្ឌទម្រង់ដើម ឬ នៅពេលដែលទិន្នន័យត្រូវបានដាក់បញ្ចូលជាស្វ័យប្រវត្តិដោយប្រព័ន្ធកុំព្យូទ័រ នៅចំណុចចាប់ផ្ដើម និងចុងបញ្ចប់នៃទិន្នន័យ ដើម្បីបញ្ជូនទិន្នន័យនោះ សកម្មភាពនេះត្រូវចាត់ទុកថាជាក្រដាសបន្ថែមដែលមានភ្ជាប់នូវទម្រង់ដើម ឬ ជាស្រោមសំបុត្រ ដែលមានបិទតែម៍ ដើម្បីបញ្ជូនក្រដាសដែលមានទម្រង់ដើម។

ពាក់ព័ន្ធនឹងលក្ខខណ្ឌទម្រង់ដើមនេះ សេចក្ដីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៅប្រទេសកម្ពុជា[32] ហាក់ដូចជាមិនបានធ្វើការ កំណត់លម្អិតពាក់ព័ន្ធទៅនឹងសុចរិតភាពនៃព័ត៌មាន ពេលវេលា ឬ កាលៈទេសៈដែលលក្ខខណ្ឌទម្រង់ដើមនេះត្រូវតែបំពេញនោះទេ ពោលគឺសេចក្ដីព្រាងច្បាប់នេះគ្រាន់តែធ្វើការផ្ដល់សុពលភាពគតិយុត្ត ដល់ការរក្សាព័ត៌មានដែលមិនត្រូវបានធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិក ហើយដែលព័ត៌មាននោះអាចត្រូវបានរក្សាក្នុងទម្រង់អេឡិចត្រូនិក ដោយគ្រាន់តែបំពេញនូវលក្ខខណ្ឌមួយចំនួន ដូចជា ទម្រង់អេឡិចត្រូនិកនោះជាមធ្យោបាយដែលអាចទុកចិត្តបាន ដើម្បីកំណត់ពីភាពពេញលេញរបស់ព័ត៌មាន ហើយអាចចូលទៅប្រើប្រាស់ដោយងាយស្រួលបាននៅពេលក្រោយតែប៉ុណ្ណោះ។

ហេតុនេះ សរុបសេចក្ដីមក លក្ខខណ្ឌតម្រូវដើម្បីបញ្ជាក់ពីទម្រង់ដើម នៅក្នុងបរិបទនៃប្រទេសកម្ពុជា មានគោលបំណងសំខាន់មួយគឺផ្ដល់សុពលភាពគតិយុត្ត ដល់រាល់ព័ត៌មានទាំងឡាយ ដែលត្រូវបានរក្សាទុកក្នុងទម្រង់អេឡិចត្រូនិក បើទោះជាព័ត៌មាននោះមិនត្រូវបានធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិកក៏ដោយ។

#### ២.១.១.៤. ភស្តុតាង

មាត្រា ៩ នៃ ច្បាប់គំរូស្ដីពីណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ១៩៩៨ (UNCITRAL Model

[32] សេចក្ដីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ឆ្នាំ២០១៦, មាត្រា ៧ "លក្ខខណ្ឌតម្រូវដើម្បីបញ្ជាក់ពីទម្រង់ដើម"

Law on Electronic Commerce, 1998) បានចែងពាក់ព័ន្ធនឹងភាពដែលអាចទទួលបាន និងទម្ងន់នៃភស្តុតាងរបស់ទិន្នន័យ ថា៖

"(១) នៅក្នុងនីតិវិធីច្បាប់ មិនមានបទបញ្ញត្តិអំពីភស្តុតាងណាមួយ ដែលនឹងត្រូវអនុវត្ត ដើម្បីបដិសេធនឹងភាពដែលអាចទទួលបានរបស់ទិន្នន័យដែលជាភស្តុតាង៖

(ក) ដោយមូលហេតុតែមួយគត់ គឺវាជាព័ត៌មានបែបទិន្នន័យ; ឬ

(ខ) ប្រសិនបើវាជាភស្តុតាងដែលល្អបំផុត ដោយមនុស្សប្រើប្រាស់វា អាចនឹងត្រូវបានរំពឹងថានឹងទទួលបាន ពីព្រោះតែវាមិនមែនស្ថិតនៅក្នុងទម្រង់ដើម។

(២) ព័ត៌មានដែលស្ថិតនៅក្នុងទម្រង់ជាទិន្នន័យ ត្រូវទទួលមានទម្ងន់ភស្តុតាងសមស្រប។ ក្នុងការវាយតម្លៃពីទម្ងន់នៃភស្តុតាងរបស់ទិន្នន័យ ត្រូវយកចិត្តទុកដាក់ចំពោះភាពដែលអាចជឿជាក់បានរបស់មធ្យោបាយដែលទិន្នន័យត្រូវបានបង្កើត ផ្ទុក ប្រាស្រ័យទាក់ទង ចំពោះភាពដែលអាចជឿជាក់បាន របស់មធ្យោបាយដែលសុចរិតភាពរបស់ព័ត៌មានត្រូវបានការពារ ចំពោះមធ្យោបាយដែលអ្នកបង្កើតទិន្នន័យត្រូវបានកំណត់ឡើង និងចំពោះកត្តាដែលពាក់ព័ន្ធជាច្រើនទៀត។"។[33]

គោលបំណងនៃមាត្រា ៩ នៃច្បាប់គំរូ គឺបង្កើតភាពដែលអាចទទួលយកជាភស្តុតាងបានរបស់ទិន្នន័យនៅក្នុងនីតិវិធីច្បាប់ និងតម្លៃជាភស្តុតាងរបស់ទិន្នន័យទាំងនោះ។ ពាក់ព័ន្ធនឹងភាពដែលអាចទទួលយកបាន កថាខណ្ឌទី១ នៃមាត្រា ៨ នៃច្បាប់គំរូ ដែលហាមឃាត់មិនឱ្យមានការបដិសេធពីភាពដែលអាចទទួលយកបាន នៅក្នុងនីតិវិធីច្បាប់ ដោយសំអាងទៅលើហេតុផលតែមួយគត់ ពោលគឺទិន្នន័យទាំងនោះត្រូវបានបង្កើតឡើងក្នុងទម្រង់អេឡិចត្រូនិក បានផ្តោតទៅលើគោលការណ៍ទូទៅ ដែលចាំបាច់ដើម្បីបង្ហាញពីភាពដែលអាចទទួលបានរបស់ភស្តុតាង (ផ្នែកមួយដែលបញ្ហាស្មុគស្មាញអាចកើតមានឡើងនៅក្នុងយុត្តាធិការជាក់លាក់ណាមួយ)។ ពាក្យថា " ភស្តុ-

[33] UNCITRAL Model Law on Electronic Commerce, 1998, Article 9. Admissibility and evidential weight of data messages

(1) In any legal proceedings, nothing in the application of the rules of evidence shall apply so as to deny the admissibility of a data message in evidence:

*(a)* on the sole ground that it is a data message; or,

*(b)* if it is the best evidence that the person adducing it could reasonably be expected to obtain, on the grounds that it is not in its original form.

(2) Information in the form of a data message shall be given due evidential weight. In assessing the evidential weight of a data message, regard shall be had to the reliability of the manner in which the data message was generated, stored or communicated, to the reliability of the manner in which the integrity of the information was maintained, to the manner in which its originator was identified, and to any other relevant factor.

តាងល្អបំផុត " ត្រូវបានគេយល់ ហើយមានភាពចាំបាច់ នៅក្នុងយុត្តាធិការដាក់លាក់ណាមួយនៃប្រព័ន្ធ ខមមិនឡូ។ ដោយឡែក ពាក្យថា ភស្តុតាងល្អបំផុត អាចបង្កឱ្យមានភាពមិនច្បាស់លាស់មួយចំនួននៅក្នុងប្រព័ន្ធច្បាប់ ដែលវិធាននេះមិនត្រូវបានផ្សព្វផ្សាយ។ ចំពោះរដ្ឋដែលវិធាននេះ មិនមានអត្ថន័យ ខ្លឹមសារ អ្វីទាំងអស់ នឹងអនុម័តច្បាប់គំរូ ដោយមិនរួមបញ្ចូលនូវពាក្យ ភស្តុតាងល្អបំផុត ដែលមាននៅក្នុងកថាខណ្ឌទី១ នោះទេ។

ដូចដែលបញ្ជាក់នៅក្នុងការវាយតម្លៃនៃទម្ងន់ភស្តុតាងរបស់ទិន្នន័យ កថាខណ្ឌទី២ បានផ្តល់នូវសេចក្តីណែនាំដែលមានអត្ថប្រយោជន៍ ថាតើតម្លៃនៃភស្តុតាងរបស់ទិន្នន័យត្រូវបានវាយតម្លៃដោយរបៀបណា ឧទាហរណ៍ អាស្រ័យទៅលើមធ្យោបាយដែលទិន្នន័យត្រូវបានបង្កើតថែ-រក្សា ប្រាស្រ័យទាក់ទង នោះមានភាពជឿជាក់បាន ឬយ៉ាងណា។

សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៅប្រទេសកម្ពុជ[34] បានបញ្ញត្តិយ៉ាងសាមញ្ញ ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវស្តីពីភស្តុតាងនេះថា ទំនាក់ទំនងអេឡិចត្រូនិកជា ភស្តុ-តាង មិនអាចត្រូវបានជំទាស់មិនឱ្យមានការទទួលស្គាល់បានដោយគ្រាន់តែឈរលើមូលដ្ឋានថា ភស្តុតាងនោះជាទំនាក់ទំនងអេឡិចត្រូនិក ហើយមិនស្ថិតនៅក្នុងទម្រង់ដើមនោះឡើយ។ សេចក្តីព្រាងច្បាប់នេះ មិនបានបញ្ជាក់លម្អិតពីបញ្ហាទម្ងន់របស់ភស្តុតាងនេះឡើយ។

ហេតុនេះ ទាក់ទងនឹងលក្ខខណ្ឌតម្រូវស្តីពីភស្តុតាង សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គ្រាន់តែផ្តល់សុពលភាពគតិយុត្តដល់ភស្តុតាង ដែលអាចមានទម្រង់ជាអេឡិចត្រូនិក ដោយមិនបានបង្ហាញពីទម្ងន់នៃភស្តុតាងប្រភេទនេះឡើយ។

### ២.១.២. ការបង្កើត និងសុពលភាពគតិយុត្ត នៃកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិច-ត្រូនិក

កិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក៏អាចត្រូវបានបង្កើតឡើងដូចគ្នាទៅនឹងកិច្ចសន្យាទូទៅដែរ ពោលគឺនៅពេលមានជំនួបរវាងសំណើ និងស្វីការ។ ដោយឡែក ចំណុចដែលខុសគ្នារវាងកិច្ចសន្យាទូទៅ និងកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះគឺ សំណើ និងស្វីការ នៅក្នុងកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អាចត្រូវបានធ្វើឡើងតាមមធ្យោបាយទំនាក់ទំនងអេឡិចត្រូនិក [35] ពីព្រោះសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានផ្តល់សុពលភាពគតិយុត្តទៅដល់ទំនាក់ទំនងតាមមធ្យោបាយអេឡិចត្រូនិក ដូចដែលមានរៀបរាប់នៅក្នុងកថាខណ្ឌទី១ ខាងលើ។

[34] សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ២០១៦, មាត្រា ១០ "លក្ខខណ្ឌតម្រូវស្តីពីភស្តុតាង"
[35] ដូច ៣៣, មាត្រា ១១ "ការបង្កើត និងសុពលភាពកិច្ចសន្យា"

បន្ថែមពីលើការផ្ដល់សុពលភាពគតិយុត្ត នៃទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិក សេចក្ដីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក៏បានបញ្ញត្តិដំណើរការទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិក ដោយបញ្ជាក់ពី ពេលវេលា និងទីកន្លែងនៃការបញ្ជូនចេញ និងទទួលទំនាក់ទំនងអេឡិចត្រូនិក ដើម្បីបង្កលក្ខណៈងាយស្រួលដល់ភាគីក្នុងការកំណត់ថាតើ កិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានបង្កើតឡើងនៅពេលណាមួយឱ្យប្រាកដ។ ជាក់ស្ដែង ទំនាក់ទំនងអេឡិចត្រូនិកមួយបានបញ្ជូនចេញនៅពេលដែលទំនាក់ទំនងនោះ ចាកចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកផ្ញើ (ឬភាគីដែលផ្ញើជំនួស) ឬប្រសិនបើទំនាក់ទំនងនោះមិនទាន់បានចាកចេញពីប្រព័ន្ធព័ត៌មានរបស់អ្នកគ្រប់គ្រង ទំនាក់ទំនងនោះត្រូវបានផ្ញើចេញនៅពេលដែលទំនាក់ទំនងនោះត្រូវបានទទួល។ ម្យ៉ាងទៀត ទោះបីជាទំនាក់ទំនងនោះ ត្រូវបានផ្ញើចេញពីទីតាំងណាក៏ដោយ ក៏ត្រូវសន្មតថាទំនាក់ទំនងនោះ ត្រូវបានផ្ញើចេញពីទីតាំងអាជីវកម្មរបស់អ្នកផ្ញើដែរ។

យ៉ាងណាមិញ ទំនាក់ទំនងអេឡិចត្រូនិកត្រូវបានទទួលនៅពេលដែលទំនាក់ទំនងនោះទៅដល់អាសយដ្ឋានអេឡិចត្រូនិករបស់អ្នកទទួល។ ចំពោះពេលវេលានៃការទទួលទំនាក់ទំនងអេឡិចត្រូនិក គឺនៅពេលដែលទំនាក់ទំនងនោះ ត្រូវបានទាញយកដោយអ្នកទទួលតាមរយៈអាសយដ្ឋានដែលអ្នកទទួលបានបញ្ជាក់ជាមុន។ នៅក្នុងករណីដែល ទំនាក់ទំនងអេឡិចត្រូនិកមិនត្រូវបានផ្ដល់ឱ្យអ្នកទទួល នោះពេលវេលានៃការទទួល គឺជាពេលដែលអ្នកទទួលបានទាញយកព័ត៌មានពីអាសយដ្ឋានមួយ ហើយអ្នកទទួលបានដឹងអំពីការផ្ញើចេញទំនាក់ទំនងអេឡិចត្រូនិក ទៅកាន់អាសយដ្ឋាននោះ។ ទំនាក់ទំនងអេឡិចត្រូនិក ត្រូវបានសន្មតថា បានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

បន្ថែមពីលើការផ្ដល់សុពលភាពទៅលក្ខខណ្ឌសំខាន់ទាំង ៤ ដូចដែលមានរៀងរាប់នៅក្នុងកថាខណ្ឌខាងលើ សេចក្ដីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បានបញ្ជាក់បន្ថែមពី "អានុភាពរវាងគូភាគី" ដោយគូភាគី ពោលគឺទាំងអ្នកផ្ញើ និងអ្នកទទួល ព័ត៌មានដែលត្រូវបានទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិក ភាគីទាំងពីរ មិនអាចបដិសេធពីសុពលភាពគតិយុត្ត និងភាពអាចអនុវត្តបាននៃការបង្ហាញឆន្ទៈ និងសេចក្ដីថ្លែងផ្សេងៗរបស់ខ្លួនឡើយ។[36]

## ២.២. កិច្ចប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

នៅក្នុងពាណិជ្ជកម្មទូទៅ ប្រតិបត្តិការមានលក្ខណៈងាយស្រួល ដោយមុនដំបូង ជ្រើសយក

[36] សេចក្ដីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ២០១៦, មាត្រា ១២ "អានុភាពរវាងគូភាគី"

ទំនិញដែលខ្លួនពេញចិត្ត បង់ប្រាក់នៅបញ្ជរបង់ប្រាក់ ហើយទទួលយកទំនិញជាការស្រេច ពោលគឺអនុវត្តសកម្មភាពទាំងនោះភ្លាមៗ។ ដោយឡែក ប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក៏មានលក្ខណៈស្រដៀងគ្នាផងដែរ ប៉ុន្តែគឺយើងមិនអាចឃើញទំនិញផ្ទាល់ទេ ដរាបណាទំនិញមិនទាន់បានបញ្ជូនមកដល់ទីតាំង។ ដូចនេះ វាទាមទារឱ្យមានការផ្តល់ជំនឿទុកចិត្តខ្ពស់ពីសាធារណៈជនទាំងលើគុណភាពទំនិញ សេវាទូទាត់សងប្រាក់ និងភាពរឹងមាំនៃសេវាទូទាត់សងប្រាក់ សុវត្ថិភាពក្នុងការដឹកជញ្ជូនជាដើម។ នៅក្នុងផ្នែកនេះ នឹងធ្វើការសិក្សាអំពីប្រតិបត្តិការនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចនៅប្រទេសកម្ពុជា (២.២.១) និងកិច្ចប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅប្រទេសដទៃ (២.២.២)។

### ២.២.១. កិច្ចប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅប្រទេសកម្ពុជា

ជាទូទៅ ប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គឺមានលក្ខណៈដូចទៅនឹងការធ្វើពាណិជ្ជកម្មតាមបែបធម្មតាដែរ គឺមានលំដាប់ដូចតទៅ។ ជាដំបូង ស្វែងយល់ពីព័ត៌មាននៃទំនិញ ជ្រើសរើសទំនិញ ការបញ្ជាទិញ ទូទាត់ប្រាក់ ដឹកជញ្ជូន តែប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមិនត្រូវបានអនុវត្តទាំងស្រុងដោយផ្អែកលើប្រព័ន្ធអ៊ីនធើណេតទេ ពោលគឺ ព័ត៌មាននៃទំនិញ ជ្រើសរើសទំនិញ ការបញ្ជាទិញ ធ្វើឡើងតាមប្រព័ន្ធអ៊ីនធើណេត ដោយឡែក ការទូទាត់ប្រាក់កន្លងមកឃើញមានការអនុវត្តដោយផ្ទេរប្រាក់តាមសេវាធនាគារ ឬការប្តូរប្រាក់ យើងអាចដឹងបានថាក្រៅពីអ្នកទិញ និងអ្នកលក់ ក៏មានអន្តរការី និងក្រុមហ៊ុនដឹកជញ្ជូន និងអ្នកផ្គត់ផ្គង់ទំនិញដែលចូលរួមចំណែកក្នុងប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងទម្រង់។ ចំពោះការដឹកជញ្ជូនទំនិញវិញ មិនរាប់បញ្ចូលទំនិញប្រភេទឌីជីថលដូចជា សូហ្វវែរ បទភ្លេង MP3 វីដេអូរឿងភាគត្រូវបានអនុវត្តដូចកន្លងមក ពោលតាមសេវាដឹកជញ្ជូន។

ដូចដែលបានរៀបរាប់ពីខាងលើរួចមកហើយថា បច្ចុប្បន្ននេះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលបានគេប្រតិបត្តិនៅប្រទេសកម្ពុជា គឺមានត្រឹមជាលក្ខណៈក្រុមហ៊ុនឯកជនតូចៗ រវាងបុគ្គល និងបុគ្គលតែប៉ុណ្ណោះ។ ការបង្កើតទម្រង់ និងការរចនាគេហទំព័រលក់ដូរទំនិញទាំងនោះគឺមានលក្ខណៈស្រដៀងគ្នា ដោយមិនទាន់មានលក្ខណៈជាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពេញលេញនោះទេ គឺគ្រាន់មានលក្ខណៈជាការទិញទំនិញលើប្រព័ន្ធអនឡាញតែប៉ុណ្ណោះ។ ខាងក្រោមនេះ យើងនឹងលើកយកប្រតិបត្តិការនៃការទិញទំនិញ តាមប្រព័ន្ធអេឡិចត្រូនិកជាក់ស្តែងលើគេហទំព័រក្នុងស្រុកមួយដែលមានទម្រង់ជាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលកំពុងសិក្សាគឺពីគេហទំព័រ shop168។

### ២.២.១.១. ការជ្រើសរើសទំនិញ

ការចូលប្រើប្រាស់ទៅអាសយដ្ឋានគេហទំព័រទំនិញ ហើយពិនិត្យមើលប្រភេទទំនិញដែលចង់បាន។ ក្រោយពីប្រទះឃើញទំនិញដែលពេញចិត្តដែលមានភ្ជាប់បង្ហាញតម្លៃ ភាគរយនៃការបញ្ចុះតម្លៃ លេខកូដទំនិញ តម្លៃសម្រាប់អ្នកដែលជាសមាជិក ព័ត៌មានលម្អិតអំពីទំនិញ នៅក្បែររូបភាពទំនិញជាដើម។ លើសពីនេះ ក៏មានបង្ហាញពីរបៀប ឬនីតិវិធីនៃការជ្រើសរើសជាបន្តបន្ទាប់មុនឈានដល់ការបញ្ជាទិញ ដែលរៀបរាប់ជាលំដាប់លំដោយ ហើយអ្នកប្រើប្រាស់អាចអនុវត្តតាមការណែនាំទាំងនោះ។ គួយ៉ាងដូចជា ការជ្រើសរើសពីពណ៌ ទំហំជាដើម។

### ២.២.១.២. ការបញ្ជាទិញទំនិញ

ក្រោយពីបានមើល និងជ្រើសរើសទំនិញដែលពេញចិត្តរួចមក គេនឹងបញ្ជាទិញទំនិញដោយយកដាក់កន្រ្តកដែលបញ្ជាក់នៅលើផ្ទាំងកុំព្យូទ័រ។ នៅទីនេះ វានឹងចេញបញ្ជាក់ពីទំនិញ ដូចវិក្ក័យបត្រក្នុងការទិញទំនិញទូទៅដែរ ដូចជា ចំនួនទំនិញដែលកម្មង់ទិញ ពណ៌ ទំហំ តម្លៃរាយ តម្លៃសរុប ជាមួយនឹងពាក្យ ទូទាត់លុយ។ ក្រោយមក នីតិវិធីបន្ទាប់ នឹងតម្រូវឱ្យយើងបំពេញព័ត៌មានមួយចំនួន ថាតើអ្នកប្រើប្រាស់ជាអតិថិជនដែលជាសមាជិក ឬអតិថិជនថ្មី ។ ចំពោះអតិថិជនថ្មីនឹងតម្រូវឱ្យបង្កើតគណនី ដើម្បីប្រើវាក្នុងការទូទាត់ប្រាក់ និងងាយស្រួលក្នុងការជាវលើកក្រោយ ។ ចំពោះអតិថិជនដែលជាសមាជិកគ្រាន់តែបំពេញឈ្មោះគណនី និងលេខសម្ងាត់។ ចំណុចនេះអាចនិយាយបានថា កិច្ចសន្យាទិញ លក់បានកើតឡើងតាមប្រព័ន្ធទំនាក់ទំនងអេឡិចត្រូនិក ព្រោះជម្រើសចុងក្រោយដែលត្រូវចុច គឺការបញ្ជូនសំណើ ក្រោយពីអាននូវលក្ខខណ្ឌ និងយល់ស្របនឹងលក្ខខណ្ឌដែលបានកំណត់ដោយក្រុមហ៊ុន។

គេក៏បានបញ្ជាក់ផងដែរថា ការទំនាក់ទំនងទៅអតិថិជនក្រោយពីបានបញ្ជាទិញនឹងធ្វើតាមប្រព័ន្ធសារអេឡិចត្រូនិក ឬក៏តាមរយៈទូរសព្ទ ដែលភាគច្រើនការទំនាក់ទំនងគឺធ្វើឡើងតាមទូរសព្ទ។

### ២.២.១ ៣. ការទូទាត់ប្រាក់

ក្រោយកិច្ចសន្យាទិញ លក់បានកើតឡើងហើយ បន្ទាប់មកអ្នកទិញត្រូវមានកាតព្វកិច្ចទូទាត់ប្រាក់ដើម្បីទទួលបានទំនិញ។

នៅប្រទេសកម្ពុជា ទោះបីជាការប្រើប្រាស់សាច់ប្រាក់ក្នុងសេដ្ឋកិច្ចនៅមានកម្រិតខ្ពស់ ក៏ការអភិវឌ្ឍប្រព័ន្ធទូទាត់ត្រូវបានគេមើលឃើញថាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ក្នុងអំឡុងពេល

ជាងមួយទសវត្សនេះ ដោយក្នុងនោះរួមមានការដាក់ឱ្យ ប្រើប្រាស់ឧបករណ៍ទូទាត់ជាក្រដាស និងជាអេឡិចត្រូនិកដោយធនាគារពាណិជ្ជ និងអ្នកដំណើរការតតិយភាគី មួយចំនួន។[37]

ប័ណ្ណទូទាត់ដែលប្រើប្រាស់ទូលំទូលាយនាពេលបច្ចុប្បន្នមានបួនប្រភេទ [38] គឺ ប័ណ្ណឥណទាន[39] ប័ណ្ណឥណពន្ធ[40] ប័ណ្ណម៉ាស៊ីនទូទាត់សងប្រាក់ដោយស្វ័យប្រវត្តិ (ប័ណ្ណATM)[41] និងប័ណ្ណបង់ប្រាក់ជាមុន[42] ។

ជាក់ស្តែងក្នុងសង្គមពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបច្ចុប្បន្ន អ្នកប្រើប្រាស់អាចបង់ប្រាក់តាមអ្នកផ្តល់សេវាទូទាត់ប្រាក់ ដែលសហការជាដៃគូជាមួយ ពោលគឺទូទាត់ទៅតាមធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុណាមួយ ដែលបានកំណត់ដោយក្រុមហ៊ុនសហគ្រាសទាំងនោះ។ សព្វថ្ងៃគ្រឹះស្ថានហិរញ្ញវត្ថុ ដែលត្រូវបានដាក់ឱ្យមានការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកមាន ដូចជា អ៊ីម៉ាន់នី (e-money) ស្មាតលុយ (SmartLuy) ផេហ្គោ (PayGo) ក្រុមហ៊ុនវីង (Wing) ធនាគារអេស៊ីលីដា ធនាគារ ANZ ធនាគារ ABA ជាពិសេសគឺការ បង់ប្រាក់ផ្ទាល់ពេលទទួលទំនិញ។

ធនាគារជាតិ បានចេញនូវបទបញ្ញា ដែលណែនាំអំពីអាជ្ញាប័ណ្ណ នៃអ្នកផ្តល់សេវាទូទាត់ គឺតម្រូវឱ្យគ្រឹះស្ថានទាំងនោះ ផ្តល់សេវាអនឡាញ ក្នុងការទទួលកាតទូទាត់តាមអេឡិចត្រូនិក ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាសម្រាប់ធ្វើប្រតិបត្តិការចំនួន ៨.០០០.០០០.០០០ (ប្រាំបីពាន់លានរៀលជាសាច់ប្រាក់ (ប្រការ១៣នៃប្រកាសស្តីពីការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់) ។ មកដល់ខែធ្នូ ឆ្នាំ២០១៤ មានធនាគារពាណិជ្ជចំនួន ៣៦ ធនាគារឯកទេស ១១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៤០ ប្រតិបត្តិករឥណទានដែលបានចុះបញ្ជី ៣៨ និងមានអ្នកដំណើរការតតិយភាគីចំនួន៦ ដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាគឺក្រុមហ៊ុនវីង ក្រុមហ៊ុន វៀតថែល ក្រុមហ៊ុន

[37] ធនាគារជាតិនៃកម្ពុជា , ប្រវត្តិនៃការទូទាត់ 「https://www.nbc.org.kh/payment_systems/background_of_payment_systems.php」 (ចូលទស្សនាចុងក្រោយថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧)

[38] ធនាគារជាតិនៃកម្ពុជា , កាត 「https://www.nbc.org.kh/payment_systems/payment_cards.php」 (ចូលទស្សនាចុងក្រោយថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧)

[39] ប័ណ្ណឥណទាន ជាប័ណ្ណមួយប្រភេទដែលផ្តល់សិទ្ធិឱ្យអ្នកកាន់ប័ណ្ណប្រើប្រាស់សម្រាប់ធ្វើការទូទាត់សងលើការទិញទំនិញនិងសេវា ដោយផ្អែកលើការសន្យាសងប្រាក់វិញរបស់អ្នកកាន់ប័ណ្ណលើការទិញទំនិញនិងសេវានេះ។

[40] ប័ណ្ណឥណពន្ធ ជាប័ណ្ណមួយប្រភេទដែលអាចធ្វើការទូទាត់ជំនួសឱ្យសាច់ប្រាក់ នៅពេលទិញទំនិញ។

[41] ប័ណ្ណ ATM ជាប័ណ្ណដែលអាចប្រើបាន ជាមួយម៉ាស៊ីន ATM សម្រាប់ធ្វើប្រតិបត្តិការ ដូចជា ការមើលសមតុល្យគណនី និងការដកប្រាក់ជាដើម ប៉ុន្តែមិនអាចត្រូវបានប្រើសម្រាប់ទិញទំនិញបាននោះទេ។

[42] ប័ណ្ណបង់ប្រាក់ជាមុន ជាប័ណ្ណមួយប្រភេទដែលប្រាក់ត្រូវបានបញ្ចូលតាមរយៈការដាក់ប្រាក់ក្នុងគណនីមួយដែលភ្ជាប់ទៅនឹងប័ណ្ណនោះ ហើយចំនួនប្រាក់នោះអាចត្រូវបានចំណាយ នៅតាមហាងលក់ទំនិញដែលចូលរួមជាសមាជិក ។

អាយអឹម-អ៊ី ក្រុមហ៊ុនវេសស្ទើន យូនៀន (Western Union) ក្រុមហ៊ុនម៉ាន់នីក្រាម (Money Gram) និងក្រុមហ៊ុនផេហ្គោស៊ី។[43]

### ២.២.១.៤. ការដឹកជញ្ជូន និងការទទួលបានទំនិញ

នៅប្រទេសកម្ពុជា សេវាដឹកជញ្ជូនដែលជាប់ទាក់ទងនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកស្ទើរតែត្រូវបានអនុវត្តទាំងស្រុង ដោយក្រុមហ៊ុនឯកជន ពោលគឺ សេវាកម្មប្រៃសណីយ៍ក្នុងប្រទេសមិនបានចូលរួមក្នុងទម្រង់ពាណិជ្ជកម្មនេះទេ។ ប៉ុន្តែ ជំនួសឱ្យសេវានេះ គេឃើញមានសេវាដឹកជញ្ជូនដែលត្រូវបានប្រើប្រាស់ជាទូទៅ គឺជារបស់សហគ្រាសឯកជនបរទេស (DHL FEDEX ជាដើម)។

ជាក់ស្តែង ក្រៅពីសេវាដឹកជញ្ជូនតាមក្រុមហ៊ុនឯកជនខាងលើ សព្វថ្ងៃ មធ្យោបាយដឹកជញ្ជូនដែលឃើញមានអនុវត្ត គឺមាន ម៉ូតូឌុប ដែលនេះជាការរៀបចំរបស់អ្នកលក់ក្នុងការដឹកជញ្ជូនទៅកាន់អតិថិជនដែលមិនសូវឆ្ងាយពីទីតាំងហាងរបស់ខ្លួន។ ចំពោះ ការដឹកជញ្ជូនទៅតាមបណ្តាខេត្ត ក្រុងឆ្ងាយៗ ពីទីតាំងក្រុមហ៊ុនដែលផ្តល់ទំនិញ គេឃើញមានប្រើរថយន្តក្រុង រថយន្តតាក់ស៊ីដែលភាគច្រើន ការចំណាយទៅលើសេវានេះ គឺជាការទទួលខុសត្រូវរបស់អ្នកទិញ។ ចំពោះរយៈពេលនៃការទទួលទំនិញ គឺអាស្រ័យទៅតាមទីតាំងអាសយដ្ឋានរបស់អ្នកទិញ ពោលគឺ ចំណាយប្រហែលមួយថ្ងៃ ចំពោះខេត្ត ឬក្រុងដែលឆ្ងាយទីតាំងក្រុមហ៊ុនដែលផ្តល់ទំនិញ។ នៅពេលដែលទំនិញបានទៅដល់អ្នកទិញ នឹងបង់ប្រាក់ផ្ទាល់។

គួរបញ្ជាក់ផងដែរថា ការដឹកជញ្ជូនទំនិញមកកាន់អតិថិជនដែលបានជាវទំនិញតាមគេហទំព័រ Shop168 គឺជាការដឹកជញ្ជូនផ្ទាល់របស់Shop168។ បញ្ហាដែលកើតឡើងត្រង់ចំណុចនេះគឺការខូចទ្រង់ទ្រាយនៃទំនិញ ដែលធ្វើឱ្យទំនិញ ប្រើការមិនបាន ដែលមូលហេតុអាចមកពីការវេចខ្ចប់របស់អ្នកលក់ ឬក្រុមហ៊ុនសហគ្រាសមិនបានត្រឹមត្រូវ ឬក៏ជាការធ្វេសប្រហែសរបស់អ្នកដឹកជញ្ជូនដែលភាគច្រើនមានបញ្ហាទាក់ទងនឹងការទទួលខុសត្រូវ។

### ២.២.២. កិច្ចប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅប្រទេសដទៃ

ដោយហេតុថាប្រតិបត្តិការនៃការទិញទំនិញតាម ប្រព័ន្ធអេឡិចត្រូនិកនៅប្រទេសនានាដែលអនុវត្តពាណិជ្ជកម្មអេឡិចត្រូនិកក៏មានលក្ខណៈស្រដៀងនឹងប្រព័ន្ធដែលបានរៀបរាប់ខាងលើ

[43] ក្រុមហ៊ុនខាងលើត្រូវបានគេស្គាល់ថាគ្រឹះស្ថានមិនមែនធនាគារ ពោលគឺដើរតួនាទីជាអ្នកដំណើរការតតិយភាគី។ អ្នកដំណើរការតតិយភាគី គឺជាគ្រឹះស្ថានមួយដែលផ្តល់សិទ្ធដោយធនាគារក្នុងការផ្តល់នូវសេវាទូទាត់សងប្រាក់មួយឬច្រើនប្រភេទឱ្យទៅអតិថិជន។ ធនាគារជាតិនៃកម្ពុជាបានចេញនូវប្រកាសមួយស្តីពី អ្នកដំណើរការតតិយភាគីនៅឆ្នាំ ២០១០។

ដែរ ដូចនេះយើងគ្រាន់តែរៀបរាប់បន្ថែមទៅលើចំណុចដែលកម្ពុជាមិនបានយកមកអនុវត្តតែប៉ុណ្ណោះនៅខាងក្រោមនេះ។

**២.២.២.១. ការជ្រើសរើសទំនិញ**

ដំណាក់កាលដំបូងនេះគឺមានលក្ខណៈស្រដៀងទៅនឹងប្រតិបត្តិការ ដែលបានរៀបរាប់នៅខាងលើដែរ គឺ ក្រោយពីចូលក្នុងអាស័យដ្ឋានគេហទំព័រទំនិញរួចមក ហើយរកឃើញទំនិញដែលពេញចិត្តដែលមានភ្ជាប់បង្ហាញតម្លៃ និងព័ត៌មានច្រើនដែលទាក់ទងលម្អិតពីទំនិញរួចមក គេនឹងធ្វើការចុចរើសទំនិញនោះ*(សូមមើលឧបសម្ព័ន្ធទី៣ .១ ៖ ការរាយមុខទំនិញទូទៅនៃគេហទំព័រQoo10 របស់ប្រទេសជប៉ុន (www.qoo10.jp), ឧបសម្ព័ន្ធទី៣ .២ ៖ ក្រោយពីការជ្រើសរើស និងការបញ្ជាទិញ និង ឧបសម្ព័ន្ធទី៣ .៣ ៖ បញ្ជីរាយមុខទំនិញដែលបានជ្រើសរើស)*។

**២.២.២.២. ការបញ្ជាទិញ**

ក្រោយពីបានជ្រើសរើស និងបំពេញលក្ខខណ្ឌរួចហើយ ជាទូទៅ ការជូនដំណឹងពីស្វីការ នឹងត្រូវបញ្ជាក់តាមវិធី២ គឺទី១ តាមរយៈការបង្ហាញនៅលើផ្ទាំងកញ្ចក់កុំព្យូទ័រ និងទី២ តាមរយៈសារអេឡិចត្រូនិក។

ទី១ តាមរយៈការបង្ហាញនៅលើផ្ទាំងកញ្ចក់កុំព្យូទ័រ ក្រោយពីបានបំពេញនូវ ឈ្មោះ និងចំនួនទំនិញ អាស័យដ្ឋាន ឈ្មោះអ្នកប្រើប្រាស់ជាដើមរួចហើយ ចុចលើប៊ូតុងការបញ្ជូនសំណើបន្ទាប់មកការបញ្ជាក់ពីស្វីការទៅនឹងសំណើ នឹងបង្ហាញនៅលើផ្ទាំងកញ្ចក់កុំព្យូទ័រ។ នៅទីនេះទាំងសំណើ ទាំងការបញ្ជូនដំណឹងពីស្វីការសុទ្ធតែត្រូវបានធ្វើដោយឆ្លងការផ្ទាំងកញ្ចក់កុំព្យូទ័រ ដូចនេះ វេលាដែលការបញ្ជូនដំណឹងពីស្វីការដែលបង្ហាញនៅលើផ្ទាំងកញ្ចក់កុំព្យូទ័រត្រូវបានគិតថាជាពេលវេលានៃការបង្កើតកិច្ចសន្យា។ ដោយឡែកចំពោះសារអេឡិចត្រូនិកវិញ នឹងត្រូវបានបញ្ជូនមកអ្នកប្រើប្រាស់ក្នុងរយៈពេលដ៏ខ្លី ក្រោយពីបានបំពេញលក្ខខណ្ឌដែលបានកំណត់ទុករួចរាល់ហើយ ដើម្បីទុកជាភស្តុតាងដែលមានតម្លៃដូចជាវិក័យប័ត្រ។ វាមានសរសេរសង្ខេបដូចជា កាលបរិច្ឆេទនៃការទិញទំនិញ លេខកូដទំនិញ មធ្យោបាយដឹកជញ្ជូន ទិន្នន័យនៃការដឹកជញ្ជូន (ក្រុមហ៊ុនដឹកជញ្ជូន ពេលវេលាចេញទំនិញ ពេលវេលាមកដល់នៃទំនិញ) លក្ខខណ្ឌនិងពេលវេលានៃការទូទាត់ប្រាក់ អាស័យដ្ឋានអ្នកប្រើប្រាស់ លេខទំនិញ អ្នកទទួលការចំណាយសេវាដឹកជញ្ជូន ករណីទំនិញមានលក្ខណៈមិនប្រក្រតី(លក្ខខណ្ឌនៃការដូរ ឬលុបចោលទំនិញ) ករណីមានការភាន់ច្រឡំក្នុងការបង្ហាញឆន្ទៈក្នុងការទិញដោយសារដំណើរមិនប្រក្រតីនៃប្រព័ន្ធអ៊ីនធើណេត ការបញ្ជូនសារសំណើដោយអនិតិជនជាដើម *(សូម*

*មើលឧបសម្ព័ន្ធទី៣.៥ ៖ ការចុះឈ្មោះដើម្បីទិញទំនិញ, ឧបសម្ព័ន្ធទី៣.៦ ៖ ការបញ្ជាទិញ (ទឹកប្រាក់ដែលត្រូវបង់), ឧបសម្ព័ន្ធទី៣.៧ ៖ ការបញ្ជាទិញ (ព័ត៌មានពាក់ព័ន្ធនឹងការដឹកជញ្ជូន), ឧបសម្ព័ន្ធទី៣.៨ ៖ ការបញ្ជាទិញ (ការជ្រើសរើសប្រភេទនៃការទូទាត់ប្រាក់) និង ឧបសម្ព័ន្ធទី៣.៩ ៖ ព័ត៌មានពាក់ព័ន្ធនឹងការដឹកជញ្ជូន)* ។

### ២.២.២.៣. ការទូទាត់ប្រាក់

ការទូទាត់ប្រាក់នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានមធ្យោបាយជាច្រើនដែលត្រូវបានអនុវត្តពីដើមមកដូចជា ការផ្ទេរប្រាក់តាមធនាគារ ការបង់ប្រាក់ពេលទទួលបានទំនិញ ហើយបច្ចុប្បន្នក៏មានវិធីជាលុយអេឡិចត្រូនិក ប័ណ្ណឥណទាន ការផ្ទេរប្រាក់តាមប៉ុស្តិ៍ប្រៃសនីយ កាតក្រេឌីត ការទូទាត់តាមម៉ាស៊ីនដែលដាក់នៅក្នុងហាងទំនិញ[44] (នៅប្រទេសជប៉ុន)។ ជាទូទៅការទូទាត់ប្រាក់ នឹងត្រូវគិតថ្លៃសេវាទទួលប្រាក់ផងដែរ *(សូមមើលឧបសម្ព័ន្ធទី៣.១០ ៖ ការណែនាំអំពីការទូទាត់ប្រាក់)* ។

### ២.២.២.៤. ការដឹកជញ្ជូន និងការទទួលបានទំនិញ

សេវាដឹកជញ្ជូន ត្រូវបានចូលរួមយ៉ាងសកម្មពី ក្រុមហ៊ុនឯកជន ។ ក្រោយពីបានប្រគល់ទំនិញទៅឱ្យអ្នកដឹកជញ្ជូនពីអ្នកលក់រួចហើយ ដំណឹងពេលវេលានៃការមកដល់នៃទំនិញ ការមកដល់យឺតយ៉ាវនៃទំនិញ អតិថិជននឹងទាក់ទងដោយផ្ទាល់ទៅក្រុមហ៊ុនដឹកជញ្ជូន។ នៅក្នុងនោះលក្ខខណ្ឌផ្សេងៗដែលបានកំណត់របស់ក្រុមហ៊ុនត្រូវបានអនុវត្តមានដូចជា ការខូចខាតនៃទំនិញ ការដឹកជញ្ជូនទំនិញមានការយឺតយ៉ាវ ករណីគ្មានអ្នកទទួលទំនិញពេលទំនិញមកដល់ជាដើម។

គួរបញ្ជាក់ផងដែរថា រយៈពេលនៃដំណើរដឹកជញ្ជូនអតិថិជនអាចតាមដាននៅលើគេហទំព័ររបស់ក្រុមហ៊ុនដឹកជញ្ជូន ដោយដំណាក់កាលនីមួយៗ នៃការដឹកជញ្ជូនបានបញ្ជាក់យ៉ាងច្បាស់លាស់ ពេលវេលាជាក់លាក់នៃការមកដល់នៃទំនិញក៏ត្រូវបានបង្ហាញ *(សូមមើលឧបសម្ព័ន្ធទី៣.១១ ៖ ការចូលមើលព័ត៌មាននៃការបញ្ជាទិញ និងឧបសម្ព័ន្ធទី៣.១២ ៖ សារអេឡិចត្រូនិកបញ្ជាក់ពីការបញ្ជាទិញពីក្រុមហ៊ុន Qoo10)* ។

[44] Mastui Shigenori, Suzuki Hidemi, Yamaguchi Itsuko,「インターネット法 (Internet Law)」,有斐閣、2015、ទំព័រ១៩៩

# ជំពូកទី៣

# ឱកាស និងបញ្ហាប្រឈមនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនត្រឹមតែបង្កើតឱកាសដល់ការរីកលូតលាស់នៃក្រុមហ៊ុន សហគ្រាស ក្នុងស្រុក និងអន្តរជាតិប៉ុណ្ណោះទេ ក៏ជួយជំរុញដល់ការអភិវឌ្ឍនៃសេដ្ឋកិច្ចជាតិមួយកម្រិតធំផងដែរ។ ប៉ុន្តែ ទន្ទឹមនឹងនេះ ភាពវិវឌ្ឍមិនចេះចប់នៃបច្ចេកវិទ្យាដែលជាផ្នែកយ៉ាងសំខាន់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក៏បង្កជាផលវិបាក ឬបញ្ហានានា ដែលចាំបាច់ទាមទារឱ្យមានការចូលរួម និងយកចិត្តទុកដាក់ពីគ្រប់មជ្ឈដ្ឋាន។ ឱកាសនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នឹងត្រូវយកមកសិក្សាដោយផ្ដោតទៅលើពាណិជ្ជករ អតិថិជន និងសង្គមជាតិ (៣.១) ហើយក៏បញ្ជាក់ពីបញ្ហា ដែលអាចប្រឈមរបស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកផងដែរ (៣.២)។

## ៣.១. ឱកាសនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

យោងទៅតាមគេហទំព័រ Tutorialpoint.com ដែលជាគេហទំព័រដែលផ្ដល់នូវការអប់រំតាមប្រព័ន្ធអនឡាញទាក់ទងនឹង វិទ្យាសាស្ត្រកុំព្យូទ័រ និងព័ត៌មានបច្ចេកវិទ្យា ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បានផ្ដល់នូវអត្ថប្រយោជន៍ជាច្រើន ដែលអត្ថប្រយោជន៍ទាំងនោះត្រូវបានគេបែងចែកជា ៣ ផ្នែកផ្សេងគ្នា គឺអត្ថប្រយោជន៍សម្រាប់ពាណិជ្ជករ អតិថិជន និងសង្គមជាតិ។

❖ ពាណិជ្ជករ

តាមរយៈការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ពាណិជ្ជករអាចពង្រីកទីផ្សាររបស់ខ្លួនទៅដល់ទីផ្សារទាំងថ្នាក់ជាតិ និងអន្តរជាតិ ដោយចំណាយដើមទុនបន្តិចបន្តួចប៉ុណ្ណោះ ហើយពាណិជ្ជករអាចទាក់ទាញអតិថិជនច្រើនជាងមុន ស្វែងរកអ្នកផ្គត់ផ្គង់ដែលសមស្របបំផុត និងអាចបង្កើតដៃគូពាណិជ្ជកម្មនៅជុំវិញពិភពលោក។

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ៖

- ជួយឱ្យពាណិជ្ជករកាត់បន្ថយការចំណាយទៅលើ ដំណើរការនៃការបង្កើត ចែកចាយ ទាញយក និងគ្រប់គ្រងព័ត៌មាននៅលើក្រដាស តាមរយៈការប្រើប្រាស់ព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិក
- ធ្វើឱ្យយីហោ របស់ក្រុមហ៊ុន មានភាពប្រសើរឡើង
- ធ្វើឱ្យជំនួញ ដំណើរការទៅដោយសាមញ្ញ មានភាពរហ័ស និងប្រកបដោយប្រសិទ្ធិផល

- បង្កើនផលិតផលរបស់ក្រុមហ៊ុន ដោយពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកគាំទ្រនូវការគ្រប់គ្រងមួយ ដែលធ្វើឡើងដោយឆ្លើយតបនឹងការបញ្ជាទិញរបស់អតិថិជន ហើយប្រើប្រាស់ពេលវេលា ដែលមានលក្ខណៈសមរម្យ។

❖ អតិថិជន

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ផ្តល់នូវការបម្រើសេវាកម្ម ២៤ ម៉ោង ក្នុងមួយថ្ងៃ ហើយចំនួន ៧ ថ្ងៃ ក្នុងមួយសប្តាហ៍ ដោយអតិថិជន អាចធ្វើប្រតិបត្តិការ ដើម្បីទទួលបានផលិតផល ឬ ការឆ្លើយតបចំពោះសំនួរអ្វីមួយពាក់ព័ន្ធនឹងផលិតផល ឬ សេវា ដែលផ្គត់ផ្គង់ដោយក្រុមហ៊ុន ឬ សហគ្រាសនោះ ដែលនៅគ្រប់ទីកន្លែង និងនៅគ្រប់ពេលវេលា ទោះបីជាអតិថិជននោះមានទីតាំងនៅទីណាក៏ដោយ។

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ផ្តល់ឱ្យអតិថិជននូវជម្រើសច្រើន ដែលអាចឱ្យអតិថិជនធ្វើការប្រៀបធៀប និងជ្រើសរើសយកជម្រើសដែលល្អប្រសើរ និងមានតម្លៃថោកសម្រាប់ពួកគាត់ ការដឹកជញ្ជូនទំនិញដែលមានភាពរហ័ស។ អតិថិជន ក៏អាចចូលទៅមើលព័ត៌មានទាក់ទងនឹងផលិតផលណាមួយ ដោយមិនចំណាយពេលយូរ ព្រមទាំងមើលមតិយោបល់របស់អតិថិជនដទៃទៀត ហើយថាតើអតិថិជនដទៃទាំងនោះចង់បានផលិតផលណាមួយ មុននឹងធ្វើការសម្រេចទិញផលិតផល ។ ពាណិជ្ជកម្មតាមបែបទំនើបនេះ ក៏បង្កលក្ខណៈឱ្យមានការប្រកួតប្រជែងរវាងពាណិជ្ជករ ដែលកត្តានេះនឹងនាំឱ្យមានការបញ្ចុះតម្លៃច្រើន ដើម្បីទាក់ទាញអតិថិជន។

❖ សង្គមជាតិ

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នឹងធ្វើឱ្យអតិថិជន មិនចាំបាច់ធ្វើដំណើរទៅហាងលក់ទំនិញ ហេតុនេះការកកស្ទះចរាចរណ៍ និងការបំពុលខ្យល់អាកាសនឹងត្រូវបានកាត់បន្ថយ។ រាជរដ្ឋាភិបាល ក៏អាចប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក ក្នុងការបម្រើសេវាសាធារណៈដល់ប្រជាពលរដ្ឋ ដូចជាសេវាសុខាភិបាល ការអប់រំ និងសេវាសង្គមផ្សេងៗ ដែលកត្តានេះ នឹងការបន្ថយការចំណាយ និងធ្វើឱ្យការបម្រើសេវានោះមានលក្ខណៈប្រសើរឡើង។

ជារួមមក ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បានផ្តល់គុណសម្បត្តិជាច្រើន ទៅដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដែលក្នុងនោះរួមមានទាំងពាណិជ្ជករ អតិថិជន និងរាជរដ្ឋាភិបាលពោលគឺសង្គមជាតិទាំងមូល។

## ៣.២. បញ្ហាដែលអាចប្រឈមរបស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ស្របពេលនឹងការរីកលូតលាស់ដ៏សម្បើម នៃប្រព័ន្ធអ៊ីនធើណេតទៅតាមសម័យកាលបច្ចុ-

ប្បន្ន និងអនាគត បទបញ្ញត្តិច្បាប់ដែលបានតាក់តែងកន្លងមក ត្រូវបានគេបារម្ភថា តើត្រូវសម្រប ឬបកស្រាយសម្រួលយ៉ាងដូចម្ដេច ដើម្បីឆ្លើយតបនឹងបញ្ហាដែលធ្លាប់កើតឡើង ពោលគឺគេអាចហៅថាជាបញ្ហាច្បាប់មួយផងដែរ។ ឧទាហរណ៍ ក្រមរដ្ឋប្បវេណី ក៏ដូចជាច្បាប់ការពារអ្នកប្រើប្រាស់[45] ដែលស្ថិតនៅក្នុងផ្នែកនីតិឯកជន។

ទាក់ទិននឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងប្រទេសដទៃ ពិសេសគឺប្រទេសជប៉ុនគេឃើញមានបញ្ហាច្រើនទាក់ទងនឹងព័ត៌មានពាណិជ្ជកម្មរបស់បុគ្គល ការការពារអ្នកប្រើប្រាស់ ការទទួលស្គាល់តាមប្រព័ន្ធអេឡិចត្រូនិក ការការពារនៃដំណើរការមិនត្រឹមត្រូវ សិទ្ធិអ្នកនិពន្ធ ដែលភាគច្រើនកើតក្នុងការទូទាត់ប្រាក់នៅហាងទំនិញ សេវាដឹកជញ្ជូនទំនិញ ការដេញថ្លៃ។ ជាពិសេសផងដែរ គេឃើញមានច្បាប់ និងបទដ្ឋានគតិយុត្តដែលត្រូវបានបញ្ញត្តិឡើងជាច្រើន ដែលជាប់ទាក់ទងនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដូចជា ច្បាប់ស្ដីពីកិច្ចសន្យាអេឡិចត្រូនិក (ឆ្នាំ២០០១) ច្បាប់ស្ដីពីហត្ថលេខាអេឡិចត្រូនិក (ឆ្នាំ២០០០) ច្បាប់ស្ដីពីឯកសារអេឡិចត្រូនិក (ឆ្នាំ២០០៤) ច្បាប់ស្ដីពីការការពារព័ត៌មានបុគ្គលឯកជន (ឆ្នាំ២០០៣) ជាអាទិ៍។

ក្រឡេកមកប្រទេសកម្ពុជាវិញ ការរីកដូចផ្សិតនូវគ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារជាច្រើនបាននឹងកំពុងសហការយ៉ាងសកម្មជាមួយនឹងរាជរដ្ឋាភិបាល ក្នុងការសម្រួលរបៀបរបបនៃការទូទាត់ប្រាក់ និងការផ្ទេរប្រាក់ ដោយបង្កើតគណនី ហើយនិងការទូទាត់តាមរយៈទូរសព្ទក៏ជាប្រព័ន្ធមួយដ៏ថ្មី ងាយស្រួល និងពេញនិយម និងជួយជម្រុញអភិវឌ្ឍសេដ្ឋកិច្ចជាតិទៅមុខយ៉ាងរហ័សផងដែរ។ ប៉ុន្តែ ដោយប្រទេសកម្ពុជា ជាប្រទេសកំពុងកិវឌ្ឍដែលទើបចាប់ផ្ដើមកើតនូវពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងអំឡុង១ទសវត្សនេះ ហានិភ័យទាក់ទងនឹងវិស័យនានា អាចនឹងកើតឡើងស្របពេលដំណើរការនេះមិនទាន់បានចូលរួមពេញលេញពីសំណាក់រដ្ឋាភិបាលនៅឡើយ។ នៅក្នុងផ្នែកនេះ បញ្ហាប្រឈមរបស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា (៣.២.១) និងការសិក្សាទៅលើបញ្ហា និងរកដំណោះស្រាយដោយសិក្សាពីប្រទេសដទៃ(៣.២.២)។

### ៣.២.១. បញ្ហាប្រឈមរបស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា

ខណៈពេលដែលប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលមួយ ដែលទំនើបកម្មនៃបច្ចេកវិទ្យា បាន និងកំពុងរុញច្រាននាវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឱ្យមានសន្ទុះទៅមុខនោះ ហើយដែលរាជរដ្ឋាភិបាល កំពុងតែរៀបចំសេចក្ដីព្រាងច្បាប់ដើម្បីគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះ បញ្ហាមួយចំនួន ត្រូវបានមជ្ឈដ្ឋានជាច្រើនមើលឃើញថាជាឧបសគ្គ ដែល

[45] ច្បាប់ការពារអ្នកប្រើប្រាស់នៅប្រទេសកម្ពុជា ស្ថិតក្នុងដំណាក់កាលពង្រាងនៅឡើយ ដែលបច្ចុប្បន្នកំពុងនៅក្រោមការពិភាក្សានៅក្រសួងពាណិជ្ជកម្ម

រារាំងដំណើរការរលូននៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា និងទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធដើម្បីចូលរួមដោះស្រាយបញ្ហាទាំងនោះ។

ជាក់ស្តែង សភាពាណិជ្ជកម្មចក្រភពអង់គ្លេស និងសភាពាណិជ្ជកម្មអឺរ៉ុបប្រចាំនៅកម្ពុជា បានរៀបចំឱ្យមានការប្រជុំមួយស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងទីផ្សាររួមរបស់អាស៊ានលើកទី ១ (eCommerce in ASEAN Emerging Market I) នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០១៥។ នៅក្នុងកិច្ចប្រជុំនោះផងដែរ បញ្ហាមួយចំនួនពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានលើកឡើង ដោយបញ្ហាទាំងនោះត្រូវបានបែងចែកជាបីផ្នែកផ្សេងៗគ្នា គឺ កត្តាបច្ចេកទេស និងប្រតិបត្តិការ កត្តាសេដ្ឋកិច្ចសង្គម និងវប្បធម៌ និងកត្តាច្បាប់ និងរដ្ឋាភិបាល។[46]

❖ កត្តាបច្ចេកទេស និងប្រតិបត្តិការ

- ទូរគមនាគមន៍ ឬ ប្រព័ន្ធអ៊ីនធើណេត
  + អ៊ីនធើណេតមានល្បឿនយឺត
  + ការប្រើប្រាស់អ៊ីនធើណេតមានតម្លៃថ្លៃ
  + មិនមានការផ្គត់ផ្គង់សេវាអ៊ីនធើណេតក្នុងស្រុក
  + ការព្រួយបារម្ភពាក់ព័ន្ធនឹងអាជ្ញាបណ្ណ និងលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រង
  + តម្រូវការនៃគេហទំព័ររបស់ពាណិជ្ជកម្មតាមប្រព័ន្ធអ៊ីនធើណេត នៅក្នុងទូរសព្ទដៃ
- សេវាហិរញ្ញវត្ថុ និងមធ្យោបាយទូទាត់ប្រាក់
  + មិនមានមធ្យោបាយទូទាត់ប្រាក់គ្រប់គ្រាន់
  + អ្នកទិញមិនមានកាតធនាគារគ្រប់គ្រាន់ ដោយពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបច្ចុប្បន្នប្រើប្រាស់វិធីសាស្ត្រ ប្រគល់សាច់ប្រាក់នៅពេលបានទទួលទំនិញ (Cash-on-Delivery)
  + ឥទ្ធិពលនៃការប្រើប្រាស់ប្រាក់ដុល្លារ (លក្ខខណ្ឌក្នុងការប្រើប្រាស់ប្រាក់រៀល)
- សេវាដឹកជញ្ជូន
  + កង្វះខាតនៃប្រព័ន្ធដឹកជញ្ជូនទំនិញទៅឱ្យអតិថិជន
  + បញ្ហានៃការបញ្ជូនទំនិញត្រឡប់ទៅវិញ ប្រសិនបើអតិថិជនមិនពេញចិត្ត

[46] ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៅក្នុងទីផ្សារដែលកំពុងអភិវឌ្ឍរបស់អាស៊ាន, ២៦ តុលា ២០១៥

❖ កត្តាសេដ្ឋកិច្ចសង្គម និងវប្បធម៌

+ ទំនុកចិត្តនៅក្នុងការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ជាជាងការប្រើប្រាស់សាច់ប្រាក់
+ ការដោះស្រាយវិវាទ
+ ធនធានមនុស្សសម្រាប់ធ្វើទំនាក់ទំនងពាណិជ្ជកម្ម
+ ការយល់ដឹងអំពីរបៀបនៃការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក

❖ កត្តាច្បាប់ និងរដ្ឋាភិបាល

+ ការប្រែប្រួលយ៉ាងឆាប់រហ័ស ទៅរកពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អាចជះឥទ្ធិពលដល់ការប្រកួតប្រជែង
+ ការផ្សព្វផ្សាយពីច្បាប់ថ្មី ដែលគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
+ សេចក្តីណែនាំពីច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់
+ ការប្តេជ្ញារបស់រាជរដ្ឋាភិបាលក្នុងការវិនិយោគលើបច្ចេកវិជ្ជាព័ត៌មានវិទ្យា

ដោយបានសិក្សាស្រាវជ្រាវ និងពើបប្រទះនឹងបញ្ហាប្រឈមជាច្រើនសម្រាប់ដំណើរការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការសិក្សានឹងសាកល្បងសិក្សាលម្អិតទៅលើបញ្ហាប្រឈមចំនួន ពីរ ពីក្នុងចំណោមបញ្ហាប្រឈម ដែលបានរៀបរាប់ខាងលើ គឺ ការទូទាត់ និងផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក និង ការដោះស្រាយវិវាទ ហើយព្យាយាមសិក្សាទៅលើករណីរបស់ប្រទេសដទៃ ដើម្បីស្វែងរកដំណោះស្រាយសមស្របមួយ សម្រាប់អនុវត្តនៅក្នុងករណីប្រទេសកម្ពុជា ដូចដែលបញ្ជាក់នៅក្នុងកថាខណ្ឌខាងក្រោមនេះ។

### ៣.២.២. ការសិក្សាទៅលើបញ្ហា និងរកដំណោះស្រាយដោយសិក្សាពីប្រទេសដទៃ

#### ៣.២.២.១. ការទូទាត់ និងការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ( e-payment )

ជាការពិតណាស់ នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការទូទាត់ជាសាច់ប្រាក់ផ្ទាល់ មិនត្រូវបានគេនិយមប្រើទេ ពីព្រោះវាត្រូវចំណាយពេលច្រើន និងប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ (ចោរកម្មជាដើម) ។ ការទូទាត់ និងការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក (e-payment) និងយន្តការដោះស្រាយបញ្ហា គឺជា ខ្សែសង្វាក់ដ៏សំខាន់មួយនៅក្នុងការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ដូចនេះ ប្រព័ន្ធនៃការទូទាត់ប្រាក់និងការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ក្នុងការទិញទំនិញត្រូវគេគិតថាជាការជ្រើសរើសដ៏ត្រឹមត្រូវមួយ។

ជាទូទៅ ជំនឿចិត្ត និងសុវត្ថិភាពតាមប្រព័ន្ធអ៊ីនធើណេត គឺជាធាតុមួយដ៏សំខាន់នៅក្នុងដំណើរប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ គួរបញ្ជាក់ផងដែរថា ឧស្សាហកម្មនៃការ

ទូទាត់ប្រាក់ និងការប្រើប្រាស់កាតនៅប្រទេសកម្ពុជា ដែលរាប់បញ្ចូលកាតក្រេឌីត គឺមានការរីកលូតលាស់ដ៏គួរឱ្យកត់សម្គាល់ ដែលបានបង្ហាញថាកម្រិតតួលេខបានឡើងដល់ ២៦.៣១% ហើយការប្រើប្រាស់កាតបានកើនឡើងចំនួន ៩៦៩០៩៧ នៅក្នុងឆ្នាំ២០០៩ ដល់១.២លាននៅចុងឆ្នាំ ២០១៣។

ក. <u>បញ្ហា</u>

នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បញ្ហាជាច្រើនបានកើតឡើងទាក់ទងនឹងវិស័យ និងសេវាផ្សេងៗ ដែលនាំឱ្យច្បាប់និងបទដ្ឋានជាច្រើនត្រូវបានបង្កើតឡើង ដើម្បីធានាដំណើរការលូតលាស់នៃពាណិជ្ជកម្មនៅក្នុងទម្រង់នោះ ហើយជាពិសេសធានាដល់អ្នកប្រើប្រាស់។ នៅក្នុងចំណុចនេះ យើងនឹងលើកយកបញ្ហា២តែប៉ុណ្ណោះមកសិក្សា គឺទាក់ទងនឹងការទូទាត់ប្រាក់តាមសេវាដឹកជញ្ជូន និងការទូទាត់ប្រាក់តាមរយៈកាតឬប័ណ្ណ ព្រោះគិតថាប្រជាជនយើងភាគច្រើននៅតែជ្រើសរើសបង់ប្រាក់ពេលទទួលបានទំនិញ ហើយស្របពេលនេះការប្រើប្រាស់កាតក្នុងការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក បានកើនឡើងគួរឱ្យកត់សម្គាល់ ដែលជាហេតុអាចនាំមានបញ្ហាកើតឡើងទាក់ទងនឹងសេវានេះ។

❖ ការបង់លុយតាមសេវាដឹកជញ្ជូន

ការទូទាត់ និងការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក គឺធ្វើឡើងនៅមុន ឬក្រោយពេលទទួលបានទំនិញ តែភាគច្រើនធ្វើឡើងនៅមុនពេលទទួលបានទំនិញ។ ដែលជាហេតុពិបាកផ្តល់ជំនឿចិត្ត និងធានាថាទំនិញនោះដូចនឹងអ្វីដែលបានរំពឹងទុកដែរឬទេ(សម្រាប់អតិថិជន) ហើយអ្នកលក់ក៏មិនអាចធានា ថាអតិថិជននឹងបង់ប្រាក់តាមកាតព្វកិច្ចដែរឬទេ។ ដូចនេះ ការប្រគល់ប្រាក់ស្របពេលទំនិញមកដល់ដៃ គឺជាវិធីមួយដែលគេនៅអនុវត្តច្រើនរៀងមក ដោយនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការទូទាត់ប្រាក់នឹងធ្វើតាមអ្នកដឹកជញ្ជូន។

នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សេវាកម្មបង់លុយពេលទទួលទំនិញ ត្រូវបានគេអនុវត្តច្រើនមកដែររហូតមកដល់បច្ចុប្បន្ន។ នៅក្នុង សេវាកម្មបង់លុយពេលទទួលទំនិញ អ្នកលក់បានប្រគល់សិទ្ធិក្នុងការទាមទារការទូទាត់ទៅឱ្យអ្នកដឹកជញ្ជូន។ ពោលគឺ អ្នកលក់ បានប្រគល់សិទ្ធិឱ្យអ្នកដឹកជញ្ជូនទាំងការដឹកជញ្ជូនទំនិញ និងការទទួលយកប្រាក់ថ្លៃទំនិញ ដោយតំណាងខ្លួន ហើយក្រុមហ៊ុនដឹកជញ្ជូន ក៏បានទទួលការប្រគល់នោះ នេះបានន័យថាកិច្ចសន្យាបានកើតឡើងរវាងភាគីទាំង២។ អ្នកដឹកជញ្ជូននឹងប្រគល់ទៅឱ្យប្រាក់ដែលទទួលបានពីអ្នកទិញ ទៅអ្នកលក់នៅពេលក្រោយតាមរយៈផ្ទេរតាមធនាគារជាដើម។ តែករណីដែលក្រុមហ៊ុនដឹកជញ្ជូនមិនអាចដំណើរការបានតទៅមុខទៀតដោយប្រការណាមួយ ក្រោយពីបានទទួលលុយពីអ្នកទិញ នោះអ្នកទទួល

ខុសត្រូវគឺជាអ្នកលក់ ពោលគឺអ្នកលក់អាចនឹងមិនទទួលបានអ្វីទាំងអស់។ ហើយទោះបីជាក្នុងករណីដែលអ្នកទិញ បានរកឃើញថា ទំនិញ ឬសេវាដែលទទួលបានមានវិការៈ ក៏មិនអាចធ្វើការទាមទារឱ្យសងលុយត្រឡប់មកវិញតាមកិច្ចសន្យាទិញលក់ទៅកាន់អ្នកដឹកជញ្ជូនបានទេ គឺទាមទារបានតែចំពោះអ្នកលក់តែប៉ុណ្ណោះ។

បញ្ហានេះ ក្នុងប្រទេសជប៉ុន គេមិនទាន់ឃើញមានច្បាប់ដែលអាចយកមកគ្រប់គ្រងបាននៅឡើយទេ ពោលគឺជាគោលការណ៍ ច្បាប់ស្តីពីធនាគារមិនអាចយកបកស្រាយបានទេ ព្រោះវាផ្ទុយនឹងច្បាប់ខាងលើដោយការទទួលយកទូទាត់នេះ មិនមានត្រូវបានផ្តល់អាជ្ញាប័ណ្ណដែលពាក់ព័ន្ធនឹងការងារធនាគារណាមួយទេ។

❖ ការលួចព័ត៌មានតាមរយៈកាត ឬប័ណ្ណ

នៅពេលដែលទូទាត់ប្រាក់ទៅតាមប្រព័ន្ធធនាគារ ព័ត៌មានបុគ្គល (លេខអត្តសញ្ញាណប័ណ្ណ លេខកូដសំងាត់ធនាគារ) នឹងត្រូវបានគេលួច ពោលគឺបុគ្គលដែលគ្មានសិទ្ធិមួយចំនួន បានប្រើសកម្មភាពខុសច្បាប់ដើម្បីចូលទៅប្រើប្រាស់ តើហានិភ័យមួយនេះជាការទទួលខុសត្រូវរបស់ភាគីខាងធនាគារ ឬជារបស់អ្នកប្រើប្រាស់។ ដូចនេះ គេចង់មានដំណោះស្រាយ ដែលផ្តល់ផលប្រយោជន៍ និងផ្តល់ការការពារច្រើនទៅលើអ្នកប្រើប្រាស់។

ខ. <u>ដំណោះស្រាយ</u>

នៅប្រទេសជប៉ុន ទាក់ទិននឹងបញ្ហាទី១ គេគិតថាបើមើលជាលក្ខណៈច្បាប់ ការទូទាត់ប្រាក់ពីអ្នកទិញបែបនេះគឺដោយសារតែ អ្នកដឹកជញ្ជូនគឺតំណាងឱ្យអ្នកលក់ ប៉ុន្តែ វាមិនមែនជាធាតុសំខាន់ទេ ពោលគឺជាក់ស្តែង បើមានហានិភ័យណាកើតឡើងវាជាការទទួលខុសត្រូវរបស់អ្នកលក់។ ចំពោះបញ្ហានេះ ក៏ធ្លាប់មានការចេញសេចក្តីសម្រេចថាវាជាសេវាដែលខុសនឹងច្បាប់។ តែដោយយោងតាមច្បាប់ដែលពាក់ព័ន្ធនឹងការទូទាត់មូលនិធិ មានមាត្រាដែលចង្អុលថា ប្រសិនបើទទួលការចុះឈ្មោះពីគណៈរដ្ឋមន្ត្រី ដែលទាក់ទងនឹងការងារផ្ទេរមូលនិធិ នោះអាចប្រកបរបរនេះបានដោយស្របតាមច្បាប់។ ជាក់ស្តែង រាល់ធនាគារ ឬគ្រឹះស្ថាន ហិរញ្ញវត្ថុទាំងអស់ដែលផ្តល់សេវាទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកត្រូវតែយល់ព្រម និងទទួលស្គាល់ពីភ្នាក់ងាររដ្ឋ ពោលគឺធនាគារជាតិ ។ ហើយចំពោះការងារដឹកជញ្ជូន និងការទូទាត់ប្រាក់ជាសេវាពីរផ្សេងគ្នាដែលទាមទារអ្នកផ្តល់សេវាទាំងអស់ត្រូវអនុវត្តឱ្យបានត្រឹមត្រូវ។

ជាការពិតណាស់ ការបញ្ជាក់ពីអ្នកកាន់កាតឬប័ណ្ណពិតប្រាកដ គឺខាងក្រុមហ៊ុនត្រូវអនុវត្តឱ្យច្បាស់ ដូចជាបញ្ជាក់ពីលេខកាត ពេលវេលានៃការផុតកំណត់នៃកាត ការបញ្ចូលលេខសម្ងាត់ ការជូនដំណឹងពីការបញ្ជាក់លទ្ធផលនៃអ្នកកាន់ពិតប្រាកដជាដើម ។

បន្ថែមពីនេះ វិធីនៃការដោះស្រាយបញ្ហាក្នុងការការពារអ្នកប្រើប្រាស់ ត្រូវបានគេលើកឡើងដូចខាងក្រោម:[47]

- បង្កើតយន្តការដោះស្រាយបញ្ហាទូទាត់ប្រាក់ដែលងាយស្រួលប្រើប្រាស់សម្រាប់អតិថិជន និងផ្តល់នូវ សុវត្ថិភាពក្នុងកម្រិតសមស្របមួយដែលអាចជឿទុកចិត្តបាន
- ធនាគារគួរធានាថាអ្នកប្រើប្រាស់មានលទ្ធភាពទទួលព័ត៌មានពីរបៀបនៃការទូទាត់ប្រាក់
- សុវត្ថិភាពនៃរបៀបនៃការទូទាត់ប្រាក់ទាំងនោះ ត្រូវធ្វើឱ្យច្បាស់លាស់ និងងាយយល់ ដើម្បីឱ្យអ្នកប្រើប្រាស់អាចវិភាគពីកម្រិតគ្រោះថ្នាក់និងការពារទុកជាមុនបាន
- របៀបនៃការអនុវត្តវិធីទូទាត់ប្រាក់ដោយមានប្រសិទ្ធិភាព
- ធនាគារគួរតែអនុវត្តវិធានការសមហេតុផល ដើម្បីធ្វើបច្ចុប្បន្នភាពនៃយន្តការទូទាត់ប្រាក់ដែលពួកគេប្រើ ដើម្បីធានាថាកម្រិតនៃការផ្តល់សុខសុវត្ថិភាពត្រូវរក្សានៅកម្រិតសមស្របតាមពេលវេលា។

លើសពីនេះ ភាគីគួរតែត្រូវបានជម្រុញឱ្យប្រើប្រព័ន្ធអាជ្ញាកណ្តាលក្នុងការដោះស្រាយជម្លោះទាក់ទងនឹងការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។ ការទូទាត់តាមកិច្ចសន្យា (Contractual payment settlement) ក៏ត្រូវចង្អុលបង្ហាញថាជាវិធីមួយដ៏សមស្របក្នុងការធានាសុវត្ថិភាពនៃការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកដែរ។

### ៣.២.២.២. ការដោះស្រាយវិវាទ

គួរកត់សម្គាល់ផងដែរថា កន្លងមកក្រសួងពាណិជ្ជកម្ម មិនដែលទទួលបានព័ត៌មានពាក់ព័ន្ធនឹងបញ្ហាវិវាទ ដែលកើតចេញពីទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះទេ។[48] ម្យ៉ាងទៀត សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក៏មិនមានបញ្ញត្តិច្បាស់លាស់ដែលចង្អុលបង្ហាញពីនីតិវិធីដោះស្រាយវិវាទ ប្រសិនបើមានវិវាទកើតឡើងនោះដែរ។ ទាក់ទងនឹង

[47] Proposed New Zealand Model Code for Consumer Protection in Electronic Commerce

[48] អ៊ឹម កុយ (អនុប្រធាននាយកដ្ឋាននីតិកម្មនៃក្រសួងពាណិជ្ជកម្ម), បទសម្ភាសន៍ដោយ យ៉េន វណ្ណីដា និង អ៊ឹង ហ៊ុយគង់, ៣១ ឧសភា ២០១៧

បញ្ហាវិវាទនេះផងដែរ អ្នកជំនាញរបស់ក្រសួងពាណិជ្ជកម្ម ដែលធ្វើការពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក រំពឹងថាបញ្ហាជាច្រើនដែលកើតឡើងចំពោះអ្នកប្រើប្រាស់នៅក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះ នឹងត្រូវបានដោះស្រាយដោយ ច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ ដែលបច្ចុប្បន្នសេចក្តីព្រាងច្បាប់នេះ ស្ថិតនៅដំណាក់កាលត្រួតពិនិត្យរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ ទោះជាយ៉ាងណាក៏ដោយ អ្នកជំនាញដដែល ក៏បានលើកឡើងថា សេចក្តីព្រាងច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ មិនបានបង្កើតឱ្យមានស្ថាប័ន ឬ យន្តការដោះស្រាយវិវាទណាមួយថ្មី សម្រាប់ដោះស្រាយវិវាទ ដែលនឹងកើតមាននោះដែរ ពោលគឺរាល់វិវាទទាំងអស់នឹងត្រូវដោះស្រាយដោយស្ថាប័ន ដែលមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទបច្ចុប្បន្ន ដែលមានដូចជាតុលាការមជ្ឈត្តការពាណិជ្ជកម្មកម្ពុជា ជាដើម។

ការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ មានគុណវិបត្តិមួយចំនួន ដូចជាការចំណាយច្រើនខាងផ្នែកហិរញ្ញវត្ថុ ក៏ដូចជាពេលវេលា។ ម្យ៉ាងទៀត ភាគីត្រូវត្រៀមលក្ខណៈច្រើន ជាពិសេសផ្នែកច្បាប់ និងឯកសារពាក់ព័ន្ធ ដើម្បីគាំទ្រការទាមទាររបស់ខ្លួន និងដើម្បីទៅតតាំងនៅតុលាការ។ យ៉ាងណាមិញ ចំពោះការដោះស្រាយវិវាទដោយមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅប្រទេសកម្ពុជា ទាមទារឱ្យភាគីត្រូវចំណាយថវិកាច្រើនទៅលើថ្លៃសេវា និងប្រើប្រាស់ពេលវេលាច្រើនដូចគ្នា។ ហេតុនេះលទ្ធភាពដែលភាគី ស្វែងរកដំណោះស្រាយពីតុលាការ ក៏ដូចជាមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គឺមានកម្រិតទាប ពីព្រោះភាគីអាចត្រូវចំណាយប្រាក់ថ្លៃសេវា និងប្រាក់សម្រាប់រៀបចំផ្សេងៗ ច្រើនជាងកម្មវត្ថុនៃបណ្តឹងរបស់ខ្លួន ហេតុនេះ ភាគីប្រហែលអាចជ្រើសយកជម្រើសមិនដោះស្រាយបញ្ហារបស់ខ្លួនវិញ។

អាស្រ័យលើហេតុផលទាំងនេះហើយ ទើបមានអនុសាសន៍មួយចំនួនត្រូវបានលើកឡើងពាក់ព័ន្ធនឹងការដោះស្រាយវិវាទប្រកបដោយប្រសិទ្ធិភាព ដែលក្នុងនោះរួមមានការដោះស្រាយជម្លោះផ្ទៃក្នុង (Internal Complaint Handling) និងការដោះស្រាយជម្លោះដោយប្រើប្រាស់ប្រព័ន្ធខាងក្រៅ (External Complaint Handling)។

ទាក់ទងនឹងការដោះស្រាយវិវាទផ្ទៃក្នុង ស្ថាប័នជំនួញគួរតែបង្កើតឱ្យមាននីតិវិធីដោះស្រាយវិវាទដែលយុត្តធម៌ និងមានប្រសិទ្ធិភាព សម្រាប់ដោះស្រាយរាល់ពាក្យបណ្តឹង និងបញ្ហារបស់អ្នកប្រើប្រាស់។[49] នីតិវិធីដោះស្រាយវិវាទនោះទៀតសោត ត្រូវធ្វើឡើង ៖

- ក្នុងរយៈពេលសមស្របមួយ

[49] អនុសាសន៍របស់ OECD ស្តីពីការការពារអ្នកប្រើប្រាស់នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ២០១៦

- មិនគិតថ្លៃពីអ្នកប្រើប្រាស់
- មិនរារាំងសិទ្ធិរបស់ភាគីក្នុងការប្តឹងបន្តទៅស្ថាប័នផ្សេង ប្រសិនបើជម្លោះនោះមិនអាចដោះស្រាយបាន
- មិននាំឱ្យមានសេចក្តីសន្និដ្ឋានណាមួយចំពោះវិវាទឡើយ ប្រសិនវិវាទនោះត្រូវបានប្តឹងបន្តទៅតុលាការ ។ល។

ស្ថាប័នជំនួញ ក៏ចាំបាច់ត្រូវផ្តល់នូវព័ត៌មានច្បាស់លាស់ និងភាពងាយស្រួល ដើម្បីឱ្យអតិថិជនអាចប្រើប្រាស់ នីតិវិធីដោះស្រាយពាក្យបណ្តឹង ឬ បញ្ហារបស់អតិថិជន។ បន្ថែមពីនេះ ប្រសិនបើអតិថិជន មិនពេញចិត្តនឹងដំណោះស្រាយ ដែលផ្តល់ជូនដោយយន្តការដោះស្រាយវិវាទផ្ទៃក្នុងស្ថាប័នជំនួញ គួរតែផ្តល់ជូនអតិថិជននូវព័ត៌មានពាក់ព័ន្ធនឹងយន្តការដោះស្រាយវិវាទដោយប្រើប្រាស់ប្រព័ន្ធខាងក្រៅ ដែលជាដៃគូ ឬ ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធ។

ស្ថាប័នដែលផ្តល់យន្តការការដោះស្រាយវិវាទ ដោយប្រើប្រាស់ប្រព័ន្ធខាងក្រៅនេះទៀតសោត ចាំបាច់ត្រូវតែ អាចឱ្យអតិថិជនប្រើប្រាស់បាន ឯករាជ្យ យុត្តិធម៌ មានទំនួលខុសត្រូវ មានប្រសិទ្ធិភាព និងប្រសិទ្ធិផល ហើយនឹងមិននាំឱ្យមានសេចក្តីសន្និដ្ឋានណាមួយចំពោះវិវាទឡើយ ប្រសិនវិវាទនោះត្រូវបានប្តឹងបន្តទៅតុលាការ។

គួរកត់សម្គាល់ផងដែរថា ក្រសួងពាណិជ្ជកម្ម ទៅថ្ងៃអនាគត អាចនឹងមានគម្រោងបង្កើតឱ្យមានការិយាល័យមួយសម្រាប់គ្រប់គ្រងទំនាក់ទំនងពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិកផងដែរ។ ដោយហេតុថា បច្ចុប្បន្ននៅក្នុងក្រសួងពាណិជ្ជកម្មក្រៅពីនាយកដ្ឋាននីតិកម្ម ដែលមានតួនាទីក្នុងតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនមានផ្នែកណាមួយផ្សេងដែលមានតួនាទីគ្រប់គ្រងលើកិច្ចការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះឡើយ។ ជាក់ស្តែងការចុះបញ្ជីក្រុមហ៊ុនដែលធ្វើ សកម្មភាពពាណិជ្ជកិច្ចតាមប្រព័ន្ធអនឡាញ ត្រូវធ្វើឡើងនៅក្រសួងប្រៃសណីយ និងទូរគមនាគមន៍ មិនមែននៅក្រសួងពាណិជ្ជកម្មនោះឡើយ។[50]

ប្រសិនបើការិយាល័យនេះ ត្រូវបានបង្កើតឡើងមែននោះ គេរំពឹងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នឹងប្រព្រឹត្តទៅដោយរលូន ហើយទាំងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់នឹងបង្កើតឱ្យមានទំនាក់ទំនងពាណិជ្ជកម្ម ដែលមានលក្ខណៈចាស់ទុំ ដើម្បីកាត់បន្ថយវិវាទដែលអាចកើតមានឡើង ឬ អាចចូលរួមដោះស្រាយវិវាទទៀតផង។

[50] អ៊ឹម កុយ (អនុប្រធាននាយកដ្ឋាននីតិកម្មនៃក្រសួងពាណិជ្ជកម្ម), បទសម្ភាសន៍ដោយ យ៉េន វណ្ណីដា និង អ៊ឹង ហ៊ុយគង់, ៣១ ឧសភា ២០១៧

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីធ្វើការបកស្រាយទៅលើប្រធានបទនៃសារណា **របបពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** រួចមក យើងខ្ញុំយល់ឃើញថាប្រធានបទនេះ មានសារៈសំខាន់ខ្លាំងណាស់ សម្រាប់យើងខ្ញុំជានិស្សិត និងអ្នកសិក្សាស្រាវជ្រាវក្នុងការពង្រីកចំណេះដឹងទៅលើប្រធានបទមួយ ដែលថ្មី ដែលសិស្សនិស្សិត និងអ្នកអានភាគច្រើន ពុំធ្លាប់បានយល់ដឹងស៊ីជម្រៅ ស្របពេលដែលប្រទេសកម្ពុជាបច្ចុប្បន្នកំពុងតែស្ថិតនៅក្នុងរបត់មួយ ដែលប្រជាជនភាគច្រើនកំពុងតែក្លាយខ្លួនទៅជាពាណិជ្ជករ និងអ្នកប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គួបផ្សំនឹងលក្ខណៈអំណោយផលកាន់តែប្រសើរឡើងនៃប្រព័ន្ធអ៊ីនធើណេត ឧបករណ៍អេឡិចត្រូនិក ជាដើមនោះ។ ទាំងអស់នេះ សុទ្ធសឹងតែត្រូវបានស បង្ហាញដោយការខិតខំប្រឹងប្រែងរបស់ស្ថាប័នពាក់ព័ន្ធ (ក្រសួងពាណិជ្ជកម្ម) ក្នុងការតាក់តែងសេចក្តីព្រាងច្បាប់មួយ ដើម្បីគ្រប់គ្រងទៅលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ហើយបានបញ្ជូនសេចក្តីព្រាងច្បាប់ទៅដល់ទីស្តីការគណៈរដ្ឋមន្ត្រីកាលពីចុងឆ្នាំ២០១៦ និងការរំពឹងថាសេចក្តីព្រាងច្បាប់នេះ នឹងត្រូវបានអនុម័តឱ្យប្រើប្រាស់នៅក្នុងរវាងឆ្នាំ២០១៧។

ដំណើរការសិក្សាស្រាវជ្រាវ បង្កើតឱ្យចេញជាសារណានេះឡើង បានផ្តល់នូវចំណេះដឹងជាច្រើនដល់យើងខ្ញុំជានិស្សិត ដោយយើងស្គាល់កាន់តែច្បាស់ថាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានលក្ខណៈយ៉ាងណា ប្រវត្តិនៃការកកើតឡើងយ៉ាងដូចម្តេច មានភាពចាំបាច់កម្រិតណាសម្រាប់ប្រទេសកម្ពុជា។ បន្ថែមពីនេះទៅទៀតនោះ គឺឱកាសក្នុងការសិក្សាទៅលើសេចក្តីព្រាងចុងក្រោយបង្អស់នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បន្ទាប់ពីមានការកែប្រែជាច្រើនដងក្នុងរយៈពេលប្រមាណជាមួយទសវត្ស មកហើយ។ សេចក្តីព្រាងចុងក្រោយនៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានកត់សម្គាល់ឃើញថា ភាគច្រើនបានពឹងផ្អែកទៅលើច្បាប់គំរូស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (UNCITRAL Model Law on Electronic Commerce) និងលិខិតតុបករណ៍អន្តរជាតិ ក៏ដូចជាលិខិតបទដ្ឋានគតិយុត្តរបស់បណ្តាប្រទេសនានាផងដែរ។ ថ្វីត្បិតតែ សេចក្តីព្រាងច្បាប់នេះ បានពឹងផ្អែកទៅលើលិខិតតុបករណ៍អន្តរជាតិ និងលិខិតបទដ្ឋានគតិយុត្តរបស់ប្រទេសនានាយ៉ាងណាក្តី ចំណុចវិជ្ជមាន និងអវិជ្ជមានមួយចំនួននៃសេចក្តីព្រាងច្បាប់នៅតែត្រូវបានគេមើលឃើញ។

យ៉ាងណាមិញ វិសាលភាពនៃសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះមានលក្ខណៈធំទូលាយ ដោយគ្របដណ្តប់លើគ្រប់សកម្មភាពប្រតិបត្តិការផ្នែករដ្ឋប្បវេណី និងពាណិជ្ជកម្ម និងរបស់រាជរដ្ឋាភិបាលផងដែរ។ ការណ៍នេះ អាចចោទជាសំនួរថាតើវិសាលភាពនេះ

មានភាពធំធេងពេកឬទេ ខណៈពេលដែលចំណងជើងនៃច្បាប់ផ្ទាល់ ផ្តោតសំខាន់ទៅលើ ពាណិជ្ជកម្ម ។ អាចនិយាយម្យ៉ាងទៀតថា សេចក្តីព្រាងច្បាប់នេះ ដើរតួនាទីសំខាន់ដោយផ្តល់សុពលភាពគតិយុត្តទៅលើលក្ខខណ្ឌសំខាន់ៗទាំងបួន ដែលរួមមានលក្ខខណ្ឌលាយលក្ខណ៍អក្សរ លក្ខខណ្ឌហត្ថលេខា លក្ខខណ្ឌទម្រង់ដើម និងលក្ខខណ្ឌភស្តុតាង។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គេគួរកត់សម្គាល់ផងដែរថា សេចក្តីព្រាងច្បាប់នេះ បានបញ្ញត្តិច្បាស់លាស់ពីលក្ខខណ្ឌទាំងបួននេះ។ ម្យ៉ាងទៀត បើទោះជាសេចក្តីព្រាងច្បាប់នេះ មិនបានបញ្ញត្តិច្បាស់លាស់ពីការការពារអ្នកប្រើប្រាស់ ប៉ុន្តែសេចក្តីព្រាងច្បាប់នេះ មានបញ្ញត្តិជាក់លាក់ចង្អុលបង្ហាញទៅបទប្បបញ្ញត្តិផ្សេងដែលបានចែងពីការការពារអ្នកប្រើប្រាស់ ពោលគឺច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ ដែលបច្ចុប្បន្នកំពុងត្រូវបានពិនិត្យដោយទីស្តីការគណៈរដ្ឋមន្ត្រីនៃប្រទេសកម្ពុជា។ ពាក់ព័ន្ធនឹងការទូទាត់ និងផ្ទេរប្រាក់តាមប្រព័ន្ធ អេឡិចត្រូនិក សេចក្តីព្រាងច្បាប់នេះ គ្រាន់តែបានបញ្ញត្តិពីការតម្រូវឱ្យមានការអនុញ្ញាតជាមុនពីធនាគារជាតិ ក្នុងករណីដែលបុគ្គលណាមួយមានបំណងធ្វើប្រព័ន្ធទូទាត់ ផ្តល់សេវាទូទាត់ ចេញផ្សាយឧបករណ៍អេឡិចត្រូនិក ឬផ្តល់មធ្យោបាយទូទាត់អេឡិចត្រូនិក ជាដើម ប៉ុន្តែមិនបានចែងពីការគ្រប់គ្រងដល់បុគ្គលទាំងនោះទេ។

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទនេះរួចមក យើងខ្ញុំមានអនុសាសន៍មួយចំនួន សម្រាប់ធ្វើឱ្យដំណើរការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកាន់តែមានភាពប្រសើរឡើង ដូចតទៅ៖

- ការសិក្សាទៅលើការដាក់ឱ្យអនុវត្តនៃ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៅបណ្តាប្រទេសអភិវឌ្ឍដទៃគួរតែត្រូវបានធ្វើឡើងឱ្យបានច្រើនថាតើ នៅដំណាក់កាលដំបូងមានបញ្ហាប្រឈមអ្វីខ្លះ? បញ្ហាអ្វីខ្លះដែលប្រទេសកម្ពុជាអាចប្រឈមដែរ? តើប្រទេសទាំងនោះដោះស្រាយបញ្ហា ដែលកើតឡើងនោះដោយរបៀបណា? ហើយដំណោះស្រាយទាំងនោះសមស្របសម្រាប់អនុវត្តនៅប្រទេសកម្ពុជាដែរ ឬទេ?
- ស្ថាប័នមានសមត្ថកិច្ច និងភាគីពាក់ព័ន្ធគួរពិចារណាទៅលើដំណោះស្រាយ ចំពោះបញ្ហាជាក់ស្តែងមួយចំនួន ដែលត្រូវបានលើកឡើងនៅក្នុងសារណានេះ ដូចជាការដោះស្រាយវិវាទ ពីព្រោះដើម្បីធានាថាគ្រប់ភាគីនៅក្នុងទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានភាពកក់ក្តៅក្នុងការធ្វើទំនាក់ទំនងតាមមធ្យោបាយនេះ ហើយរាល់វិវាទដែលអាចកើតមានឡើង នឹងត្រូវបានដោះស្រាយដោយឆាប់រហ័សប្រកបដោយយុត្តិធម៌។

- គួរមានស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រាន់ ដែលធ្វើការប្រកបដោយប្រសិទ្ធិភាពក្នុងការដាក់ឱ្យអនុវត្តច្បាប់ ពោលគឺគ្រប់គ្រងទៅលើសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ ជាក់ស្តែងក្រៅពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលមានតួនាទីចុះបញ្ជីក្រុមហ៊ុនពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ស្ថាប័នជំនាញដូចជាក្រសួងពាណិជ្ជកម្ម អាចតាមដានទៅលើការអនុវត្តច្បាប់នេះ ដូចជាពិនិត្យពីភាពត្រឹមត្រូវស្របច្បាប់របស់លក្ខខណ្ឌសំខាន់ៗរបស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬធ្វើការបណ្តុះ បណ្តាលទៅស្ថាប័នមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទដែលអាចកើតមាន។

ការខិតខំប្រឹងប្រែងក្នុងការតាក់តែងសេចក្តីព្រាងច្បាប់នៅតែបន្តធ្វើឡើង ចំណុចអវិជ្ជមានមួយចំនួននៅតែត្រូវបានគេមើលឃើញ ប៉ុន្តែចំណុចវិជ្ជមានជាច្រើនក៏មិនគួរត្រូវបានមើលរំលងនោះដែរ។ ទៅអនាគត នៅពេលដែល សេចក្តីព្រាងច្បាប់ត្រូវបានអនុម័តឱ្យប្រើប្រាស់ ការគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ប្រកបដោយសណ្តាប់ធ្នាប់ពីស្ថាប័នមានសមត្ថកិច្ច និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ក្នុងការធ្វើឱ្យមានភាពចាស់ទុំនៃប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក នោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅប្រទេសកម្ពុជា ក៏មានលក្ខណៈល្អប្រសើរទៅតាមនោះដែរ។

សរុបសេចក្តីមក ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បាន និងកំពុងវិវត្តខ្លួន និងដើរតួយ៉ាងសំខាន់ ក្នុងការលើកតម្កើងជីវភាពរបស់ប្រជាជនកម្ពុជា នៅក្នុងសម័យកាលទំនើបនេះ ក៏ដូចជាចូលរួមចំណែកគួរឱ្យកត់សម្គាល់ទៅក្នុងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ដោយបានបង្កើតនូវទីផ្សារដែលមិនមានព្រំដែនសម្រាប់ពាណិជ្ជករ។ កត្តាទាំងនេះហើយ ដែលធ្វើឱ្យច្បាប់សម្រាប់គ្រប់គ្រងសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក កាន់តែមានសារៈសំខាន់ថែមមួយកម្រិតទៀត ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ ចូលរួមចំណែកពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធ ដើម្បីធានាបាននូវប្រព័ន្ធមួយដែលមានសុវត្ថិភាព និងទទួលបានទំនុកចិត្តពីពាណិជ្ជករ និងអ្នកប្រើប្រាស់ផងដែរ។

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ២០០៧ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧
- ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៦
- ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩
- ប្រកាសស្តីពីការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧
- សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២)
- សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (ថ្ងៃទី២៦ខែឧសភា ឆ្នាំ២០១៤)
- សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

- 電子署名法（2000 年）, ច្បាប់ស្តីពីហត្ថលេខាអេឡិចត្រូនិក (ឆ្នាំ២០០០)
- 電子消費者契約及び電子承諾通知に関する民法の特例に関する法律(2001 年)、ច្បាប់ទាក់ទងនឹងកិច្ចសន្យាប្រើប្រាស់អេឡិចត្រូនិក និងការជូនដំណឹងពីស្វីការតាមប្រព័ន្ធអេឡិចត្រូនិក(ឆ្នាំ២០០១)
- ច្បាប់គំរូស្តីពីណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ១៩៩៨ (UNCITRAL Model Law on Electronic Economic)

<https://www.uncitral.org/pdf/english/texts/electcom/05-89450_Ebook.pdf> (ចូលទស្សនាចុងក្រោយថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧)

- សេចក្តីណែនាំឱ្យអនុម័ត ច្បាប់គំរូស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ១៩៩៦

## សៀវភៅ និងអត្ថបទផ្សេងៗ

- សម្តេចសង្ឃរាជជូនណាត, "វចនានុក្រមខ្មែរ",បោះពុម្ពលើកទី១ (ភ្នំពេញះពុទ្ធសាសនបណ្ឌិត, ១៩៦៧)

- វចនានុក្រម Longman , បោះពុម្ពលើកទី៣ , ទំព័រ២៦៤ និង៤៤៥
- សាស្ត្រាចារ្យ គង់ សាផន "នីតិពាណិជ្ជកម្ម" បោះពុម្ពលើកទី១, រោងពុម្ព អ៊ីម៉េក ព្រីនធីង, ឆ្នាំ ២០១២
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី១ គន្ថីទី២, ទំព័រ១០, ភ្នំពេញ ៖ក្រសួងយុត្តិធម៌ (២០១០)
- ក្រុមការងារនៃអនាគតគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រម នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, "សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១", កែសម្រួលលើការបោះពុម្ពលើកទី១, ២០១៣។
- World Trade Organization 'E-commerce in Developing Countries' 2013 , page 3 , អង្គការពាណិជ្ជកម្មពិភពលោក "ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងប្រទេសកំពុងអភិវឌ្ឍ" ឆ្នាំ២០១៣, ទំព័រ 3
- 江頭　憲治郎「商取引法」第 6 版、弘文堂、8−9 ページ、អិហ្កាក់ជីរ៉ា កេនជីរ៉ូ "ច្បាប់ពាណិជ្ជកម្ម", បោះពុម្ពលើកទី៦ រោងពុម្ព កូប៊ីនដូ, ទំព័រ៨ និង៩
- Mastui Shigenori, Suzuki Hidemi, Yamaguchi Itsuko,「*インターネット法*」,有斐閣、2015、168 ページ、*「ច្បាប់ស្តីពីប្រព័ន្ធអ៊ីនធើណេត」* រោងពុម្ពយូហ៊ីកាគឺ ឆ្នាំ២០១៥ ទំព័រ១៦៨
- អនុសាសន៍របស់អង្គការសម្រាប់កិច្ចសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) ស្តីពីការការពារអ្នកប្រើប្រាស់នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ២០១៦ (Consumer Protection in E-Commerce, OCED Recommendations, 2016)

<https://www.oecd.org/sti/consumer/ECommerce-Recommendation-2016.pdf> (ចូលទស្សនាចុងក្រោយថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧)

- វាយតម្លៃចំពោះភាពរួចរាល់សម្រាប់ការធ្វើជំនួញតាមប្រព័ន្ធអេឡិចត្រូនិកនៅប្រទេសកម្ពុជា (Rapid eTrade Readiness Assessment, Cambodia)

  <http://unctad.org/en/PublicationsLibrary/dtlstict2017d2_en.pdf> (ចូលទស្សនាចុងក្រោយថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧)

- សារណាបញ្ចប់ថ្នាក់អនុបណ្ឌិត អំពី បទដ្ឋានច្បាប់សម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅអាស៊ាន៖ច្បាប់គំរូ ឆ្នាំ២០០៦ (E-COMMERCE LEGAL FRAMEWORK FOR ASEAN: a MODEL CODE, National University of Singapore, 2006)

<http://scholarbank.nus.edu.sg/bitstream/handle/10635/15500/E-Commerce%20legal%20framework%20for%20ASEAN%20A%20model%20code-T.%20A.%20Anuragini-ht031454m.pdf?sequence=1> (ចូលទស្សនាចុងក្រោយថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧)

- សារណាបញ្ចប់ការសិក្សា "ការរៀបចំច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិកនៅកម្ពុជា" សរសេរដោយ ញឹក ពេជ្រម៉ូលីកា និងឡឹក សីហា ដឹកនាំដោយសាស្ត្រាចារ្យ សន សោភណ្ឌ ឆ្នាំ២០១៨
- តើអង្គការអន្តរជាតិណាខ្លះដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក? (What international organizations are involved in e-commerce law?)

< https://www.itu.int/ITU-T/special-projects/ip-policy/final/Attach04.doc> (ចូលមើលចុងក្រោយថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៧)

- សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងពាណិជ្ជកម្មថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៦

<https://www.facebook.com/moc.gov.kh/videos/vb.689434681069413/1338538166159058/?type=2&theater> (ចូលទស្សនាចុងក្រោយថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧)

- សុន្ទរកថារបស់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៦ នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រ

<http://www.moc.gov.kh/en-us/press-center/details/content/211601> (ចូលទស្សនាចុងក្រោយថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧)

- ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៅក្នុងទីផ្សារដែលកំពុងអភិវឌ្ឍរបស់អាស៊ាន, ២៦ តុលា ២០១៥

<http://britchamcambodia.org/uploads/cbcc1-ecommerce-in-asean-emerging-markets-i---presentation.pdf> (ចូលទស្សនាចុងក្រោយថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧)

## គេហទំព័រ

- វចនានុក្រមធុរកិច្ច 〈http://www.businessdictionary.com/definition/commerce.html〉 〈https://www.wto.org/english/res_e/booksp_e/ecom_brochure_e.pdf〉(ចូលទស្សនាចុងក្រោយថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧)

- គេហទំព័រshop168 〈http://shop168.com.kh/?sl=EN〉 (ចូលទស្សនាចុងក្រោយថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៧)
- គេហទំព័រLittle Fashion 〈https://www.l192.com/〉(ចូលទស្សនាចុងក្រោយថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៧)
- គេហទំព័រ 楽天市場 〈http://www.rakuten.co.jp/〉 (ចូលទស្សនាចុងក្រោយថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៧)
- គេហទំព័រQoo10 〈http://list.qoo10.jp/gmkt.inc/Bestsellers/Default.aspx?g=1#540207593〉 (ចូលទស្សនាចុងក្រោយថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៧)
- ធនាគារជាតិនៃកម្ពុជា , ប្រវត្តិនៃការទូទាត់ 〈https://www.nbc.org.kh/payment_systems/background_of_payment_systems.php〉 (ចូលទស្សនាចុងក្រោយថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧)
- គេហទំព័រ Tutorial point
<https://www.tutorialspoint.com/e_commerce/pdf/e_commerce_advantages.pdf> (ចូលទស្សនាចុងក្រោយថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧)


## សារព័ត៌មាន


- ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៅប្រទេសកម្ពុជា: ព័ត៌មានសំខាន់ប្រចាំឆ្នាំ, ២០១៦ (E-commerce In Cambodia: Highlights Of The Year, 2016), B2B Business Cambodia
<https://www.b2b-cambodia.com/articles/e-commerce-in-cambodia-highlights-of-the-year>
(ចូលទស្សនាចុងក្រោយថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧)
- ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានពន្យឺតដោយរាជរដ្ឋាភិបាល (E-commerce adoption slowed by the government), Phnom Penh Post
<http://www.phnompenhpost.com/business/e-commerce-slowed-government-report> (ចូលទស្សនាចុងក្រោយថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧)
- ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការទិញទំនិញអនឡាញ (Online) នៅប្រទេសកម្ពុជា (E-commerce and Online Shopping in Cambodia), Khmer CMS

<https://khmercms.com/e-commerce-and-online-shopping-in-cambodia> (ចូលទស្សនាចុងក្រោយថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧)

- ប្រទេសកម្ពុជា ធ្វើសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកខណៈពេលដែលការលក់ទំនិញអនឡាញ (Online) កើនឡើង (Cambodia drafts e-commerce law as online sales grow), Xinhua

<http://news.xinhuanet.com/english/2016-11/06/c_135809717.htm> (ចូលទស្សនាចុងក្រោយថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧)

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីព្រាង

# ច្បាប់

## ស្តីពី

# ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦

ក្រសួងពាណិជ្ជកម្ម

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលបំណង**

ច្បាប់នេះមានគោលបំណងៈ

១. គ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជា និងជាមួយអន្តរជាតិ។

២. បង្កើតភាពប្រាកដប្រជាផ្នែកគតិយុត្តក្នុងប្រតិបត្តិការផ្នែករដ្ឋប្បវេណី និងផ្នែកពាណិជ្ជកម្មដែលទាក់ទងទៅនឹងទំនាក់ទំនងអេឡិចត្រូនិក។

**មាត្រា ២.- គោលដៅ**

ច្បាប់នេះមានគោលដៅដូចខាងក្រោមៈ

១. កំណត់អំពីយថាភូតភាព សុក្រឹតភាព និងភាពអាចជឿទុកចិត្តបាននៃទម្រង់អេឡិចត្រូនិក។

២. ជំរុញការអភិវឌ្ឍក្របខណ្ឌគតិយុត្តិ និងធុរកិច្ច ដើម្បីអនុវត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកប្រកបដោយសុវត្ថិភាព។

៣. បង្កា និងបង្ក្រាបអំពើដែលបង្កការខូចខាតដល់ទិន្នន័យ និងប្រព័ន្ធព័ត៌មាន។

៤. ផ្តល់ទំនុកចិត្តដល់សាធារណជនក្នុងការប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង លុបបំបាត់ឧបសគ្គទាំងឡាយដែលរាំងស្ទះដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ហើយដែលកើតចេញពីភាពមិនប្រាកដប្រជានៃលក្ខខណ្ឌតម្រូវចំពោះលិខិតជាលាយលក្ខណ៍អក្សរ និងហត្ថលេខា។

៥. សម្រួលដល់ការតម្កល់ឯកសារតាមប្រព័ន្ធអេឡិចត្រូនិកជាមួយស្ថាប័នសាធារណៈ និងលើកកម្ពស់ការផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធភាពរបស់ស្ថាប័នសាធារណៈ តាមរយៈការប្រើប្រាស់កំណត់ត្រាតាមប្រព័ន្ធអេឡិចត្រូនិកដែលអាចជឿទុកចិត្តបាន។

៦. បង្កើតវិធាន បទប្បញ្ញត្តិ និងស្តង់ដាររួមមួយ ដែលទាក់ទងនឹងយថាភូតភាព និងសុក្រឹតភាពរបស់កំណត់ត្រាតាមប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា៣.- វិសាលភាព**

១. ច្បាប់នេះត្រូវអនុវត្តលើសកម្មភាព ឯកសារ និងប្រតិបត្តិការផ្នែករដ្ឋប្បវេណី និងពាណិជ្ជកម្មទាំងអស់ លើកលែងតែសកម្មភាព ឯកសារ និងប្រតិបត្តិការទាក់ទងនឹង៖

- ការបង្កើត ឬការអនុវត្តលិខិតប្រគល់សិទ្ធិ។
- ការបង្កើត ឬការចុះហត្ថលេខាលើមតកសាសន៍ លិខិតកែមតកសាសន៍ ឬ បញ្ហាផ្សេងៗទៀតទាក់ទិននឹងការស្នងមរតក។
- រាល់កិច្ចសន្យាសម្រាប់ការលក់ ការផ្ទេរ ឬការបោះបង់សិទ្ធិលើអចលនទ្រព្យឬផលប្រយោជន៍ផ្សេងៗទៀតក្នុងទ្រព្យនោះ។
- ការផ្ទេរអចលនវត្ថុឬផលប្រយោជន៍ណាមួយដែលពាក់ព័ន្ធនឹងអចលនវត្ថុនោះ
- ឧបករណ៍អាចជួញដូរបាន
- ករណីលើកលែងផ្សេងទៀតដែលត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី២
## សុពលភាពនៃទំនាក់ទំនងអេឡិចត្រូនិក

**មាត្រា ៤.- ការទទួលស្គាល់លក្ខណៈគតិយុត្តនៃទំនាក់ទំនងអេឡិចត្រូនិក**

គ្មានបុគ្គលណាម្នាក់អាចបដិសេធមិនទទួលស្គាល់អានុភាពគតិយុត្ត ឬសុពលភាព ឬភាពអាចទទួលយកបាន ឬភាពដែលអាចយកទៅតតាំងជាមួយតតីយជនបាននៃទំនាក់ទំនងអេឡិចត្រូនិក ដោយគ្រាន់តែសម្អាងលើមូលហេតុដែលថាវាធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក ឬស្ថិតនៅក្នុងទំនាក់ទំនងអេឡិចត្រូនិចឡើយ។

**មាត្រា ៥.- លក្ខខណ្ឌតម្រូវជាលាយលក្ខណ៍អក្សរ**

១. នៅពេលដែលបទប្បញ្ញត្តិណាមួយ តម្រូវឲ្យផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរ ឬធ្វើកំណត់ត្រាជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថាលក្ខខណ្ឌតម្រូវនេះត្រូវបានបំពេញប្រសិនបើព័ត៌មាននេះធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក ហើយអាចចូលប្រើប្រាស់បាន និងអាចយកទៅប្រើប្រាស់ជាសំអាងនៅពេលក្រោយបាន។

២. នៅពេលដែលលក្ខខណ្ឌក្នុងកថាខណ្ឌ ១ ត្រូវយកមកអនុវត្ត លក្ខខណ្ឌតម្រូវតាមច្បាប់ដែលទាមទារឱ្យបុគ្គលណាមួយផ្តល់សំណៅចម្លងច្រើនច្បាប់ក្នុងពេលតែមួយស្តីអំពីព័ត៌មានណាមួយ ឬបញ្ហាផ្សេងៗណាមួយទៅឲ្យបុគ្គលមួយផ្សេងទៀត បុគ្គលដែលផ្តល់អាចបំពេញ

លក្ខខណ្ឌនេះដោយគ្រាន់តែផ្តល់ក្រោមទម្រង់អេឡិចត្រូនិកតែមួយច្បាប់ ។

**មាត្រា ៦**.- **លក្ខខណ្ឌតម្រូវចំពោះហត្ថលេខា**

១. នៅពេលដែលបទប្បញ្ញត្តិណាមួយតម្រូវឲ្យមានហត្ថលេខារបស់បុគ្គលណាមួយនៅក្នុងទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិក លក្ខខណ្ឌតម្រូវនេះត្រូវចាត់ទុកថាបានបំពេញតាមរយៈការចុះហត្ថលេខាតាមប្រព័ន្ធអេឡិចត្រូនិក ប្រសិនបើហត្ថលេខាអេឡិចត្រូនិកដែលបានប្រើនោះអាចជឿជាក់បាន និងស្របតាមគោលបំណងដែលទំនាក់ទំនងអេឡិចត្រូនិកនោះត្រូវបានបង្កើតឡើង ឬត្រូវបានប្រាស្រ័យទាក់ទង ក្នុងគោលបំណងឆ្លុះបញ្ចាំងគ្រប់កាលៈទេសៈជាក់ស្តែង រួមទាំងរាល់កិច្ចព្រមព្រៀងដែលពាក់ព័ន្ធផងដែរ។

២. ទោះបីជាបទប្បញ្ញត្តិណាមួយកំណត់អំពីលក្ខខណ្ឌតម្រូវឱ្យមានចុះហត្ថលេខា ឬគ្រាន់តែកំណត់ផលវិបាកនៃការមិនចុះហត្ថលេខា ក៏កថាខណ្ឌ១ខាងលើត្រូវយកមកអនុវត្តផងដែរ។

៣. ហត្ថលេខាអេឡិចត្រូនិកត្រូវបានសន្មតថាអាចជឿជាក់បានសម្រាប់គោលបំណងបំពេញលក្ខខណ្ឌតម្រូវដូចមានកំណត់នៅក្នុងកថាខណ្ឌ១ ប្រសិនបើហត្ថលេខាអេឡិចត្រូនិកនោះ គោរពតាមលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

ក. អាចផ្សារភ្ជាប់ទៅនឹងហត្ថលេខីតែម្នាក់គត់។

ខ. អាចកំណត់បានអត្តសញ្ញាណរបស់ហត្ថលេខី។

គ. ត្រូវបានបង្កើតឡើងដោយប្រើប្រាស់មធ្យោបាយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ហត្ថលេខីនោះ។

ឃ. ត្រូវបានភ្ជាប់ទៅនឹងទិន្នន័យដែលពាក់ព័ន្ធនឹងហត្ថលេខាអេឡិចត្រូនិកនោះដែលអាចឱ្យបុគ្គលណាមួយកំណត់អំពីការកែប្រែទិន្នន័យនោះនាពេលក្រោយបាន។

៤. កថាខណ្ឌ ៣ ខាងលើ មិនកម្រិតលទ្ធភាពរបស់បុគ្គលណាមួយក្នុងទំនាក់ទំនងអេឡិចត្រូនិកឡើយ ក្នុងការ៖

ក. កំណត់លក្ខខណ្ឌផ្សេងទៀតពាក់ព័ន្ធនឹងការបញ្ជាក់ភាពអាចជឿជាក់បានរបស់ហត្ថលេខាអេឡិចត្រូនិក ឬ

ខ. លើកភស្តុតាងអំពីភាពមិនអាចជឿជាក់បាននៃហត្ថលេខាអេឡិចត្រូនិក។

## មាត្រា ៧.- លក្ខខណ្ឌតម្រូវដើម្បីបញ្ជាក់ពីទម្រង់ដើម

លក្ខខណ្ឌគតិយុត្តក្នុងការរក្សាព័ត៌មានដែលមិនត្រូវបានធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក អាចត្រូវបានបំពេញដោយការរក្សាព័ត៌មាននោះក្រោមទម្រង់អេឡិចត្រូនិក ប្រសិនបើ៖

១. ទម្រង់អេឡិចត្រូនិកនោះជាមធ្យោបាយដែលអាចជឿទុកចិត្តបានដើម្បីកំណត់ភាពពេញលេញរបស់ព័ត៌មាននោះ និង

២. ព័ត៌មាននោះអាចចូលយកបានដោយងាយស្រួល សម្រាប់យកទៅប្រើប្រាស់បានពេលក្រោយ។

## មាត្រា ៨.- ទម្រង់បែបបទដែលកំណត់

នៅពេលដែលបទប្បញ្ញត្តិណាមួយតម្រូវឲ្យព័ត៌មានធ្វើឡើងក្នុងទម្រង់បែបបទណាមួយ លក្ខខណ្ឌតម្រូវនោះត្រូវជំនួសដោយការផ្តល់ព័ត៌មានតាមទម្រង់អេឡិចត្រូនិកបាន ប្រសិនបើទម្រង់អេឡិចត្រូនិកនោះត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- មានផ្ទុកព័ត៌មានដូចគ្នា ឬដូចគ្នាភាគច្រើនទៅនឹងទម្រង់បែបបទដែលបានកំណត់
- អាចចូលទៅមើលបាន អាចយល់បាន និងអាចទាញយកមកប្រើប្រាស់បាននៅពេលក្រោយ
- អាចឱ្យបុគ្គលដែលទទួលបានព័ត៌មាននោះរក្សាទុកបាន។

## មាត្រា ៩.- លក្ខខណ្ឌតម្រូវលើការរក្សាទុកកំណត់ត្រា

១. នៅពេលដែលបទប្បញ្ញត្តិណាមួយតម្រូវឲ្យរក្សាទុកនូវឯកសារ កំណត់ត្រា ឬព័ត៌មានជាក់លាក់ណាមួយ លក្ខខណ្ឌតម្រូវនោះត្រូវចាត់ទុកថាបានបំពេញ ប្រសិនបើ ការរក្សាទុកនោះបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- ព័ត៌មានដែលមាននៅក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះអាចចូលប្រើប្រាស់បាន និងសម្រាប់យកទៅប្រើប្រាស់នាពេលអនាគត
- ទំនាក់ទំនងអេឡិចត្រូនិកត្រូវបានរក្សាទុកក្នុងទម្រង់ដើមដែលត្រូវបានបង្កើតឡើង ផ្ញើ ឬទទួលបាន ឬក្នុងទម្រង់ដែលអាចត្រូវបានបង្ហាញពីសុក្រិតភាពនៃព័ត៌មាននោះ
- ព័ត៌មានទាំងនោះ ត្រូវរក្សាទុកដើម្បីឱ្យបុគ្គលណាម្នាក់អាចកំណត់បាននូវប្រភពដើម និងគោលដៅនៃទំនាក់ទំនងអេឡិចត្រូនិកនោះ កាលបរិច្ឆេទ និងពេលវេលា ដែលទំនាក់ទំនងអេឡិចត្រូនិកនោះត្រូវបានផ្ញើ ឬទទួល ។

២. កាតព្វកិច្ចក្នុងការរក្សាឯកសារ កំណត់ត្រា ឬព័ត៌មានស្របតាមកថាខណ្ឌ ១ មិនរាប់បញ្ចូលព័ត៌មានណាមួយ ដែលគ្រាន់តែធ្វើឡើងក្នុងគោលបំណងសម្រាប់តែធ្វើការបញ្ជូន ឬទទួលសារនោះឡើយ។

**មាត្រា ១០.- លក្ខខណ្ឌតម្រូវស្ដីពីភស្ដុតាង**

គ្មានបទប្បញ្ញត្តិណាមួយក្នុងការអនុវត្តវិធានស្ដីពីភស្ដុតាង អាចជំទាស់ការទទួលស្គាល់ទំនាក់ទំនងអេឡិចត្រូនិកជាភស្ដុតាង ដោយគ្រាន់តែឈរលើមូលដ្ឋានដែលថា ៖

១. ភស្ដុតាងនោះជាទំនាក់ទំនងអេឡិចត្រូនិក ឬ

២. ភស្ដុតាងនោះមិនស្ថិតក្នុងទម្រង់ដើម។

**មាត្រា ១១.- ការបង្កើត និងសុពលភាពនៃកិច្ចសន្យា**

១. ច្បាប់នេះកំណត់ថា ក្នុងការបង្កើតកិច្ចសន្យា សំណើ និង ស្វីការ អាចត្រូវបានធ្វើឡើងតាមមធ្យោបាយទំនាក់ទំនងអេឡិចត្រូនិក។

២. នៅពេលណាដែលទំនាក់ទំនងអេឡិចត្រូនិកត្រូវបានប្រើប្រាស់ ដើម្បីបង្កើតកិច្ចសន្យា កិច្ចសន្យានោះមានសុពលអាចអនុវត្តបាន។

**មាត្រា ១២.- អានុភាពរវាងគូភាគី**

អ្នកផ្ញើ និង អ្នកទទួលនៃទំនាក់ទំនងអេឡិចត្រូនិកមិនត្រូវបដិសេធអានុភាពគតិយុត្តិ សុពលភាព និងភាពអាចអនុវត្តបានចំពោះការបង្ហាញឆន្ទៈ ឬសេចក្ដីថ្លែងផ្សេងៗរបស់ខ្លួនឡើយ។

**មាត្រា ១៣.- ការកែប្រែដោយមានការព្រមព្រៀងរបស់គូភាគី**

បញ្ញត្តិដែលពាក់ព័ន្ធនឹងជំពូកទី២ អាចត្រូវបានធ្វើការកែប្រែដោយមានកិច្ចព្រមព្រៀងរវាងគូភាគីដែលចូលរួមក្នុងការបង្កើត ការផ្ញើ ការទទួល ការរក្សាទុក ឬដំណើរការទំនាក់ទំនងអេឡិចត្រូនិក លើកលែងតែមានចែងផ្សេងពីនេះក្នុងកិច្ចព្រមព្រៀងដើម។

២. ទោះជាមានបញ្ញត្តិដូចមានចែងក្នុងជំពូក២ គូភាគីនៃកិច្ចសន្យា ឬក្នុងប្រតិបត្តិការណាមួយ ក៏អាច៖

ក. ហាមឃាត់មិនឲ្យប្រើប្រាស់កំណត់ត្រាតាមប្រព័ន្ធអេឡិចត្រូនិច ការទំនាក់ទំនងអេឡិចត្រូនិច ឬហត្ថលេខាតាមប្រព័ន្ធអេឡិចត្រូនិចក្នុងកិច្ចសន្យា ឬប្រតិបត្តិការណាមួយតាមរយៈកិច្ចព្រមព្រៀង។ ឬ

ខ. ដាក់លក្ខខណ្ឌតម្រូវបន្ថែមផ្សេងៗដែលពាក់ព័ន្ធនឹងទម្រង់ ឬយថាភូតភាពនៃកិច្ចសន្យា ឬប្រតិបត្តិការតាមរយៈកិច្ចព្រមព្រៀង។

## ជំពូកទី៣
## ដំណើរការទំនាក់ទំនង

**មាត្រា ១៤.- ពេលវេលា និងទីកន្លែងនៃការបញ្ជូនចេញ និងទទួលទំនាក់ទំនងអេឡិចត្រូនិក**

១. ទំនាក់ទំនងអេឡិចត្រូនិកមួយត្រូវបានបញ្ជូនចេញនៅពេលដែលៈ

ក. ទំនាក់ទំនងអេឡិចត្រូនិកនោះចាកចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកផ្ញើ ឬ របស់ភាគីដែលផ្ញើជំនួសក្នុងនាមអ្នកផ្ញើរ ឬ

ខ. ក្នុងករណីដែលទំនាក់ទំនងអេឡិចត្រូនិកនោះមិនទាន់បានចាកចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកផ្ញើ ឬ របស់ភាគីដែលផ្ញើជំនួស ទំនាក់ទំនងអេឡិចត្រូនិកមួយត្រូវបានបញ្ជូនចេញនៅពេលដែលទំនាក់ទំនងអេឡិចត្រូនិកនោះត្រូវបានទទួល

២. ពេលវេលានៃការទទួលទំនាក់ទំនងអេឡិចត្រូនិក គឺពេលដែលទំនាក់ទំនងអេឡិចត្រូនិកនោះ អាចទាញយកបានដោយអ្នកទទួលនៅក្នុងអាស័យដ្ឋានអេឡិចត្រូនិកដែលអ្នកទទួលបានបញ្ជាក់ជាមុន។ ទំនាក់ទំនងអេឡិចត្រូវបានសន្មតថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

៣. ប្រសិនបើទំនាក់ទំនងអេឡិចត្រូនិកមិនត្រូវបានផ្តល់ឲ្យអ្នកទទួល នោះពេលវេលាដែលទទួលបានទំនាក់ទំនងអេឡិចត្រូនិចនោះ គឺជាពេលវេលាដែលទំនាក់ទំនងអេឡិចត្រូនិកអាចទាញយកបានដោយអ្នកទទួលតាមរយៈអាសយដ្ឋានមួយ ហើយអ្នកទទួលបានទទួលដឹងអំពីការផ្ញើចេញទំនាក់ទំនងអេឡិចត្រូនិកទៅកាន់អាសយដ្ឋាននោះ។ ទំនាក់ទំនងអេឡិចត្រូនិកនោះត្រូវបានសន្មតថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

៤. ទំនាក់ទំនងអេឡិចត្រូនិកត្រូវបានសន្មតថាបានទទួលដោយអ្នកទទួលនៅពេលវាទៅដល់អាស័យដ្ឋានអេឡិចត្រូនិករបស់អ្នកទទួល។ទំនាក់ទំនងអេឡិចត្រូនិកនោះត្រូវបានសន្មតថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

៥. ទំនាក់ទំនងអេឡិចត្រូនិកមួយត្រូវបានសន្មតថាបានបញ្ជូនចេញពីទីតាំងអាជីវកម្មរបស់អ្នកផ្ញើទោះបីទំនាក់ទំនងអេឡិចត្រូនិកនោះត្រូវបានផ្ញើចេញពីទីតាំងណាក៏ដោយ។

**មាត្រា ១៥.- ការអញ្ជើញឲ្យបង្កើតសំណើ**

រាល់ការស្នើសុំចុះកិច្ចសន្យាតាមរយៈប្រព័ន្ធព័ត៌មានដែលធ្វើឡើងដោយទំនាក់ទំនងអេឡិចត្រូនិក ហើយដែលមិនសំដៅដល់បុគ្គលណាមួយជាក់លាក់ ត្រូវចាត់ទុកថាជាការអញ្ជើញឱ្យធ្វើសំណើបង្កើតកិច្ចសន្យា លុះត្រាតែសំណើបង្កើតកិច្ចសន្យាមានបង្ហាញឲ្យឃើញច្បាស់អំពីឆន្ទៈរបស់បុគ្គលដែលបានបង្កើតសំណើនោះ ថាខ្លួននឹងត្រូវជាប់កាតព្វកិច្ចលុះត្រាតែមានស្វីការ ហើយនៅពេលដែលមានស្វីការ ការអញ្ជើញនោះត្រូវចាត់ទុកថាជាសំណើ។

**មាត្រា ១៦.- ការប្រើប្រាស់ប្រព័ន្ធសារស្វ័យប្រវត្តិសម្រាប់បង្កើតកិច្ចសន្យា**

កិច្ចសន្យាដែលបង្កើតឡើង ដោយអន្តរកម្មរវាងប្រព័ន្ធសារស្វ័យប្រវត្តិជាមួយរូបវន្ត បុគ្គល ឬ ជាមួយប្រព័ន្ធសារស្វ័យប្រវត្តិផ្សេងទៀត មិនត្រូវបានជំទាស់អំពីសុពលភាព ឬភាពដែលអាចតតាំងបានរបស់កិច្ចសន្យានោះ ដោយគ្រាន់តែផ្អែកលើមូលដ្ឋានអវត្តមាននៃរូបវន្តបុគ្គលក្នុងការពិនិត្យ ឬចូលអន្តរាគមក្នុងសកម្មភាពនីមួយៗដែលធ្វើឡើងដោយប្រព័ន្ធសារស្វ័យប្រវត្តិ ឬក្នុងការពិនិត្យ ឬចូលអន្តរាគមដើម្បីបង្កើតកិច្ចសន្យានោះឡើយ។

**មាត្រា ១៧ .- កំហុសឆ្គងក្នុងទំនាក់ទំនងអេឡិចត្រូនិក**

នៅពេលដែលរូបវន្តបុគ្គលបញ្ចូលព័ត៌មានខុសនៅក្នុងទំនាក់ទំនងអេឡិចត្រូនិកមួយ ដែលបានដោះដូរជាមួយភាគីម្ខាងទៀតតាមរយៈប្រព័ន្ធស្វ័យប្រវត្តិ ហើយប្រព័ន្ធស្វ័យប្រវត្តិនោះមិនផ្តល់ឱកាសឲ្យរូបវន្តបុគ្គលនោះធ្វើការកែប្រែនូវព័ត៌មានដែលខុស នោះរូបវន្តបុគ្គល ឬភាគីដែលជំនួសមុខឲ្យរូបវន្តបុគ្គលដែលធ្វើសកម្មភាពនោះ មានសិទ្ធិកែតម្រូវ ឬ ដកចេញពីទំនាក់ទំនងអេឡិចត្រូនិកនូវព័ត៌មានដែលខុសនោះបាន ក្នុងករណីដែល៖

១. រូបវន្តបុគ្គលនោះ ជូនដំណឹងទៅភាគីម្ខាងទៀតអំពីកំហុសដែលបានកើតឡើង ឲ្យបានឆាប់បំផុតតាមលទ្ធភាពដែលអាចធ្វើទៅបាន ក្រោយពីបានដឹងអំពីកំហុសនោះ ហើយត្រូវបង្ហាញថាខ្លួនបានបញ្ចូលព័ត៌មានខុសនៅក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះ និង

២. រូបវន្តបុគ្គលនោះមិនទទួលបានផលប្រយោជន៍ណាមួយ ដោយសារការបញ្ចូលព័ត៌មានខុសនេះ មុនពេលដែលខ្លួនធ្វើការជូនដំណឹងទៅឲ្យភាគីម្ខាងទៀត។

# ជំពូកទី ៤
# កំណត់ត្រាអេឡិចត្រូនិក និងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព

**មាត្រា ១៨.- កំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាព**

ប្រសិនបើនីតិវិធីសុវត្ថិភាពត្រូវបានប្រើប្រាស់ត្រឹមត្រូវចំពោះកំណត់ត្រាអេឡិចត្រូនិកមួយ ដើម្បីបញ្ជាក់ថាកំណត់ត្រាអេឡិចត្រូនិកនោះមិនត្រូវបានកែប្រែ ចាប់តាំងពីពេលជាក់លាក់ណាមួយ កំណត់ត្រានេះត្រូវបានចាត់ទុកថាជាកំណត់ត្រាអេឡិចត្រូនិចដែលមានសុវត្ថិភាព គិតចាប់ពីពេលជាក់លាក់នោះ រហូតដល់ពេលធ្វើការពិនិត្យបញ្ជាក់។

**មាត្រា ១៩.-ហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព**

តាមរយៈការអនុវត្តនីតិវិធីសុវត្ថិភាព ហត្ថលេខាអេឡិចត្រូនិក**ដែលមានសុវត្ថិភាព** មួយអាចត្រូវបានពិនិត្យបញ្ជាក់បាននៅពេលដែលៈ

១. ហត្ថលេខានោះជាកម្មសិទ្ធិផ្ទាល់របស់បុគ្គលដែលប្រើប្រាស់វា។

២. ហត្ថលេខានោះមានសមត្ថភាពបញ្ជាក់អំពីអត្តសញ្ញាណរបស់បុគ្គលនោះ

៣. ហត្ថលេខានោះត្រូវបានបង្កើតតាមរបៀប ឬដោយប្រើប្រាស់មធ្យោបាយមួយដែលស្ថិតនៅក្រោមការត្រួតពិនិត្យផ្តាច់មុខរបស់បុគ្គលដែលប្រើប្រាស់វា។ និង

៤. ហត្ថលេខាដែលបានភ្ជាប់ទៅនឹងកំណត់ត្រាអេឡិចត្រូនិកតាមរបៀបណាមួយ នៅពេលដែលកំណត់ត្រាអេឡិចត្រូនិកត្រូវបានផ្លាស់ប្តូរ ហត្ថលេខាអេឡិចត្រូនិកនោះនឹងត្រូវអស់សុពលភាព។

ហត្ថលេខាដែលមានលក្ខណៈខាងលើនេះ ត្រូវចាត់ទុកថាជាហត្ថលេខាអេឡិចត្រូនិកមានសុវត្ថិភាព។

**មាត្រា ២០. ការសន្មតទាក់ទងនឹងកំណត់ត្រានិងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព**

១. រាល់ដំណើរការណាមួយដែលពាក់ព័ន្ធនឹងកំណត់ត្រាអេឡិចត្រូនិកសុវត្ថិភាព កំណត់ត្រាអេឡិចត្រូនិកនោះត្រូវបានសន្មត់ថាជាកំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាពនៅពេលដែលកំណត់ត្រានោះមិនត្រូវបានកែប្រែចាប់តាំងពីពេលជាក់លាក់ណាមួយ លើកលែងតែមានភស្តុតាងផ្ទុយ។

២. រាល់ដំណើរការណាមួយដែលពាក់ព័ន្ធនឹងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព ហត្ថលេខាអេឡិចត្រូនិកនោះត្រូវបានសន្មត់ថាជាហត្ថលេខាអេឡិចត្រូនិកដែលមាន

សុវត្ថិភាព លុះត្រាតែៈ

ក. ហត្ថលេខាអេឡិចត្រូនិកសុវត្ថិភាពនោះ គឺជាហត្ថលេខារបស់រូបវន្តបុគ្គលដែលបានចុះហត្ថលេខា និង

ខ. ហត្ថលេខាអេឡិចត្រូនិកសុវត្ថិភាព ត្រូវបានចុះហត្ថលេខាដោយរូបវន្តបុគ្គលដែលមានឆន្ទៈក្នុងការចុះហត្ថលេខា ឬបានឯកភាពលើកំណត់ត្រាអេឡិចត្រូនិកនោះ។

៣. ក្នុងករណីដែលគ្មានកំណត់ត្រាអេឡិចត្រូនិកសុវត្ថិភាព ឬ ហត្ថលេខាអេឡិចត្រូនិកសុវត្ថិភាព គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងជំពូក៤ អាចការសន្មតជាមុនអំពីយថាភូតភាព ឬសុក្រិតភាពនៃកំណត់ត្រាអេឡិចត្រូនិក ឬ ហត្ថលេខាអេឡិចត្រូនិកនោះឡើយ។

**មាត្រា ២១.- អាជ្ញាធរមានសមត្ថកិច្ចគ្រប់គ្រង និងផ្ដល់នីតិវិធីដើម្បីធានាសុវត្ថិភាពដែលបានកំណត់**

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងផ្ដល់នីតិវិធីដើម្បីធានាសុវត្ថិភាពដែលបានកំណត់។ ស្ថាប័ននេះត្រូវ ផ្ដល់នូវបទប្បញ្ញត្តិដែលទាក់ទងនឹងនីតិវិធីដើម្បីធានាសុវត្ថិភាព ដោយរាប់បញ្ចូលទាំងៈ

១. ការកំណត់លក្ខខណ្ឌដែលតាមរយៈនេះ ហត្ថលេខាអេឡិចត្រូនិកអាចត្រូវបានចាត់ទុកជាហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព។

២. ការកំណត់លក្ខខណ្ឌដែលតាមរយៈនេះ កំណត់ត្រាអេឡិចត្រូនិកអាចត្រូវបានចាត់ទុកជាកំណត់ត្រាអេឡិចត្រូនិកដែលបានធានា និង

៣. បទប្បញ្ញត្តិ អាជ្ញាបណ្ណ ឬ សិទ្ធិអំណាចរបស់អ្នកផ្ដល់នីតិវិធីដើម្បីធានាសុវត្ថិភាព។

## ជំពូកទី ៥
## អន្តរការី និងអ្នកផ្ដល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

**មាត្រា ២២.- ការទទួលខុសត្រូវរបស់អន្តរការី និងអ្នកផ្ដល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

១. អន្តរការី និងអ្នកផ្ដល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ឬ ព្រហ្មទណ្ឌពាក់ព័ន្ធនឹងព័ត៌មានដែលមានក្នុងកំណត់ត្រាអេឡិចត្រូនិកដែលពាក់ព័ន្ធនឹងការផ្ដល់សេវារបស់អន្តរការី និង អ្នកផ្ដល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះឡើយ

ក្នុងករណីដែលខ្លួនមិនមែនជាអ្នកផ្ញើកំណត់ត្រានោះ និង ក្នុងករណីដែល៖

ក. អន្តរការី និងអ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះមិនបានដឹងថាព័ត៌មានដែលបានផ្ញើនោះបង្កឱ្យមានការទទួលខុសត្រូវផ្នែក រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ឬ

ខ. អន្តរការី និងអ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះមិនបានដឹងអំពីអង្គហេតុឬកាលៈទេសៈដែលអាចឱ្យស្មានទុកថាព័ត៌មាននោះអាចបង្កឱ្យមានការទទួលខុសត្រូវផ្នែក រដ្ឋប្បវេណី ឬ ព្រហ្មទណ្ឌ ឬ

គ. អន្តរការីនិងអ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានដឹងនាពេលក្រោយថា ព័ត៌មាន ឬអង្គហេតុ ឬកាលៈទេសៈដែលអាចឱ្យស្មានទុកថា ព័ត៌មាននោះអាចបង្កឱ្យមានការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណី ឬ ព្រហ្មទណ្ឌ ហើយបានអនុវត្តតាមនីតិវិធីចំពោះព័ត៌មានខុសច្បាប់ និងការបរិហាកេរ្តិ៍ដូចមានចែងក្នុងមាត្រា ២៣ ខាងក្រោម។

២. អន្តរការី និងអ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនត្រូវតាមដានត្រួតពិនិត្យកំណត់ត្រាអេឡិចត្រូនិកណាមួយដែលដំណើរការដោយប្រព័ន្ធអេឡិចត្រូនិកដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ដើម្បីបញ្ជាក់ឲ្យច្បាស់ថាដំណើរការនៃកំណត់ត្រាអេឡិចត្រូនិកនោះ អាចបង្កើតជាបទល្មើស ឬនាំឱ្យមានការទទួលខុសត្រូវរដ្ឋប្បវេណីនោះឡើយ។

៣. បញ្ញត្តិនៃមាត្រានេះមិនត្រូវយកមកអនុវត្តដើម្បីឱ្យអន្តរការី និងអ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករួចផុតពី៖

ក. កាតព្វកិច្ចដែលបង្កើតឡើងដោយច្បាប់ ឬបទដ្ឋាននានា ឬ

ខ. កាតព្វកិច្ចអនុលោមតាមបទបញ្ជា ឬសេចក្តីបង្គាប់របស់តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ឬ

គ. កាតព្វកិច្ចតាមកិច្ចសន្យា។

**មាត្រា ២៣.- នីតិវិធីចំពោះព័ត៌មានខុសច្បាប់ និងការបរិហាកេរ្តិ៍**

១. ក្នុងករណីដែលអន្តរការី ឬ អ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានដឹងថាព័ត៌មានក្នុងកំណត់ត្រាអាចបង្កឱ្យមានការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ អន្តរការីឬអ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវចាត់ វិធានការជាបន្ទាន់ដូចខាងក្រោម៖

ក. ដកព័ត៌មានចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រង់របស់ អន្តរការី និងអ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងឈប់ផ្តល់សេវាពាក់ព័ន្ធនឹងព័ត៌មាននោះ។

ខ. ជូនដំណឹងដល់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឬស្ថាប័នពាក់ព័ន្ធនានាអំពីអង្គហេតុ និងអត្តសញ្ញាណនៃជនសង្ស័យ។

២. ក្នុងករណីដែលអន្តរការី និងអ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដឹងអំពីហេតុការណ៍ណាមួយ ឬស្ថានភាពណាមួយដែលអាចបណ្តាលឱ្យមានការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ អន្តរការី និងអ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវចាត់វិធានការជាបន្ទាន់ដូចខាងក្រោម៖

ក. អនុវត្តតាមនីតិវិធីដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឬក្រមនីតិវិធីព្រហ្មទណ្ឌដែលមានជា ធរមាន ឬក្រមសីលធម៌ពាក់ព័ន្ធនានា ឬ

ខ. ជូនដំណឹងដល់ដល់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

៣. នៅពេលដែលបានទទួលដំណឹងពាក់ព័ន្ធនឹងព័ត៌មានដូចមានចែងក្នុងកថាខណ្ឌ (២) នៃមាត្រានេះ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍អាចបញ្ជាឱ្យអន្តរការី និងអ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក៖

ក. ដកព័ត៌មានចេញពីប្រព័ន្ធពត៌មានដែលស្ថិតក្រោមការគ្រប់គ្រង់របស់ខ្លួន ឬ

ខ. ឈប់ផ្តល់សេវាដល់បុគ្គលនោះ ឬ

គ. ឈប់ផ្តល់សេវាពាក់ព័ន្ធនឹងកំណត់ត្រាអេឡិកត្រូនិក។

៤. អន្តរការី និងអ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមិនត្រូវទទួលខុសត្រូវ ទោះជាតាមរយៈកិច្ចសន្យា ឬក្រៅកិច្ចសន្យា ឬអនុលោមតាមច្បាប់ ប្រសិនបើអន្តរការី និងអ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកផ្តល់សេវាដែលពាក់ព័ន្ធនឹងព័ត៌មាននៅក្នុងកំណត់ត្រា ឬអនុវត្តដោយសុច្ចរិតទៅតាមបទបញ្ជារបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

៥. បុគ្គលណាមួយដែលជូនដំណឹងអំពីសកម្មភាពខុសច្បាប់ទៅដល់អន្តរការី និងអ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយដឹងថាការជូនដំណឹងនោះខុសពីការពិត ឬមានលក្ខណៈបោកបញ្ឆោត ត្រូវទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណី ឬព្រហ្មទណ្ឌពីបទល្មើសនោះ។

**មាត្រា ២៤.- ក្រមសីលធម៌ និង បទប្បញ្ញត្តិសម្រាប់ អន្តរការី និងអ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

១. អន្តរការី និងអ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវអនុវត្តតាមក្រមសីលធម៌ និងបទប្បញ្ញត្តិនានាដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងពាណិជ្ជកម្ម។

២. ក្រមសីលធម៌វិជ្ជាជីវៈ ឬ ក្រមសីលធម៌ដែលបានលើកឡើងក្នុងកថាខណ្ឌ ១ ខាងលើ នេះនឹងត្រូវកំណត់ និង រៀបរៀងឡើងដោយមានការចូលរួមសហការរវាងក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ក្រសួងពាណិជ្ជកម្ម និង អង្គការ ឬ សមាគមតំណាងអន្តរការី ឬ អ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬ អ្នកប្រើប្រាស់។

## ជំពូកទី ៦
## កិច្ចការពារអ្នកប្រើប្រាស់

**មាត្រា ២៥.- ព័ត៌មានអប្បបរមាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

១. បុគ្គលដែលប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកដើម្បីលក់ទំនិញ ឬសេវាទៅឱ្យអ្នកប្រើប្រាស់ត្រូវផ្តល់ព័ត៌មានត្រឹមត្រូវ ច្បាស់លាស់ និងងាយយល់បាន ហើយត្រូវមានព័ត៌មានយ៉ាងតិចដូចខាងក្រោម៖

ក. ឈ្មោះស្របច្បាប់របស់បុគ្គល អាសយដ្ឋានអាជីវកម្មដែលបានចុះបញ្ជី និងមធ្យោបាយអេឡិចត្រូនិកសម្រាប់ទំនាក់ទំនង ឬលេខទូរសព្ទ។

ខ. ទម្រង់ទំនាក់ទំនងដែលរហ័ស ងាយស្រួល និង មានប្រសិទ្ធិភាពរវាងអ្នកប្រើប្រាស់ជាមួយអ្នកលក់ ។

គ. ខចែង លក្ខខណ្ឌ និងសោហ៊ុយរបស់ទំនិញ ឬសេវានានាដែលពាក់ព័ន្ធនឹងប្រតិបត្តិការពាណិជ្ជកម្ម ជាពិសេស ខចែងនិងលក្ខខណ្ឌ និង មធ្យោបាយទូទាត់ ប្រាក់ និងព័ត៌មានលម្អិតពាក់ព័ន្ធនឹងការដក ឬ លុបចោលការបញ្ជាទិញ ការបញ្ឈប់ការ ការប្រគល់ និងការប្តូរទំនិញ និងការសងប្រាក់មកវិញ។

ឃ. ទំនិញ និងសេវាជាក់ស្តែងដែលដាក់លក់។

២. ព័ត៌មានដែលមានចែងក្នុងកថាខណ្ឌ (១) ត្រូវចាត់ទុកថាគ្រប់គ្រាន់សម្រាប់ឲ្យអ្នក

ប្រើប្រាស់អាចមានសមត្ថភាពក្នុងការសម្រេចចិត្តលើប្រតិបត្តិការពាណិជ្ជកម្ម និង សម្រាប់រក្សាទុកដោយត្រឹមត្រូវជាព័ត៌មាន។

**មាត្រា ២៦.- ទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំ**

បុគ្គលណាក៏ដោយ ទោះបីជាមានទីតាំងអាជីវកម្មក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ដែលផ្ញើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំទៅកាន់អ្នកប្រើប្រាស់ដែលស្ថិតនៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ឬតាមរយៈអន្តរការី ឬអ្នកផ្តល់សេវាទូរគមនាគមន៍ ត្រូវផ្តល់ជម្រើសច្បាស់លាស់និងងាយស្រួលសម្រាប់ឲ្យអ្នកប្រើប្រាស់អាចធ្វើការបដិសេធមិនទទួលយកទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំនោះ។

**មាត្រា ២៧.- ការការពារទិន្នន័យ**

បុគ្គលណាដែលរក្សាព័ត៌មានជាលក្ខណៈឯកជនក្រោមទម្រង់អេឡិចត្រូនិក ត្រូវធានាថា៖

ក. ព័ត៌មាននោះត្រូវបានការពារប្រកបដោយសុវត្ថិភាពគ្រប់កាលៈទេសៈសមហេតុផលដើម្បីចៀសវាង៖

១. ការបាត់បង់ និង

២. ការចូល ការប្រើប្រាស់ ការកែប្រែ ការបែកធ្លាយ ឬការបង្ហាញព័ត៌មានទាំងនោះ លើកលែងតែមានការអនុញ្ញាតពីម្ចាស់នៃព័ត៌មាននោះឬ ពីភាគីផ្សេងទៀតដែលមានការអនុញ្ញាតត្រឹមត្រូវតាមច្បាប់។

ខ. បុគ្គលដែលរក្សាព័ត៌មាននោះត្រូវប្រើគ្រប់មធ្យោបាយក្នុងការការពារសុវត្ថិភាពព័ត៌មានដែលផ្តល់ឲ្យតតីយជនដោយមានការអនុញ្ញាតក្នុងចំណុចទី២ នៃកថាខណ្ឌ (ក) ខាងលើ ដើម្បីជៀសវាងការប្រើប្រាស់ព័ត៌មានដោយគ្មានការអនុញ្ញាត។

**មាត្រា ២៨.- ការអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់**

បុគ្គលដែលប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកក្នុងសកម្មភាពពាណិជ្ជកម្មជាមួយអ្នកប្រើប្រាស់ ក៏ត្រូវអនុវត្តតាមបទប្បញ្ញត្តិនានាទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់ផងដែរ។

## ជំពូកទី៧

## សកម្មភាព និងប្រតិបត្តិការរបស់រាជរដ្ឋាភិបាល

**មាត្រា ២៩.- ការទទួលស្គាល់ទំនាក់ទំនងអេឡិចត្រូនិកដោយស្ថាប័នរដ្ឋ**

១. ក្រសួង ឬ ស្ថាប័នរាជរដ្ឋាភិបាលនានាអាចប្រើប្រាស់ទម្រង់អេឡិចត្រូនិកសម្រាប់

សកម្មភាពដូចខាងក្រោម៖

ក. ការចុះបញ្ជីឯកសារ ឬការបំពេញលក្ខខណ្ឌតម្រូវដែលកំណត់ថាឯកសារត្រូវបង្កើត ឬ រក្សាទុក ឬ

ខ.ការចេញអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតនានា ឬ

គ. បញ្ញត្តិសម្រាប់មធ្យោបាយ និង របៀបក្នុងការទូទាត់ប្រាក់។

២. នៅពេលដែល ក្រសួង ឬស្ថាប័នរាជរដ្ឋាភិបាលសម្រេចអនុវត្តកិច្ចការណាមួយ ដូចមានចែងក្នុងកថាខណ្ឌ(១) ខាងលើ ក្រសួង ឬស្ថាប័ននោះអាចបញ្ជាក់៖

ក. របៀប និងទម្រង់ ដែលទំនាក់ទំនងអេឡិចត្រូនិក ត្រូវចុះបញ្ជី បង្កើត រក្សាទុក ឬ បោះផ្សាយ និង

ខ. ប្រភេទនៃហត្ថលេខាដែលតម្រូវឱ្យធ្វើនៅពេលដែលមានការតម្រូវឱ្យចុះហត្ថលេខាលើទំនាក់ទំនងអេឡិចត្រូនិកនោះ និង

គ. របៀប និងទម្រង់ដែលហត្ថលេខានោះត្រូវភ្ជាប់ទៅលើទំនាក់ទំនងអេឡិចត្រូនិក និង

ឃ. ដំណើការគ្រប់គ្រង និងនីតិវិធីដែលសមស្របដើម្បីធានាភាពពេញលេញ សុវត្ថិភាព និងការរក្សាការសម្ងាត់នៃទំនាក់ទំនងអេឡិចត្រូនិក ឬការបង់ប្រាក់ និង

ង. លក្ខខណ្ឌដទៃផ្សេងទៀតពាក់ព័ន្ធនឹងគុណភាពនៃទំនាក់ទំនងអេឡិចត្រូនិក ការបង់ប្រាក់ដែលមានបញ្ជាក់ជាក់ស្តែងសម្រាប់ឯកសារជាក់លាក់ណាមួយ។

## ជំពូកទី៨
## ភស្តុតាងអេឡិចត្រូនិក

### មាត្រា ៣០.- ការទទួលយកជាទូទៅនៃភស្តុតាងអេឡិចត្រូនិក

គ្មានបទប្បញ្ញត្តិនៃវិធានស្តីពីភស្តុតាងណាមួយដែលយកមកអនុវត្ត ដើម្បីបដិសេធការទទួលយកកំណត់ត្រាអេឡិចត្រូនិក ធ្វើជាភស្តុតាងដោយគ្រាន់តែសម្អាងលើមូលដ្ឋានថា វាជាកំណត់ត្រាអេឡិចត្រូនិកនោះឡើយ ទោះបីជាភស្តុតាងនោះមិនស្ថិតក្នុងទម្រង់ដើមក៏ដោយ។

### មាត្រា ៣១.- សុក្រឹតភាពនៃប្រព័ន្ធអេឡិចត្រូនិក

១. នៅក្នុងនីតិវិធីតាមផ្លូវច្បាប់ សុពលភាពនៃភស្តុតាងអេឡិចត្រូនិកអាចត្រូវបានបញ្ជាក់តាមរយ:សុក្រឹតភាពនៃប្រព័ន្ធអេឡិចត្រូនិក ដែលបានកត់ត្រា ឬរក្សាទុកនូវទិន្នន័យណាមួយ។

២. លើកលែងតែមានភស្តុតាងផ្ទុយ សុក្រឹតភាពនៃប្រព័ន្ធអេឡិចត្រូនិក ដែលកំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រា ឬរក្សាទុក ត្រូវបានគេសន្មតក្នុងនីតិវិធីតាមផ្លូវច្បាប់ដូចខាងក្រោម៖

ក.នៅពេលដែលមានភស្តុតាងគាំទ្រដល់អង្គហេតុណាមួយដែលបញ្ជាក់ថាប្រព័ន្ធអេឡិចត្រូនិក ឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀត បានដំណើរការជាប្រក្រតីនៅគ្រប់រយៈពេលសំខាន់ៗ ឬ ក្នុងករណីដែលប្រព័ន្ធអេឡិចត្រូនិក ឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀតនោះមិនបានដំណើរការជាប្រក្រតី ឬឈប់ដំណើរការទាំងស្រុង តែសុក្រឹតភាពនៃកំណត់ត្រា មិនរងការប៉ះពាល់ដោយសារស្ថានភាពទាំងនោះទេ ហើយគ្មានមូលហេតុសមស្របណាផ្សេងទៀតដែលចោទជាមន្ទិលសង្ស័យលើសុក្រឹតភាពនៃកំណត់ត្រានោះឡើយ ឬ

ខ. នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថា កំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាចូល ឬរក្សាទុក ដោយភាគីដែលចូលរួមនៅក្នុងនីតិវិធីតាមផ្លូវតុលាការនោះ ហើយដែលភាគីមានផលប្រយោជន៍ប្រឆាំងទៅនឹងភាគីម្ខាងទៀតដែលមានបំណងប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះ ឬ

គ. នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថា កំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាចូល ឬរក្សាទុកតាមធម្មតា និងក្នុងគោលបំណងអាជីវកម្មធម្មតាដោយរូបវន្តបុគ្គល ដែលមិនមែនជាភាគីនៅក្នុងនីតិវិធីតាមផ្លូវច្បាប់ ហើយរូបវន្តបុគ្គលនោះមិនបានកត់ត្រាចូល ឬរក្សាទុកនូវកំណត់ត្រាអេឡិចត្រូនិកក្រោមការគ្រប់គ្រងរបស់ភាគីដែលមានបំណងប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះ។

**មាត្រា ៣២.- សុក្រឹតភាពនៃព័ត៌មាន**

១. លើកលែងតែមានភស្តុតាងផ្ទុយពីនេះ កំណត់ត្រាអេឡិចត្រូនិកដែលបានកត់ត្រា ឬរក្សាទុកនៅក្នុងប្រព័ន្ធអេឡិចត្រូនិក ត្រូវបានសន្មត់ថាមានសុក្រឹតភាពនៅក្នុងនីតិវិធីតាមផ្លូវច្បាប់ ប្រសិនបើកំណត់ត្រាអេឡិចត្រូនិកនោះ៖

ក. នៅពេញលេញ និងគ្មានការកែប្រែក្រៅពីការធ្វើបដិលេខបន្ថែមណាមួយ ឬ ការផ្លាស់ប្តូរដែលមិនសំខាន់ណាមួយដែលកើតឡើងនៅក្នុងដំណើរការជាប្រក្រតីនៃ~~ការ~~ទំនាក់ទំនង ការរក្សាទុក ឬ ការបង្ហាញ។

ខ. ត្រូវបានបញ្ជាក់ ឬចុះហត្ថលេខានៅក្នុងប្រព័ន្ធឌីជីថល តាមរយៈមធ្យោបាយ ដែលផ្តល់ឲ្យដោយអ្នកផ្តល់នីតិវិធីសុវត្ថិភាពដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ។

គ. មានសុក្រឹតភាព និងមានខ្លឹមសារដែលត្រូវបានបញ្ជាក់ ដោយក្រសួង ឬស្ថាប័នមានសមត្ថកិច្ច។

ឃ.ត្រូវបានកត់ត្រាទុកនៅក្នុងឧបករណ៍រក្សាទុកដែលមិនអាចយកទៅធ្វើឡើងវិញ ជាថ្មីម្តងទៀតបាន ឬ តាមមធ្យោបាយអេឡិចត្រូនិកផ្សេងទៀតដែលមិន អនុញ្ញាតឱ្យមានការកែប្រែទៅលើកំណត់ត្រាអេឡិចត្រូនិក។

ង. ត្រូវបានត្រួតពិនិត្យ និងបញ្ជាក់ពីសុក្រឹតភាពដោយអ្នកជំនាញដែលត្រូវបាន តែងតាំងដោយតុលាការ។

ច.នៅពេលដែលមានភស្តុតាងគាំទ្រដល់អង្គហេតុណាមួយ ដែលបញ្ជាក់ថាប្រព័ន្ធ អេឡិចត្រូនិក ឬ ឧបករណ៍ស្រដៀងគ្នាផ្សេងទៀត បានដំណើរការជាប្រក្រតី នៅគ្រប់រយៈពេលសំខាន់ៗ ឬ ក្នុងករណីដែលប្រព័ន្ធអេឡិចត្រូនិក ឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀតនោះមិនបានដំណើរការជាប្រក្រតី ឬឈប់ ដំណើរការទាំងស្រុង តែសុក្រឹតភាពនៃកំណត់ត្រា មិនរងការប៉ះពាល់ដោយ សារស្ថានភាពទាំងនោះទេ ហើយគ្មានមូលហេតុសមស្របណាផ្សេងទៀត ដែលចោទជាមន្ទិលសង្ស័យលើសុក្រឹតភាពនៃកំណត់ត្រានោះឡើយ ឬ

ឆ.នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថា កំណត់ត្រាអេឡិចត្រូនិកត្រូវ បានកត់ត្រា ឬរក្សាទុក ដោយភាគីដែលចូលរួមនៅក្នុងនីតិវិធីតាមផ្លូវច្បាប់នោះ ហើយដែលភាគីមានទំនាស់ផលប្រយោជន៍ទៅនឹងភាគីម្ខាងទៀត ដែលមានបំណងប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះឬ

២. នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថា កំណត់ត្រាអេឡិចត្រូនិកត្រូវបាន កត់ត្រា ឬរក្សាទុកតាមធម្មតា និងក្នុងគោលបំណងអាជីវកម្មធម្មតា ដោយរូបវន្តបុគ្គលដែល មិនមែនជាភាគីនៅក្នុងនីតិវិធីតាមផ្លូវច្បាប់ ហើយរូបវន្តបុគ្គលនោះមិនបានកត់ត្រា ឬរក្សាទុកនូវ កំណត់ត្រាអេឡិចត្រូនិក ក្រោមការគ្រប់គ្រងរបស់ភាគីដែលមានបំណងប្រើប្រាស់កំណត់ ត្រាអេឡិចត្រូនិកនោះ។

៣. នៅពេលដែលរបាយការណ៍ ត្រូវបានកត់ត្រាទុកនៅក្នុងកំណត់ត្រាអេឡិចត្រូនិក ដែលត្រូវបានបង្កើតឡើងដោយប្រព័ន្ធអេឡិចត្រូនិក មិនត្រូវបានចាត់ទុកថាជាពាក្យចាមអារាម

ទេនោះ របាយការណ៍ទាំងនោះអាចទទួលយកបាន ប្រសិនបើលក្ខខណ្ឌ ដូចដែលមានចែងនៅក្នុងកថាខណ្ឌ (២) ទាក់ទងនឹងកំណត់ត្រាអេឡិចត្រូនិកនោះត្រូវបានបំពេញ។

**មាត្រា ៣៣.- ឯកសារដែលបានបោះពុម្ពចេញ**

កំណត់ត្រាអេឡិចត្រូនិកដែលបានធ្វើឡើងនៅក្នុងទម្រង់ជាឯកសារដែលបានបោះពុម្ពចេញ ហើយដែលបានអនុវត្ត ផ្អែកលើ ឬប្រើប្រាស់យ៉ាងច្បាស់លាស់ និងស្រប ទៅនឹងនីតិវិធីតាមផ្លូវច្បាប់ ត្រូវចាត់ទុកជាកំណត់ត្រាសម្រាប់គោលបំណងប្រើប្រាស់ជាភស្តុតាងបាន។

**មាត្រា ៣៤.- បន្ទុកក្នុងការបង្ហាញអំពីយថាភូតភាពនៃភស្តុតាងអេឡិចត្រូនិក**

១. បុគ្គលដែលស្នើសុំបង្ហាញកំណត់ត្រាអេឡិចត្រូនិកតាមនីតិវិធីណាមួយ បុគ្គលនោះត្រូវមានបន្ទុកបង្ហាញពីយថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិកដោយមានភស្តុតាងគាំទ្រដល់កំណត់ត្រាដែលបុគ្គលនោះបានបង្ហាញ។

២. ក្នុងករណីដែលមានបទប្បញ្ញត្តិណាមួយការពារបុគ្គលងាយរងគ្រោះ ហើយដែលមានកំណត់អំពីបន្ទុកនៃភស្តុតាងដែលមានអត្ថប្រយោជន៍ដល់បុគ្គលទាំងនោះច្រើនជាងច្បាប់នេះ បទប្បញ្ញត្តិនោះត្រូវមានអាទិភាពលើមាត្រានេះ។

**មាត្រា ៣៥.- បទដ្ឋាននៃកំណត់ត្រអេឡិចត្រូនិក**

ក្នុងគោលបំណងកំណត់នៅក្នុងបទបញ្ញត្តិផ្សេងៗ អំពីកំណត់ត្រាអេឡិចត្រូនិកត្រូវបានទទួលយក ឬមិនទទួលយក អាចបង្ហាញភស្តុតាងពាក់ព័ន្ធនឹងបទដ្ឋាន នីតិវិធី ការប្រើប្រាស់ ឬការអនុវត្តអំពីរបៀបដែលកំណត់ត្រាអេឡិចត្រូនិកនោះត្រូវបានកត់ត្រាចូល ឬរក្សាទុក បទដ្ឋាន នីតិវិធី ការប្រើប្រាស់ ឬការអនុវត្តនោះត្រូវស្របទៅតាមប្រភេទនៃអាជីវកម្ម ឬកិច្ចការដែលប្រើប្រាស់ ការកត់ត្រាចូល ឬការរក្សាទុកកំណត់ត្រាអេឡិចត្រូនិក ព្រមទាំងលក្ខណៈ និងគោលបំណងនៃកំណត់ត្រាអេឡិចត្រូនិកនោះ។

**មាត្រា ៣៦- នីតិវិធីផ្សេងទៀតក្នុងការបង្កើតភស្តុតាងអេឡិចត្រូនិក**

បន្ថែមលើមធ្យោបាយបង្ហាញភស្តុតាងដូចមានចែងក្នុងមាត្រាមុនៗនៃច្បាប់នេះ ភស្តុតាងអេឡិចត្រូនិកពាក់ព័ន្ធនឹងកំណត់ត្រាអេឡិចត្រូនិកមួយចំនួនអាចត្រូវបានបង្កើតឡើង ដោយបច្ចេកទេស និងនីតិវិធីផ្សេងទៀតបាន ដូចជាការបញ្ជាក់របស់ស្ថាប័នមានសមត្ថកិច្ច ដែលកត់ត្រានៅក្នុងទម្រង់ ដែលមិនអាចកែប្រែបាន និងកោសល្យវិច្ច័យលើប្រព័ន្ធអេឡិចត្រូនិកក្នុងការស្រាវជ្រាវរបស់តុលាការ។

**មាត្រា ៣៧.- ការទទួលយកកំណត់ត្រាអេឡិចត្រូនិកពីបណ្តាប្រទេសផ្សេងទៀត**

នៅពេលដែលភស្តុតាងអេឡិចត្រូនិកដែលមានការបញ្ជាក់ ពីយុត្តាធិការនៃបណ្តាប្រទេសផ្សេងទៀត ត្រូវទទួលស្គាល់ជាភស្តុតាង ប្រសិនបើការបញ្ជាក់នោះមានសុក្រឹតភាពនៃប្រព័ន្ធអេឡិចត្រូនិក ស្របតាមបទដ្ឋានដែលប្រហាក់ប្រហែលនឹងបទដ្ឋានដូចមានចែងក្នុងមាត្រា ៣៥ នៃច្បាប់នេះ។

**មាត្រា ៣៨.- ការទទួលស្គាល់ព័ត៌មានអេឡិចត្រូនិកពីបណ្តាប្រទេសផ្សេងទៀត**

ដើម្បីកំណត់ថាព័ត៌មានក្នុងទម្រង់អេឡិចត្រូនិកមួយអាចទទួលយកបាន ឬមិនអាចទទួលយកបាន ឬ អាចទទួលយកបានកម្រិតណា គឺមិនចាំបាច់គិតពីទីតាំងដែលព័ត៌មាននោះត្រូវបានបង្កើតឡើង ឬត្រូវបានប្រើប្រាស់ ឬទីកន្លែងនៃអាជីវកម្មដែលបានបង្កើតឡើងនោះឡើយ ឲ្យតែកំណត់ត្រាអេឡិចត្រូនិកនោះអាចចូលប្រើប្រាស់បាននៅក្នុង ព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ៩
## ការទូទាត់/ផ្ទេរប្រាក់ជាអេឡិចត្រូនិក

**មាត្រា ៣៩.- ប្រតិបត្តិការទូទាត់ជាអេឡិចត្រូនិក**

បុគ្គលណាដែលធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ផ្តល់សេវាទូទាត់ ចេញផ្សាយឧបករណ៍ទូទាត់អេឡិចត្រូនិក ឬផ្តល់មធ្យោបាយទូទាត់អេឡិចត្រូនិក ឬធ្វើប្រតិបត្តិការណាដែលត្រូវបានចាត់ទុកថាជាការផ្តល់ការទូទាត់សងប្រាក់អេឡិចត្រូនិកដល់សាធារណជន ត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា ។

**មាត្រា ៤០.- ការទទួលខុសត្រូវរបស់អ្នកផ្តល់សេវាទូទាត់**

អ្នកផ្តល់សេវាទូទាត់មិនត្រូវផ្តល់ជូនអតិថិជននូវឧបករណ៍ទូទាត់ដែលមិនបានស្នើសុំទេ លើកលែងតែករណីត្រូវពន្យារ ឬប្តូរឧបករណ៍នោះ ។

មុនពេលធ្វើប្រតិបត្តិការផ្ទេរប្រាក់អេឡិចត្រូនិចអ្នកផ្តល់សេវាត្រូវបញ្ជាក់ឲ្យបានច្បាស់ពីអត្តសញ្ញាណរបស់អតិថិជននិងផ្ទៀងផ្ទាត់ឡើងវិញនូវភាពត្រឹមត្រូវនៃការផ្ទេរប្រាក់អេឡិចត្រូនិច ។ អ្នកផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវលើករណីដូចខាងក្រោម៖

១. ប្រតិបត្តិការកើតឡើងដោយគ្មានការអនុញ្ញាតពីអតិថិជន។

២. ប្រតិបត្តិការកើតឡើងបន្ទាប់ពីដឹងថាមានការបន្លំបាត់បង់ ឬចោរកម្មឧបករណ៍ផ្ទេរប្រាក់អេឡិចត្រូនិច។

៣. ប្រតិបត្តិការកើតឡើងបន្ទាប់ពីមានការជូនដំណឹងពីអតិថិជនដូចមានចែងក្នុងមាត្រា ៤៧ ស្តីពីការទទួលខុសត្រូវរបស់អតិថិជនក្នុងច្បាប់នេះ។

៤. ការខកខានមិនបានប្រតិបត្តិតាមបញ្ជារបស់អតិថិជន ឬការប្រតិបត្តិខុសពីបញ្ជាអតិថិជន។

៥. ភាពមិនប្រក្រតីនៃប្រព័ន្ធបច្ចេកទេស កំហុសក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកទេស ឬភាពខ្វះខាតនៃឧបករណ៍ផ្ទេរប្រាក់អេឡិចត្រូនិច ។

អ្នកផ្តល់សេវាទូទាត់អាចរួចផុតពីការទទួលខុសត្រូវបានតែក្នុងករណីប្រធានស័ក្តិ ឬហេតុការផ្សេងៗ ទៀតដែលហួសពីសមត្ថកិច្ចគ្រប់គ្រងរបស់អ្នកផ្តល់សេវា ឬកំហុសរបស់អតិថិជនផ្ទាល់ប៉ុណ្ណោះ ។

ក្នុងករណីដែលអ្នកផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវ អ្នកផ្តល់សេវាទូទាត់ត្រូវសងថ្លៃខូចខាតជូនអតិថិជន ក្នុងរយៈពេលមិនឲ្យលើសពី១ខែគិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងពីអតិថិជនដូចមានចែងក្នុងមាត្រា ៤១ ស្តីពីការទទួលខុសត្រូវរបស់អតិថិជន ក្នុងច្បាប់នេះ នូវថ្លៃប្រតិបត្តិការដែលមានទំនាស់ សោហ៊ុយ និងការពិន័យក្នុងការបង់ប្រាក់យឺតយ៉ាវដែលកើតចេញពីប្រតិបត្តិការនេះដោយមិនគិតពីការសងថ្លៃខូចខាតដទៃទៀតដែលអាចកើតឡើងចំពោះអតិថិជនឡើយ ។

**មាត្រា ៤១.- ការទទួលខុសត្រូវរបស់អតិថិជន**

អតិថិជនត្រូវជូនដំណឹងដល់អ្នកផ្តល់សេវាទូទាត់ពីប្រតិបត្តិការលើគណនីរបស់ខ្លួនដែលកើតឡើងដោយគ្មានការអនុញ្ញាតឬកំហុស ឬភាពមិនត្រឹមត្រូវផ្សេងទៀត ។

អតិថិជនត្រូវជូនដំណឹងដល់អ្នកផ្តល់សេវាទូទាត់ ឬអង្គភាពដែលទទួលបានការអនុញ្ញាតពីអ្នកផ្តល់សេវាទូទាត់ អំពីការបាត់បង់ឬចោរកម្មនូវឧបករណ៍ផ្ទេរប្រាក់អេឡិចត្រូនិច មធ្យោបាយផ្ទេរប្រាក់ ឬទិន្នន័យដែលអាចឲ្យគេប្រើប្រាស់ឧបករណ៍នោះបាន។ ការជូនដំណឹងនេះត្រូវធ្វើភ្លាមជាលាយលក្ខណ៍អក្សរ ឬមធ្យោបាយផ្សេងទៀតដែលអាចជឿទុកចិត្តបាន មិនឲ្យលើសពីពីរថ្ងៃ បន្ទាប់ពីបានដឹងអំពីការបាត់បង់ឬចោរកម្មលើឧបករណ៍ផ្ទេរប្រាក់អេឡិចត្រូនិចនោះ ។

ទោះបីមានការបាត់បង់ឬការខូចខាតក្រោមរូបភាពណាក៏ដោយ អតិថិជនត្រូវទូទាត់នូវចំនួនទឹកប្រាក់មិនឲ្យលើសពីចំនួន ២០០.០០០ រៀល (ពីរសែនរៀល) ឡើយ ដើម្បីដំណើរការនីតិវិធីនៃការតវ៉ា ។

ក្នុងករណីមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ការបាត់បង់ឬការខូចខាតនោះជាកំហុសរបស់អតិថិជន អ្នកផ្តល់សេវាទូទាត់មានសិទ្ធិទាមទារឲ្យអតិថិជនទទួលខុសត្រូវទូទាត់ទាំងស្រុង ចំពោះការបាត់បង់ឬការខូចខាតនោះ ។

ក្នុងករណីមិនមានភស្តុតាងបញ្ជាក់ពីកំហុសរបស់អតិថិជន អ្នកផ្តល់សេវាត្រូវប្រគល់ចំនួនទឹកប្រាក់ ២០០.០០០ រៀល (ពីរសែនរៀល) ជូនអតិថិជនវិញ ដោយគ្មានលក្ខខណ្ឌ ។

**មាត្រា ៤២.- ការក្លែងឯកសារ**

ការប្រព្រឹត្តការក្លែងបន្លំដូចបានកំណត់ខាងក្រោមគឺជាបទល្មើស និងត្រូវរងការផ្តន្ទាទោសដូចមានកំណត់ក្នុងច្បាប់នេះ។

ក.ដោយមានគោលបំណងឆបោក អ្នកចេញ អ្នកផ្តល់ឥណទាន ឬបុគ្គលណាមួយផ្សេងទៀត បុគ្គលដែលក្លែងបន្លំ ឬកែប្រែកាតទៅជាទម្រង់ណាមួយ ឬប្រើប្រាស់កាតនោះ ឬអ្នកដែលមានកាតក្លែងបន្លំ ឬវិក្ក័យប័ត្រ សំបុត្រធានាឯកសារបញ្ជាក់អំពីការទិញ ឬការបង្ហាញ ឬបទបង្ហាញផ្សេងទៀតនៃកាតក្លែងបន្លំជាកម្មសិទ្ធិ ការឃុំគ្រង ឬការគ្រប់គ្រងរបស់ខ្លួន ។

ខ. បុគ្គលដែលមិនមែនជាអ្នកផលិតឬមិនមែនជាអ្នកចេញកាតដែលគ្មានការអនុញ្ញាត ហើយកាន់កាប់កាតក្លែងបន្លំត្រូវបានសន្មតថាមាន ចេតនា ក្លែងបន្លំដូចមានចែងនៅក្នុង កថាខណ្ឌ(ក) ខាងលើ។

គ. បុគ្គលដែលក្លែងបន្លំកាតទាំងស្រុង ឬមួយផ្នែក ដែលមានលក្ខណៈដូចគ្នានឹងកាតដែលចេញដោយអ្នកចេញត្រូវបានចាត់ទុកជាបទល្មើស។

ឃ. បុគ្គលដែលក្លែងកាតដោយគ្មានការអនុញ្ញាតពីអ្នកចេញ ដែលមានដាក់ឈ្មោះលើកាត នៅពេលគាត់បំពេញកាតដោយការបន្ថែមព័ត៌មានណាមួយដោយរួមទាំងហត្ថលេខារបស់អ្នកកាន់កាប់កាត ដែលអ្នកចេញតម្រូវឲ្យលេចឡើងនៅលើកាតមុនពេលវាអាចប្រើប្រាស់បានដោយអ្នកកាន់កាប់កាត ។

## ជំពូកទី ១០
## បទល្មើសប្រឆាំង នឹងប្រព័ន្ធព័ត៌មាន និងទិន្នន័យកុំព្យូទ័រ

**មាត្រា ៤៣**.- ការលួចចូលប្រព័ន្ធ និងការជ្រៀតជ្រែក

លើកលែងតែនៅពេលមានច្បាប់អនុញ្ញាត បុគ្គលណាម្នាក់មិនត្រូវមានគោលបំណង៖

១.ចូលទៅកាន់ ឬស្វះស្វែងចូលទៅកាន់ប្រព័ន្ធឬបណ្តាញអេឡិចត្រូនិកនោះ

២. ទាញយក ថតចម្លង ឬស្រង់យកទិន្នន័យ ប្រព័ន្ធទិន្នន័យអេឡិចត្រូវនិក ឬព័តិមាន ពីប្រព័ន្ធ ឬបណ្តាញអេឡិចត្រូនិកនោះ ដោយរួមទាំងព័តិមាន ឬទិន្នន័យដែលត្រូវបានកាន់កាប់ ឬរក្សាទុកដែលអាចផ្លាស់ប្តូរទីតាំងបាន

៣. ណែនាំឬជម្រុញឲ្យមានការណែនាំអំពីកម្មវិធីចម្លងមេរោគ ឬលេខកូដចម្លងមេរោគទៅក្នុងប្រព័ន្ធ ឬបណ្តាញអេឡិចត្រូនិក

៤. បំផ្លាញ ឬនាំឲ្យខូចខាតចំពោះប្រព័ន្ធ ឬបណ្តាញអេឡិចត្រូនិកទិន្នន័យ ប្រព័ន្ធទិន្នន័យអេឡិចត្រូនិក ឬកម្មវិធីផ្សេងទៀតដែលស្ថិតក្នុងប្រព័ន្ធ ឬបណ្តាញអេឡិចត្រូនិកនោះ

៥. បង្អាក់ ឬបង្កឲ្យមានការបដិសេធចំពោះប្រព័ន្ធ ឬបណ្តាញអេឡិចត្រូនិក

៦.បដិសេធ ឬបង្កឲ្យមានការបដិសេធចំពោះការចូលទៅកាន់ចំពោះបុគ្គលដែលត្រូវបានអនុញ្ញាតឲ្យចូលទៅកាន់ប្រព័ន្ធ ឬបណ្តាញអេឡិចត្រូនិកដោយមធ្យោបាយណាមួយ

៧. ផ្តល់ជាជំនួយដល់បុគ្គលឲ្យសម្របសម្រួលសិទ្ធិចូលទៅកាន់ប្រព័ន្ធឬបណ្តាញអេឡិចត្រូនិកដែលផ្ទុយ និងបញ្ញត្តិនៃច្បាប់នេះ

៨. យកកម្រៃសេវាពីការរៀបចំផ្តល់អត្ថប្រយោជន៍ឲ្យចូលទៅក្នុងគណនីរបស់បុគ្គលផ្សេងទៀតដោយ លុកលុយចូលទៅក្នុងប្រព័ន្ធ ឬបណ្តាញអេឡិចត្រូនិក

៩. បំផ្លាញ លុបចោល ឬកែប្រែដោយឆន្ទៈនូវព័តិមានដែលស្ថិតក្នុងប្រព័ន្ធអេឡិចត្រូនិកឬកាត់បន្ថយតម្លៃ ឬអត្ថប្រយោជន៍របស់សេវា ឬធ្វើឲ្យខូចខាតដោយមធ្យោបាយណាមួយ ឬ

១០. លួច លាក់បាំង បំផ្លាញឬកែប្រែ ឬបង្កបុគ្គលម្នាក់ឲ្យលួច លាក់បាំងបំផ្លាញ ឬកែប្រែបញ្ជីអេឡិចត្រូនិកណាមួយសម្រាប់ប្រព័ន្ធអេឡិចត្រូនិកក្នុងគោលបំណងបង្កការខូចខាត។

**មាត្រា ៤៤.- ការផ្ញើសារ គំរាមតាមរយៈសេវាទំនាក់ទំនង**

១. បុគ្គលមិនត្រូវផ្ញើដោយមធ្យោបាយអេឡិចត្រូនិក ឬគ្រឿងឧបករណ៍អេឡិចត្រូនិច៖

ក. ព័តិមានដែលមានលក្ខណៈប្រមាថសុទ្ធសាធ ឬមានលក្ខណៈគំរាមកំហែង

ខ. ព័តិមានដែលខ្លួនដឹងថាខុស ប៉ុន្តែដោយគោលបំណងបង្កនូវការរុកកួន ផលអាក្រក់ ហានិភ័យ ការរំខាន ការជេរប្រមាថ ការបង្ករបួសស្នាម ការគំរាមកំហែងព្រហ្មទណ្ឌ

អមិត្តភាព សម្អប់ ឬឆន្ទៈអាក្រក់ នៅតែចចេសធ្វើដោយការទាញយកផលចំណេញពីប្រព័ន្ធអេឡិចត្រូនិក ឬឧបករណ៍អេឡិចត្រូនិកនោះ

គ. សំបុត្រអេឡិចត្រូនិក ឬសារអេឡិចត្រូនិកសម្រាប់គោលបំណងបង្កនូវការរុកកួន ឬផលអាក្រក់ឬដើម្បីនាំអ្នកទទួលទំនាក់ទំនងឬអ្នកទទួលនៅកន្លែងខុសពីប្រភពដើមនៃសារនេះ។

២. សម្រាប់គោលបំណងនៃមាត្រានេះ ពាក្យថា សំបុត្រអេឡិចត្រូនិក ឬសារអេឡិចត្រូនិក មានន័យថាជាសារ ឬព័ត៌មានដែលត្រូវបានបង្កើតឡើងឬបញ្ជូន ឬទទួលបានពីប្រព័ន្ធអេឡិចត្រូនិក ដោយរួមទាំងឯកសារភ្ជាប់ ក្នុងអត្ថបទរូបភាព សោតកម្ម វីដេអូ និងកំណត់ត្រាអេឡិចត្រូនិកណាមួយផ្សេងទៀតដែលអាចបញ្ជូនជាមួយសារ។

**មាត្រា ៤៥.- បទលួចអត្តសញ្ញាណ**

បុគ្គលមិនត្រូវប្រើប្រាស់ហត្ថលេខាអេឡិចត្រូនិក លេខសម្ងាត់ ឬភិនភាគអត្តសញ្ញាណពិសេសរបស់បុគ្គលផ្សេងទៀតដោយក្លែងបន្លំ ឬមិនស្មោះត្រង់ឡើយ។

**មាត្រា ៤៦.- ការបរិហារកេរ្តិ៍តាមប្រព័ន្ធអេឡិចត្រូនិក**

បុគ្គលម្នាក់មិនត្រូវបរិហារកេរ្តិ៍បុគ្គលម្នាក់ទៀតដោយប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកឡើយ។

**មាត្រា ៤៧.- បទក្លែងបន្លំតាមប្រព័ន្ធអេឡិចត្រូនិក**

